OLD VERSION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 18-Aug-2015, 13:28
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥**

**ម៉ោង ០៨:៥៨នាទី**

**សវនាការលើកទី៣១១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន ជាប្រធាន
ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*
ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៉ង
កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត
លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*
លោក ស្រ៊ា រតនៈ
លោក ឌេល លីសាក់ *(Dale Lysak)*
លោក ត្រាវីស ហ្វារ *(Mr.Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ
លោក វិុចទ័រ កូប៉េ *(Mr.Victor KOPPE)*
លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វលក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
| --- | --- |
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក ឌេល ឌីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ទី ស្រ៊ុនណា | ខ្មែរ |
| លោក ឡុត សួយ (2-TCW-889) | ខ្មែរ |
| លោក ឈិត យឿក (2-TCW-937) | ខ្មែរ |

# ខ្លឹមសារ

**ការសួរសំណួរទៅសាក្សី៖ លោក ឡុត សួយ** (2-TCW-889)

សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី ....................ទំព័រ ២
សួរដោយលោក គង់ សំអុន ផ្តើមពី ....................ទំព័រ ៨

**ការសួរសំណួរទៅសាក្សី៖ លោក ឈិត យឿក** (2-TCW-937)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ១៤
សួរដោយលោក នីកូឡាស គូមជែន ផ្តើមពី ....................ទំព័រ ១៧
សួរដោយលោកស្រី ទី ស្រ៊ីនណា ផ្តើមពី ....................ទំព័រ ៥២
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ៧០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៨:១២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ឡុត សួយ ជាបន្តទៀត -- បញ្ចប់ ហើយនិងផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-937។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីនិងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះគឺ លោក ឡុត សួយ លោក និងមេធាវីប្រឹក្សាមានវត្តមានរួចហើយនៅបន្ទប់សវនាការនេះ។ ហើយសាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបន្ទាប់នេះ គឺសាក្សីដែលមានរហស្សនាម 2-TCW-937 សាក្សីសាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីម្សិលមិញនេះ។ សាក្សីមានមេធាវីប្រឹក្សាគឺលោក មឿង សុវណ្ណ។ សូមអរគុណលោកប្រធាន។

[០៩:00:00]

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។

ហើយជាដំបូងនេះ អង្គជំនុំជម្រះ សម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខ

ភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឱ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ នេះ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ បានកំណត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះកម្រិតមធ្យមកាន់តែខ្លាំងពេលធ្វើចលនា និងបានផ្តល់អនុសាសន៍ថា សូមឱ្យអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាដល់លោកមេធាវីការពារក្តីលោក ខៀវ សំផន បន្តសំណួរជាបន្តទៀត។

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោកស្រីចៅក្រម និងភាគីទាំងអស់។ ជម្រាបសួរលោកសាក្សី។ ខ្ញុំនឹងបន្ត និងបញ្ចប់សំណួររបស់ខ្ញុំ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** កាលពីម្សិលមិញលោកបានលើកឡើងអំពីអង្គហេតុមួយចំនួនជាមួយលោក កូប៉េ ជាពិសេសទំនាក់ទំនងរវាងភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ា។ ខ្ញុំចង់ដឹងថា តើលោកដឹងថាមេដឹកនាំភូមិភាគពាយ័ព្យ និងភូមិបូព៌ានេះមានទំនាក់ទំនងហ្នឹងគ្នាយ៉ាងដូចម្តេចខ្លះ?

**លោក ឡូត ស្មួយ៖**

**ឆ៖** បាទខ្ញុំអត់ដឹងថាគេទំនាក់ទំនងយ៉ាងណាទេ។ ឮតែថ្នាក់ក្រោមតូចតាចដូចគ្នានេះឯង គេនិយាយថា ភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យយើងជាមិត្តភាព។

**ស៖** ដោយមិននិយាយអំពីការប្រាស្រ័យទាក់ទងគ្នា តើលោកដឹងថា សោ ភឹម ហើយនិង ជាល គាត់មានទំនាក់ទំនងអ្វីនឹងគ្នាដែរ?

**ឆ៖** ដល់គេអ្នកធំអ៊ីចុះ ខ្ញុំអត់ដឹងទេ។ ខ្ញុំតូចតាចនៅតែៗតាមអាងត្រពាំងថ្ម។

[០៩:០៣:៥៦]

**ស៖** លោកបានឆ្លើយថា លោកបានស្តាប់ឮពីទាហានដូចគ្នាថា ភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ាហ្នឹងមានទំនាក់ទំនងជាមួយនឹងគ្នា។ អ៊ីចឹងលោកអាចរៀបរាប់ឲ្យបានច្បាស់បន្តិចទេថា តើពួកទាហានហ្នឹងប្រាប់លោកថា ទំនាក់ទំនងជាមួយភូមិភាគទាំងពីរហ្នឹងយ៉ាងម៉េចខ្លះដែរ?

**ឆ៖** ពេលគេនិយាយថា ភូមិភាគបូព៌ា និងភូមិភាគយើងនេះជាបងប្អូនគ្នា។ គេគ្រាន់ប្រាប់តែប៉ុណ្ណោះឯង។

**ស៖** គេមានប្រាប់លោកថាភូមិភាគទាំងពីរហ្នឹង ជាបងប្អូនគ្នាហ្នឹង តាំងពីពេលណាមកទេ?

**ឆ៖** ពេលនោះខ្ញុំដឹងអត់ដល់ដែរ។ ពេលដែលសម្រាកលេង ជួនកាលអង្គុយនិយាយគ្នាអ៊ីចឹងទៅគេប្រាប់ទៅ ប៉ុន្តែពេលដែលបងប្អូនពីណាមក ខ្ញុំអត់ដឹងដែរ។

**ស៖** នៅក្នុងឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា គឺE3/9060 ជាភាសាបារាំង 01123699, ជាភាសាអង់គ្លេស 00728747 ទៅដល់ 48, ជាភាសាខ្មែរគឺ 00733053 លោកបាននិយាយអំពីកិច្ចប្រជុំមួយដែលលោកបានស្តាប់ឮ ដែលគេនិយាយអំពីផែនការរវាងភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ា។

សំណួរទី១របស់ខ្ញុំ ខ្ញុំចង់ដឹងថា តើលោកដឹងដោយរបៀបណា នៅពេលដែលលោកនិយាយថាភូមិភាគបូព៌ាចង់រត់ចូលព្រៃដើម្បីប្រមូលកម្លាំងជាមួយភូមិភាគពាយ័ព្យ? តើលោកដឹងយ៉ាងដូចម្តេចថាខាងភូមិភាគបូព៌ាហ្នឹង ចង់រត់ចូលព្រៃដើម្បីប្រមូលកម្លាំងទៅរួបរួមជាមួយភូមិភាគពាយ័ព្យនោះ?

**ឆ៖** ព្រោះខ្ញុំឮពួកកងតំបន់គេនិយាយ ដែលគេរត់មកនៅនឹងស្រុកភ្នំស្រុក។

**ស៖** កាលពីម្សិលមិញ គឺក្រោយម៉ោងប្រាំបួន ម្ភៃប្រាំពីរនាទី លោកបានលើកឡើងអំពីកិច្ចប្រជុំមួយចំនួនរវាង តាណាក និង តាវ៉ាល់ នៅការដ្ឋានទំនប់ត្រពាំងថ្ម។ តើខ្លួនលោកៗផ្ទាល់ លោកបានចូលរួមក្នុងកិច្ចប្រជុំទាំងនុ៎ងទេ?

[០៩:០៧:២០]

**ឆ៖** ពីព្រោះខ្ញុំតូចតាច មិនដែលបានទៅចូលប្រជុំនឹងគេទេ មានតែការយាមកាមនៅតែងក្រៅពួគេថា ហៅគាត់ទៅប្រជុំ ទៅប្រជុំទៅ ពួកខ្ញុំក៏នៅកន្លែងទៅ។

**ស៖** ចុះបើលោកមិនបានចូលរួមផង អ៊ីចឹងអ្នកណាជាអ្នកនិយាយប្រាប់លោក អំពីខ្លឹមសារនៃកិច្ចប្រជុំនុ៎ង?

**ឆ៖** ពីព្រោះគាត់មកវិញ គាត់ៗធ្វើការប្រជុំប្រាប់កូនចៅនៅក្រោមឯនេះ នៅតាមកន្លែង។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន ខ្ញុំគ្រាន់តែសូមបញ្ជាក់ចំណុចមួយឲ្យបានច្បាស់សម្រាប់ប្រតិចារឹកដោយសារមេធាវីការពារក្តី គឺថាសំណួរហាក់ដូចជាមិនច្បាស់លាស់ទេ។ កិច្ចប្រជុំដែលលើកឡើងនៅក្នុងសម្រង់នេះ គឺជាកិច្ចប្រជុំរវាងតំបន់៥ និងកងទ័ពស្រុក មិនមែនជាកិច្ចប្រជុំរវាងភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យនោះទេ។ យ៉ាងហោចណាស់ ក្នុងការបកប្រែ ខ្ញុំស្តាប់ឮទៅ ដូចជាមិនច្បាស់លាស់។ ប្រតិចារឹកច្បាស់លាស់ហើយ គឺជាកិច្ចប្រជុំ មិនមែនជាកិច្ចប្រជុំរវាងភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យនោះទេ។

[០៩:០៩:១៥]

**កញ្ញា អង់តា ហ្គីសសេ៖**

នេះមិនមែនជាខ្លឹមសារនៃសំណួររបស់ខ្ញុំទេ ប្រហែលជាមានបញ្ហាហើយ។ ដំបូង ខ្ញុំនិយាយអំពីទំនាក់ទំនងរវាងភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ បន្ទាប់មកទៀត ខ្ញុំនិយាយអំពីកិច្ចប្រជុំរវាង តាណាក និង តាវ៉ាល់។ អ៊ីចឹងខ្ញុំគិតថា ប្រហែលជា -- នេះ ជាចំណុចពីរផ្សេងគ្នាទេ លោកសហព្រះរាជអាជ្ញា។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំមិនដឹងថា អំមិញលោកឆ្លើយទៅនឹងសំណួរខ្ញុំហើយឬនៅ លោកសាក្សី? ឥឡូវខ្ញុំសួរម្តងទៀតតែម្តងទៅ។ តើលោកអាចបញ្ជាក់បានទេថា ក្រោយពីប្រជុំជាមួយ តាវ៉ាល់ ហើយ តាណាក បានមកប្រាប់លោក ហើយនិយាយជាមួយលោកអំពីខ្លឹមសារនៃការប្រជុំជាមួយមេដឹកនាំយោធា? អ៊ីចឹងខ្ញុំចង់ដឹងថា មាន តាណាក ហ្នឹងមែនទេ ជាអ្នកមកប្រាប់លោកអំពីខ្លឹមសារនៃកិច្ចប្រជុំ នៅពេលដែលគាត់ប្រជុំជាមួយ តាវ៉ាល់ នោះ?

**លោក ឡូត ស្វយ៖**

**ឆ៖** បាទ បានគាត់មកពីប្រជុំជាមួយ តាវ៉ាល់ រួចបានគាត់ហៅកូនកងទាំងអស់គ្នាមកប្រជុំប្រាប់។

**ស៖** នៅក្នុងឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា គឺនៅទំព័រដដែល ដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ លោកបានឆ្លើយថា តាណាក បានប្រាប់លោក គាត់បាននិយាយប្រាប់ភូមិភាគពាយ័ព្យថាឲ្យត្រៀមខ្លួន គឺដើម្បី -- គឺពួកគេត្រៀមខ្លួនដឹកអាវុធទៅក្នុងព្រៃ ដើម្បីបញ្ចុះបញ្ចូលអ្នកនិរតី។ ដូច្នេះសំណួររបស់ខ្ញុំ គឺនៅពេលដែលគេនិយាយថា យើងត្រៀមខ្លួនដឹកអាវុធចូលទៅក្នុងព្រៃនេះ លោកចង់និយាយអំពីអ្នកណា "យើង"ហ្នឹងចង់សំដៅទៅដល់កងទ័ពមួយណា?

**ឆ៖** ខ្ញុំនិយាយសំដៅទៅលើកងទ័ពតំបន់ដែលគេប្រមូលកម្លាំងមកនៅក្នុងព្រៃ កន្លែងអាងត្រពាំងថ្មនោះ ព្រៃឈ្យូកអាងនោះ។

[០៩:១២:០១]

**ស៖** លោកសាក្សី ខ្លួនលោកផ្ទាល់ តើលោកបានឃើញទាហានទាំងអសហ្នឹងនៅឈរជើងនៅជិតត្រពាំងថ្មហ្នឹងទេ ហើយលោកមានដឹងថា តើគេលាក់អាវុធហ្នឹងនៅកន្លែងណាទេ?

**ឆ៖** ព្រោះកន្លែងពួកគេឈរជើងនោះ ពួកខ្ញុំចូលអត់បានទេ ព្រោះសុទ្ធតែកងទ័ពគេនៅយាមច្រើន។

**ស៖** ហើយទាហានទាំងអស់ហ្នឹង គាត់ឈរជើងនៅកន្លែងណាឲ្យប្រាកដទៅ?

**ឆ៖** គេឈរជើងហ្នឹងព្រៃឈ្យូកអាងយើងហ្នឹងឯង ប៉ុន្តែឈរជើងនៅអត់បានយូរទេ រយៈពេលចំនួនប្រហែល១០ថ្ងៃ ក៏គេដកទៅវិញ ទៅនៅស្វាយវិញ។ ដឹកអាវុធគេចូលទៅកន្លែងស្វាយវិញទៅទៅកន្លែងគេវិញ។

**ស៖** ខ្ញុំចង់អានសម្រង់នៃសក្ខីកម្មរបស់សាក្សីមួយរូប ខ្ញុំមិនអាចប្រាប់លោកនូវឈ្មោះរបស់គាត់បានទេ គឺខ្ញុំសំដៅទៅលើឯកសារ E319/19.3.18 គឺសំណួរចម្លើយ៤៩ បន្ទាប់មកទៀតខ្ញុំនឹងសួរសំណួរទៅលោក។ សូមអភ័យទោស ខ្ញុំអត់មានការបកប្រែជាភាសាបារាំងទេ ខ្ញុំត្រូវលើកឡើងជាភាសាអង់គ្លេស។ លោកនិយាយអំពីការរៀបចំផែនការមួយយ៉ាងលម្អិត ដែលក្នុងនោះលោកបាននិយាយថា តាហេង មានផែនការយកសមាជិកទាំងអស់ដែលធ្វើការនៅកងចល័តឲ្យធ្វើជាទាហាន រួចយោធាដើម្បីវាយប្រឆាំងនឹងខ្មែរក្រហម។ តើលោកអាចពន្យល់ប្រាប់អំពីព្រឹត្តិការណ៍នេះបានទេ? ហើយចម្លើយ

ដូចតទៅនេះ ខ្ញុំសូមអានជាភាសាអង់គ្លេស៖ "កាលនោះគេបានត្រៀមរៀបចំឧបករណ៍សម្ភារៈនៅឃ្លាំងក្នុងការដ្ឋានត្រពាំងថ្ម ហើយមានការប្រជុំមួយនៅពេលយប់ នៅម៉ោងដប់មួយ -- ដប់ពីរ ឬម៉ោងមួយយប់ ហើយ តាហ៊ីង្ស បានប្រកាសប្រាប់ពួកកងចល័តថា អ្នកទាំងអស់គ្នានឹងក្លាយទៅជាស័ក្តិបីនាពេលខាងមុខ។ ខ្ញុំគិតថាគាត់និយាយអំពីការរៀបចំពួកយើងឲ្យទៅជាកងទ័ព ដើម្បីប្រឆាំងនឹងពួកខ្មែរក្រហម។" បញ្ចប់ការដកស្រង់។ សំណួរទី១របស់ខ្ញុំ ខ្ញុំចង់ដឹងថា តើលោកបានឃើញ ឬក៏ស្ដាប់ឮគេនិយាយអំពីឃ្លាំងដែលគេដាក់សម្ភារៈនៅការដ្ឋានត្រពាំងថ្មទេ?

[០៩:១៥:១០]

**ឆ៖** បាទ ទីកដីត្រពាំងថ្មនោះគឺអត់បានធ្វើឃ្លាំងកាំភ្លើងអីទេ គ្រាន់តែពួកកងតំបន់គេដឹកអាវុធគេមក គេត្រៀមចាំ។ គេត្រៀមកម្លាំងទុកនៅក្នុងព្រៃគឺអាវុធទាំងអស់នោះ គឺអត់បានដឹកកប់ទេ។

**ស៖** លោកសាក្សីលោកបាននិយាយត្រឹមត្រូវហើយ ក៏ប៉ុន្តែខ្ញុំចង់ដឹងថា លោកមិនមែនជាទាហានដែលមានឋានន្តរសក្តិខ្ពស់ទេ។ អ៊ីចឹង ប្រហែលជាមានរឿងមួយចំនួនដែលលោកមិនអាចដឹងបានទេ។ ម៉េចក៏លោកអះអាងប្រាកដបែបនេះ?

**ឆ៖** ពីព្រោះខ្ញុំឃើញវាដកទៅ គឺវាទៅអស់រលីង បានខ្ញុំថាមិនមានអាវុធលាក់ទុក ពីព្រោះកន្លែងដែលវានៅហ្នឹងគឺប្រជាជនចល័តយើងដែលអាចដើរចេញដើរចូលនៅកន្លែងនោះបាន។

**ស៖** ហើយអាវុធទាំងអស់ហ្នឹងជាអាវុធប្រភេទណាដែរ ពីព្រោះថាលោកៗបានឃើញហើយ អ៊ីចឹង ខ្ញុំចង់ដឹងថាប្រភេទណាដែរពេលនុ៎ង?

**ឆ៖** ខ្ញុំឃើញតែអាវុធប្រភេទអាកាដែលវាស្ពាយ ហើយនិងអាប៉ែត។

**ស៖** តើលោកអាចវាយតម្លៃបានទេថា តើអាវុធទាំងអស់ហ្នឹងមានចំនួនប៉ុន្មានដែរ?

**ឆ៖** ពេលនោះខ្ញុំអត់បានពិចារណាថា គេមានប៉ុន្មានទេ បើគ្រាន់តែមើលទៅឃើញ។ ខ្ញុំក៏អត់បានចាប់អារម្មណ៍។

**ស៖** ខ្ញុំចង់អានទូវសម្រង់នូវសក្ខីកម្មរបស់សាក្សីមួយរូបផ្សេងទៀត។ គាត់មិនត្រូវបានកោះហៅមកផ្ដល់សក្ខីកម្មទេ គឺឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ E3/9076, ERN ជាភាសាបារាំងគឺ 00731172, ជាភាសាខ្មែរ 00728870 ហើយបន្តទៅដល់ 71, សាក្សីនោះគឺឈ្មោះ មុន មុត។ គាត់និយាយអំពីជំនួបជាមួយ តាវ៉ាល់។ នេះជាចម្លើយរបស់គាត់ ខ្ញុំសុំដកស្រង់ជាភាសាអង់គ្លេស៖ "គាត់បានយកមកពីភូមិភាគបូព៌ាពីកងចល័ត ស្បែកជើងស្អាតៗត្រូវបានផ្ដល់មកឲ្យយើង។ ពេលហ្នឹងគឺថា

វាមានផែនការ ខ្ញុំភ័យខ្លាចចំពោះផែនការនេះណាស់។ សំណួរ៖ តើផែនការអ្វី? ផែនការយ៉ាងម៉េច? ដល់ពេល តាវ៉ាល់ និយាយការធ្វើការ គាត់និយាយផង បើកកន្សែង បើកដែកកេះ បើកអាវយឺតសក្ខាន ឱ្យពួកមេៗ ហើយគាត់បាននិយាយថា ពួកមិត្តឯងនេះ សុទ្ធតែស័ក្តិ៣។ គាត់និយាយនោះ ពួកមិត្តឯង សុទ្ធតែស័ក្តិ៣ ស័ក្តិ៥ គាត់ចង្អុល ក្នុងកំប្លែងជាមួយពេលប្រជុំស្រួច។ គាត់ប្រដូចយ៉ាងដូច្នេះជាមួយនឹង កងជ្រើសរើសឱ្យទៅធ្វើនៅកងចល័ត វាក្លាយទៅជាទ័ពស្អីក៏មិនដឹង។ ផែនការមានផែនការត្រូវនៅ ភ្នំកូនខ្លែងនោះឯង ហើយផែនការដែលរើបម្រាសមិនរួច។ ខ្ញុំមិនដឹងដល់មានផែនការហើយទេ។ អត់ មានការប្រជុំរ៉ៃចោលទេ រឿងប្រជុំគឺមានគម្រោងបំពាក់សម្ភារៈ គឺថាផែនការនេះគឺច្បាស់ហើយ ដូច្នេះ យើងមិនអាចនិយាយអំពីផែនការនេះឱ្យគេដឹងបានទេ។" សំណួរទី១ របស់ខ្ញុំពាក់ព័ន្ធនឹងចំណុចនេះ ខ្ញុំ ចង់ដឹងថា តើលោកបានឮ ឬក៏ឃើញថាមានការចែកស្បែកជើងមកពីភូមិភាគបូព៌ាដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន ខ្ញុំមិនជំទាស់ទៅនឹងការតាំងសំណួរនេះទេ គ្រាន់តែសួរបញ្ជាក់ឱ្យបានច្បាស់ សម្រាប់ប្រតិចារឹក។ សម្រង់ដែលទើបអានអម្បាញ់មិញនេះគឺថា គឺសាក្សីតែមួយទេនូវអ្វីដែលមេធាវី ការពារក្តីទើបតែបានអានអម្បាញ់មិញនេះ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី សូមយកចិត្តទុកដាក់អំពីពេលវេលាដែលសាលាដំបូងបានចែកឱ្យ អង្គជំនុំ ជម្រះបានប្រើពេលប្រហែលជា ២០នាទីប៉ុណ្ណោះ។ ហេតុដូច្នេះ លោកមេធាវីមានពេលតែ ២០នាទី ប៉ុណ្ណោះនាព្រឹកនេះ។ សូមអញ្ជើញលោកស្រី!

[០៩:២១:៤៣]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំនឹងប្រញាប់បញ្ចប់ ដើម្បីផ្តល់វេទិកាជូនសហភាតារបស់ខ្ញុំ។ ខ្ញុំនឹងព្យាយាមគោរពតាម ការណែនាំគឺពាក់ព័ន្ធនឹងការរក្សាការសម្ងាត់។ ដូច្នេះ សំណួរខ្ញុំៗចង់ដឹងថា លោកសាក្សី តើលោកដឹង អំពីការចែកទ្រនាប់ជើងមកពីភូមិភាគបូព៌ាដែរឬទេ នៅពេលណាមួយនោះ?

**លោក ឡូត ស្វយ៖**

**ឆ៖** បាទ ខ្ញុំអត់ដឹងថាគេចែកនៅពេលណាទេ ប៉ុន្តែខ្ញុំឃើញពួកចល័តគេពាក់ស្បែកជើងនោះ។

**ស៖** ចុះលោកដឹងអំពីកិច្ចប្រជុំមួយរវាង តាវ៉ាល់ និងកងចល័តដែលនៅក្នុងពេលនុំង តាវ៉ាល់ ហ្នឹងគាត់បាននិយាយថា ពួកគេទាំងអស់ហ្នឹង នឹងក្លាយទៅជាស័ក្តិ៣ នាពេលបន្តិចទៀតនេះហើយ។ លោកមានដឹងរឿងហ្នឹងទេ?

**ឆ៖** បាទ ការងារហ្នឹងគេអត់ដែលឲ្យអ្នកណាដឹងទេ បើគេប្រជុំពួកខ្ញុំ គឺប្រជុំតែពួកខ្ញុំ អ្នកក្រៅក៏គេមិនដឹង ព្រោះគេធ្វើការគេលាក់ការណ៍។ ពួកខ្ញុំនេះអត់ដែលដឹងរឿងរ៉ាវអីទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

ដោយសារពេលវេលាខ្លី ខ្ញុំសូមបញ្ចប់ការសំណួរត្រឹមនេះ ហើយសូមផ្តល់វេទិកានេះជូនមេធាវី គង់ សំអុន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន សូមគោរពអង្គជំនុំជម្រះ។

[០៩:២៣:៤២]

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក ឡូត ស្វយ! ខ្ញុំមានសំណួរតិចតួចទេ ដើម្បីសួរបញ្ចប់ពេលនេះ។ ជាដំបូង ខ្ញុំចង់សួរបញ្ជាក់លោកទាក់ទងទៅនឹងអាយុរបស់លោក។ ពីម្សិលម៉្ងៃនៅពេលដែលប្រធានអង្គជំនុំជម្រះបានសួរលោកៗ ថាលោកមានអាយុ៥៥ឆ្នាំ ហើយលោកអត់បានដឹងថាលោកកើតនៅឆ្នាំណាទេ។ ហើយខ្ញុំបានពិនិត្យមើលឯកសារកិច្ចសម្ភាសន៍របស់លោកជាមួយនឹងមជ្ឈមណ្ឌលកម្ពុជា លោកឆ្លើយតាំងពីឆ្នាំ២០១១។ ហើយលោកបានឆ្លើយថា លោកអាយុ៥៥ឆ្នាំ។ អ៊ីចឹងបានន័យថា តាំងពីឆ្នាំ២០១១ រហូតមកដល់ឥឡូវនេះវា បួនឆ្នាំជាងជិតប្រាំឆ្នាំ ចូលឆ្នាំទីប្រាំហើយ លោកនៅតែអាយុ៥៥ឆ្នាំដដែល។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើអាយុពិតប្រាកដរបស់លោក ៗអាចចាំបានទេថា នៅពេលដែលលោកឆ្លើយជាមួយមជ្ឈមណ្ឌលកម្ពុជាថា លោកអាយុ៥៥ឆ្នាំនោះត្រឹមត្រូវ ឬក៏នៅក្នុងអង្គជំនុំជម្រះនេះលោកឆ្លើយថា លោកអាយុ៥៥ឆ្នាំត្រឹមត្រូវ?

**លោក ឡូត ស្វយ៖**

**ឆ៖** ពេលដែលខ្ញុំឆ្លើយថា អាយុ គឺខ្ញុំ រយៈកាលកន្លងមក ដែលដល់សព្វថ្ងៃនេះ គឺខ្ញុំអត់បានរាប់អាយុខ្ញុំ ហើយខ្ញុំចេះតែឆ្លើយថា អាយុ៥៥។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងបានន័យថា លោកឆ្លើយ ៥៥ហ្នឹង គឺបន្ទាប់ពីលោកឆ្លើយជាមួយមជ្ឈមណ្ឌលកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជា ថាលោកមានអាយុ៥៥។ អ៊ីចឹងលោកនៅរក្សាអាយុហ្នឹងនៅដដែល រហូតមកដល់ឥឡូវហ្នឹង ក៏លោកឆ្លើយថា អាយុ៥៥ដែរ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំក៏មិនបានរាប់អាយុខ្ញុំដែរ ខ្ញុំដឹងតែអាយុ៥៥ ដល់សព្វថ្ងៃនេះ មិនបានរាប់ទេ មិនដឹងប៉ុន្មានទៀត។ បានដល់គេសួរ ខ្ញុំឆ្លើយថា អាយុ៥៥។

[០៩:២៦:០០]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងសិនជាខ្ញុំគិតជាលេខទៅ បើនៅដើមឆ្នាំមួយពាន់-- សូមទោសឆ្នាំ២០១១ នៅខែ៥ នៅពេលដែលលោកឆ្លើយជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា លោកមានអាយុ៥៥។ អ៊ីចឹងយ៉ាងតិចបំផុតក៏លោក កើតនៅក្នុងឆ្នាំ១៩៥៦ដែរ ហើយបើសិនជាប្រៀបធៀបនឹងអាយុកាលពីឆ្នាំ៧៥ លោកមានអាយុយ៉ាងតិចក៏១៩ឆ្នាំដែរ។ តើខ្ញុំនិយាយអ៊ីចឹង ត្រឹមត្រូវទេ?

**ឆ៖** ពេលដែលឆ្នាំ៧៥ គឺខ្ញុំ ម្តាយខ្ញុំថា ខ្ញុំអាយុ១៥ឆ្នាំ។ ព្រោះពេលនោះ ខ្ញុំមិនទាន់ចេះស្លៀកខោជើងវែងទេ ស្លៀកតែខោខ្លី។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់អំពីកាលៈទេសៈពីរដែលអាចឱ្យលោកច្រឡំ គឺកាលៈទេសៈទី១ គឺក្នុងឆ្នាំ៧០ ដែលឆ្នាំ១៩៧០ នៅពេលដែលមានរដ្ឋប្រហារ និងកាលៈទេសៈទី២ គឺនៅពេលឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមទទួលជ័យជម្នះ។ លោកអាចច្រឡំបានទេ នៅពេលណាដែលម្តាយរបស់លោកប្រាប់លោកថា លោកមានអាយុ១៥ឆ្នាំ?

**ចៅក្រម យ៉ា សុខន៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោកមេធាវីបានប្រើសំណួរនាំមុខដែលថា ម្តាយប្រាប់គាត់នៅឆ្នាំ១៩៧០ ហើយខ្ញុំមិនប្រាកដថាមេធាវីមិនបានយោងទៅរកកាលបរិច្ឆេទជាក់លាក់របស់សាក្សីនៅកំណត់ហេតុស្តាប់ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតទេ ប៉ុន្តែសំណួរនេះគឺជាសំណួរដែលនាំមុខដែលមេធាវីបានសួរអម្បាញ់មិញនេះ។

**លោក គង់ សំអុន៖**

បាទ លោកប្រធាន ខ្ញុំអត់បានសួរសំណួរនាំមុខទេ។ សំណួរអម្បាញ់មិញនេះ គឺខ្ញុំផ្ដល់កាលៈទេសៈពីរ។ ទី១ គឺតាមសក្ខីកម្មរបស់សាក្សីដែលបញ្ជាក់អំពីឆ្នាំ៧៥ ហើយខ្ញុំបង្ហាញអំពីកាលៈទេសៈដែលអាចមានការភាន់ច្រឡំ ថាតើកាលៈទេសៈណាពិតប្រាកដដែលលោកអាចចាំថានៅពេលដែលម្ដាយរបស់គាត់បានប្រាប់នោះ។ សូមអនុញ្ញាត!

[០៩:២៨:៥៦]

**ចៅក្រម យ៉ា សុខន៖**

សូមសាក្សីឆ្លើយតបសំណួររបស់លោកមេធាវី!

**លោក ឡុត សួយ៖**

**ឆ៖** ពេលដែលខ្ញុំ ម្ដាយខ្ញុំប្រាប់អាយុ១៥ឆ្នាំនេះ គឺគេរើសកងចល័តពីភូមិទៅនៅព្រៃមាន់ បានម្ដាយខ្ញុំប្រាប់ថា កូនខ្ញុំអាយុ១៥ឆ្នាំទេ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីឆ្នាំកំណើតជាសត្វតាមរបៀបខ្មែរបានទេ លោកកើតឆ្នាំណាដែរ?

**ឆ៖** ពេលនោះ ខ្ញុំអត់ដឹង ថាដឹងកើតឆ្នាំណាទេ ព្រោះម៉ែឪខ្ញុំអត់បានប្រាប់។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងឯកសារដែលជាកិច្ចសម្ភាសន៍របស់លោកជាមួយសហចៅក្រម ការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង ដូចសហព្រះរាជអាជ្ញាបានលើកអម្បាញ់មិញនេះ គឺលោកមានឆ្នាំកំណើត ឆ្នាំ១៩៥៨។ ហើយបើសិនជាគិតនៅឆ្នាំ១៩៥៨ នេះ ជាឆ្នាំកំណើតរបស់លោក ក៏មិនមែនអាយុ១៥ឆ្នាំ គឺនៅក្នុងឆ្នាំ១៩៧៥។ អ៊ីចឹងខ្ញុំចង់សួរថា តើលោកបានកំណត់ឆ្នាំ១៩៥៨ ជាឆ្នាំកំណើតរបស់លោកហ្នឹងពីណាមក?

[០៩:៣០:៥០]

**ឆ៖** ឆ្នាំកំណើតនេះ ខ្ញុំ ម្ដាយខ្ញុំប្រាប់ ខ្ញុំហ្នឹងឆ្នាំ១ ច ខែជេស្ឋ ថ្ងៃចន្ទ ប៉ុនមិនដឹងកើតនៅ--

**ស៖** បាទ សូមអរគុណ ខ្ញុំសូមចូលប្រធានបទថ្មី។ ពីម្សិលមិញ ខាងសហ -- ខាងមេធាវី ខាងសហមេធាវីរបស់លោក នួន ជា បានសួរលោកអំពីលុយរបស់កម្ពុជាប្រជាធិបតេយ្យ ដែលលោកបានទទួលរួចហើយ ហើយនៅក្នុងឯកសារ E3/9060 ជាឯកសារសម្ភាសរបស់លោកជាមួយមជ្ឈមណ្ឌល

ឯកសារកម្ពុជា ត្រង់ ERN ជាភាសាខ្មែរ 00733052 ដល់ 53, ភាសាបារាំង 01123698 ដល់ 99 ជាភាសាអង់គ្លេស 00728747។ ខ្ញុំសូមដកស្រង់ដោយអានជូនចំណុចខ្លីៗទេ សួរ "ដារ៉ាសួរថា៖ ឃើញប៉ុន្មានសន្លឹក? សួយ៖ គេយកមកបីសន្លឹក។ ដារ៉ា៖ បីសន្លឹកក្រដាស ១០រៀលទាំងបី ឬមួយយ៉ាងម៉េច? សួយ៖ ក្រដាស១០មួយ ក្រដាស២០មួយ -- អ៎! ក្រដាស២០ពីរសន្លឹក។ គ្រាន់គេប្រាប់ថា ពលទោយើងបាន២០។ អ៊ីចឹងពួត្រូវបានប៉ុន្មាន នៅពេលគេជដែកគ្នាហ្នឹង? ខ្ញុំបាន២០បាទ។ ដារ៉ា៖ ២០រៀល? សួយ៖ បាទ។" សូមបិទការដក់ស្រង់។ ខ្ញុំចង់សួរបញ្ជាក់លោកថា លោកនៅគាំទ្រសក្ខីកម្មរបស់លោកនេះទេថាលោកដែលបានឃើញក្រដាសប្រាក់នៅពេលនោះគឺបីសន្លឹក ដែលមានក្រដាស១០មួយសន្លឹក និងក្រដាស២០ ពីរសន្លឹក?

**ឆ៖** ពេលដែលគេបង្ហាញក្រដាសប្រាក់នោះ គឺគេបង្ហាញ គេថាពលទោដូចពួកយើងបានម្នាក់ ២០រៀល។ កាលនុំងគេអត់បានចែកប្រាក់ទេ គឺគ្រាន់តែគេប្រាប់ថា បានម្នាក់២០រៀល។

[០៩:៣៣:៥៨]

**ស៖** បាទខ្ញុំទទួលស្គាល់ ខ្ញុំស្ដាប់បានហើយ ប៉ុន្តែសំណួររបស់ខ្ញុំៗចង់សួរថា តើលោកបានឃើញក្រដាសបីសន្លឹក ក្រដាសប្រាក់បីសន្លឹក ដែលមានក្រដាស១០មួយសន្លឹក និងក្រដាស២០មួយសន្លឹកនោះដែរទេ?

**ឆ៖** បាទ បើគេបានមក គេព្រោះៗគ្នាខ្ញុំគេយកមកបង្ហាញ "គេថានេះក្រដាសប្រាក់ចេញ គេបើកឲ្យពួកយើងម្នាក់ៗ២០រៀល" ប៉ុន្តែខ្ញុំក៏គ្រាន់តែចាប់មើល គ្នាខ្ញុំគេដណ្ដើមពីដៃខ្ញុំទៅមើលម្នាក់ម្ដងៗ។

**ស៖** បាទ អ៊ីចឹងបានន័យថា លោកបានឃើញក្រដាស ២០រៀលនោះ។ តើអ៊ីចឹងមែនទេ? សូមលោកឆ្លើយមក ព្រោះអត់ទាន់ចូលឮសំឡេង--

**ឆ៖** ព្រោះក្រដាស២០រៀលនោះ ខ្ញុំអត់បានចាប់មើលទេ គ្រាន់តែគ្នាខ្ញុំគេកាន់។ ខ្ញុំកាន់ក្រដាស ១០ ខ្ញុំក៏ស្ទាបមើលក្រដាសប្រាក់គេនោះ ប៉ុនខ្ញុំថា ក្រដាសប្រាក់ ក្រដាស១០នោះសម្បុរវាក្រហម ហើយមានមនុស្សច្រូតស្រូវ។

**ស៖** បាទ សូមអរគុណ។ ដោយសារលោកបានរស់នៅក្នុងតំបន់ទំនប់ត្រពាំងថ្ម ក្នុងពេលចុងក្រោយ។ ខ្ញុំចង់សួរថា ពេលណាដែលលោកចេញពីទំនប់ត្រពាំងថ្ម? នៅពេលចុងក្រោយបំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺនៅដំណាក់កាលណាដែលលោកចាកចេញពីតំបន់ទំនប់ត្រពាំងថ្ម?

[០៩:៣៦:០៣]

**ឆ៖** ពេលដែលៗខ្ញុំចាកចេញពីទំនប់ត្រពាំងថ្មនោះ គឺពេលជិតចប់ សន្តិភាព គេក៏បានដកពួកខ្ញុំឲ្យទៅនៅតាមភូមិជាមួយក្រុមគ្រួសារវិញ។ គេដកទាំងអស់--

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរលោកថា តើលោកបានជួបប្រទះទឹកជំនន់ទេ នៅពេលក្នុងឆ្នាំ១៩៧៨នោះ?

**ឆ៖** ខ្ញុំស្តាប់មិនបានផង។

**ស៖** ខ្ញុំចង់សួរលោកថា លោកបានចាំថា មានគ្រោះទឹកជំនន់ទេ នៅតំបន់របស់លោក នៅតំបន់ត្រពាំងថ្មនោះ ក្នុងឆ្នាំ១៩៧៨?

**ឆ៖** ពេលនោះ នៅតំបន់ត្រពាំងថ្មនោះ គឺអត់មានទឹកជំនន់អីធំទេ ពីព្រោះទឹកធ្លាក់មកពីលើវាជាប់តែនឹងអាង ពីព្រោះពេលនោះ ខ្ញុំមកដល់ភូមិកំណើត មកដល់ភូមិរបស់ខ្ញុំវិញហើយ។

**ស៖** ក្នុងៗ -- ក្នុងពេលរដូវវស្សា លោកនៅទីណាដែរ នៅឆ្នាំ១៩៧៨?

**ឆ៖** ឆ្នាំ៧៨ ខ្ញុំនៅក្នុងភូមិពោធិ៍វាំបុណ្យ។

**ស៖** បញ្ជាក់ឃុំ ស្រុក ផង?

**ឆ៖** ខ្ញុំនៅក្នុងភូមិពោធិ៍វាំបុណ្យ ឃុំពន្លៃ ស្រុកភ្នំស្រុក ជាស្រុក ជាភូមិរបស់ក្រុមគ្រួសារខ្ញុំ។

**ស៖** ស្ថានភាពដីនៅខាងនុ៎ង យ៉ាងម៉េចដែរ? វាខ្ពស់ ឬជាប្រភេទដីទំនាបលិចទឹក?

**ឆ៖** ពីព្រោះស្ថានភាពទឹកដីខាងនុ៎ង គឺទឹកដី គឺដីវាខ្ពស់ សម្បូរទៅដោយព្រៃឈើ គេហៅតំបន់ស្រុកព្រៃ។

[០៩:៣៨:៤១]

**លោក គង់ សំអុន៖**

បាទ សូមអរគុណ លោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។ សូមអញ្ជើញ លោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ដើម្បីឲ្យមានកំណត់ត្រានៅក្នុងតុលាការ មេធាវីការពារ គឺៗថាដប់ប្រាំបួន ហាសិបប្រាំបីនោះ គឺឆ្នាំច កាលបរិច្ឆេទនៅបទសម្ភាសន៍ អូ.ស៊ី.អាយ.ជេ នោះ គឺថាគឺស្រង់ចេញពីឯកសារអត្តសញ្ញាណប័ណ្ណផ្លូវការ គឺថ្ងៃខែឆ្នាំកំណើត គឺៗគាត់កើតនៅថ្ងៃទី១០ ខែមិថុនា

ឆ្នាំ១៩៥៨។ អ៊ីចឹងនៅឆ្នាំ១៩៧៥ គាត់អាយុ១៧ឆ្នាំ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកសហព្រះរាជអាជ្ញា។

សវនាការស្ដាប់សក្ខីកម្មសាក្សី ឡូត សួយ ដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះអរគុណលោក ឡូត សួយ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេលបីថ្ងៃមកនេះ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ សូមលោកមានសំណាងល្អ សូមឱ្យមានសេចក្ដីសុខចម្រើន និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

អង្គជំនុំជម្រះសូមអរគុណ លោកមេធាវីប្រឹក្សាសាក្សីផងដែរ ដែលបានជួយដល់សាក្សីក្នុងអំឡុងពេលសវនាការរយៈពេលកន្លងមកនេះ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅវិញ។

*(សាក្សីចេញពីបន្ទប់សវនាការ)*

សូមអញ្ជើញលោកមេធាវី កូប៉េ!

[០៩:៤១:១៥]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកចៅក្រម ខ្ញុំក៏សូមឆ្លៀតឱកាសដើម្បីនឹងធ្វើសំណើពីរខ្លី។ សំណើទី១ ជូនអង្គជំនុំជម្រះ ហើយសូមឱ្យអង្គជំនុំជម្រះឱ្យច្បាប់ចម្លងនៃ ចម្លងជាពណ៌ធម្មជាតិដាក់ចូលនៅក្នុងសំណុំរឿងនៅក្រដាសប្រាក់ដែលខ្ញុំបានដាក់ -- ដែលបានម្សិលមិញ ហើយនិងខ្ញុំធ្វើសំណើផ្ទាល់មាត់តាមវិធាន៨៧ សូមឱ្យដាក់បញ្ចូលច្បាប់ចម្លងក្រដាស់ប្រាក់ជាពណ៌ហ្នឹងចូលទៅក្នុងសំណុំរឿង ហើយសំណើទី២ ខ្ញុំឮតំណាងសហព្រះរាជអាជ្ញាអន្តរជាតិនិយាយពីម្សិលមិញ គាត់បានដាក់បញ្ចូលឯកសារដែលនិយាយអំពី តាវ៉ាល់ ត្រូវបានបញ្ជូនទៅស-២១ ហើយបានឃើញចម្លើយសារ-ភាពរបស់គាត់ ហើយខ្ញុំមិនបានរកឯកសារទាំងពីរនោះ ដែលសហព្រះរាជអាជ្ញាបានយោងទេ ប្រហែលជាមិនត្រូវបានដាក់ចូលក្នុងសំណុំរឿងទេ។ អ៊ីចឹងខ្ញុំធ្វើសំណើនៅពេលនេះឱ្យសហព្រះរាជអាជ្ញាប្រាប់យើងខ្ញុំ ឬក៏ថាផ្ដល់ព័ត៌មានថ្មី តើយើងអាចនឹងបាន អាចបានឯកសារចម្លើយសារភាពរបស់ តាវ៉ាល់

ហើយនិងឯកសារមួយទៀតដែលនិយាយអំពីការចាប់ខ្លួន ហើយនិងការឃុំរបស់គាត់នៅស-២១ផងដែរ។

[០៩:៤៣:០១]

**លោក ឌេល លីសាក់៖**

បាទ យើងកំពុងរង់ចាំរហូតទាល់តែបានឯកសារទាំងបី មុនពេលដែលយើងដាក់ចូលក្នុងសំណុំរឿង ហើយមុនយើងបានជូនទៅដល់ភាគីទាំងអស់ ហើយខ្ញុំនឹងផ្តល់ទៅភាគីជាក្រៅផ្លូវការ ហើយយើងនឹងផ្តល់ទៅអង្គជំនុំជម្រះ ប៉ុន្តែយើងកំពុងតែព្យាយាមតាមដានបញ្ជីស-២១ ជាភាសាខ្មែរ ដែលជាឯកសារ E3/1900 ប៉ុន្តែយើងនឹងមានឯកសារទាំងអស់ហ្នឹងចែកទៅភាគីជាក្រៅផ្លូវការ នៅពេលដែលយើងបានឯកសារចុងក្រោយ យើងនឹងអាចដាក់ជូនតុលាការជាឯកសារផ្លូវការចុងក្រោយបាទ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកព្រះរាជអាជ្ញា។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 2-TCW-937 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:៤៦:៥១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរស្តីលោកសាក្សី! តើលោកឈ្មោះអី?

**លោក ឈិត យឿក៖**

**ឆ៖** ខ្ញុំឈ្មោះ ឈិត យឿក។

**ស៖** លោកកើតនៅថ្ងៃខែឆ្នាំណាដែរ?

**ឆ៖** ថ្ងៃទី០១ ខែឧសភា ១៩៤៦។

**ស៖** លោកប្រកបមុខរបរអ្វីដែរសព្វថ្ងៃ?

**ឆ៖** ខ្ញុំធ្វើស្រែ ហើយនិងស៊ីឈ្នួលយាមផ្ទះឲ្យគេដែរ។

**ស៖** ឪពុកបង្កើតម្តាយបង្កើតរបស់លោកឈ្មោះអីដែរ?

**ឆ៖** ឈ្មោះ ជាម ឪពុក។

**សៈ** ចុះម្តាយលោកឈ្មោះអី?

**ឆៈ** លូ តាំងវើ។

**សៈ** ប្រពន្ធរបស់លោកឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆៈ** ប្រពន្ធខ្ញុំឈ្មោះ វង់ រី មានកូនបីនាក់។

**សៈ** អរគុណលោក ឈិត យឿក។ តាមរបាយការណ៍របស់ក្រឡាបញ្ជីកាលពីព្រឹកមិញបានបញ្ជាក់ថា តាមសមត្ថភាព និងលទ្ធភាពដែលលោកអាចដឹង លោកមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន និងបុគ្គលដែលត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០២នេះទេ។ តើមែនទេ?

**ឆៈ** បាទ។

[០៩:៤៩:១០]

**សៈ** ហើយថា លោកបានធ្វើសម្បថរួចហើយ នៅចំពោះមុខលោកតាដំបងដែកមុននឹងចូលមកនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ។ តើពិតជាអ៊ីចឹងទេ?

**ឆៈ** បាទ។

**សៈ** អរគុណលោក ឈិត យឿក។ ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោកក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោក ឈិត យឿក ក្នុងឋានៈលោកជាសាក្សី នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ នៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបនឹងសំណួរ ឬការដែលឲ្យលោកធ្វើអត្ថាធិប្បាយមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សី លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោក នាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯងដូចយើងប្រាប់អំពីសិទ្ធិរបស់លោករួចហើយអម្បាញ់មិញនេះ។

ក្នុងឋានៈលោកជាសាក្សី លោកត្រូវតែឆ្លើយ ឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគីសួរចំពោះលោក។

**សៈ** តើលោកយល់ទេ លោក ឈិត យឿក?

**ឆ៖** បាទ ឮហើយ។

[០៩:៥១:១១]

**ស៖** លោក ឈិត យឿក តើលោកដែលផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងពេលកន្លងមក? ហើយប្រសិនបើបានធ្វើតើធ្វើប៉ុន្មានដង? ធ្វើនៅពេលណា? ធ្វើនៅកន្លែងណា?

**ឆ៖** បានធ្វើពីរដង ម្តងនៅនឹងផ្ទះ ម្តងទៀតនៅនឹងកន្លែងអង្គការនៅប៉ោយប៉ែត។

**ស៖** អរគុណលោក។ ហើយនៅមុនពេលចូលចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្តល់ចម្លើយកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ បានអានខ្លះៗ ដែរបាទ។

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹងបាន តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្តាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំហ្នឹងវាពិតជាត្រឹមត្រូវ វាស៊ីចង្វាក់គ្នា ស្របទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុនដែរឬទេ?

**ឆ៖** បាទ។

**ប្រធានអង្គជំនុំ៖**

ក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបញ្ញត្តិ៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិការជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី ឈិត យឿក នេះមុនភាគីដទៃទៀតនៃរឿងក្តី។ សូមបញ្ជាក់ថា ភាគីសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីមានពេលបីវគ្គនៃថ្ងៃសវនាការ ក្នុងការសួរដេញដោលសាក្សីរូបនេះ។

សូមអញ្ជើញលោកសហព្រះរាជាអាជ្ញា!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរលោកចៅក្រម ហើយនិងភាគីទាំងអស់ ហើយសូមជម្រាបសួរសាក្សីផងដែរ។

[០៩:៥៣:៤៨]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ខ្ញុំមានសំណួរមួយចំនួនទៅលោក។ តើកម្រិតវប្បធម៌ ការសិក្សារបស់លោកដល់ថ្នាក់ណាដែរ?

**លោក ឈិត យឿក៖**

**ឆ៖** ខ្ញុំរៀនដល់ទី៧ ពីសង្គម។

**ស៖** សូមអរគុណ។ នេះមានន័យថា ប្រហែលជាលោកបានសិក្សានៅសាលាប្រាំមួយឆ្នាំ តើអ៊ីចឹងឬទេ?

**ឆ៖** បាទ ដែលថាប្រាំមួយឆ្នាំនោះ ព្រោះនៅវត្តនៅអីផងបាទ។

**ស៖** លោកសាក្សី តើលោកធ្លាប់ធ្វើជាគ្រូបង្រៀនដែរឬទេ?

**ឆ៖** រយៈក្រោយមក ខ្ញុំ ដែលស្រុកចប់មកឥឡូវនេះ ខ្ញុំធ្វើនៅជំរំ ហើយពីមុនធ្វើដែរ ប៉ុន្តែធ្វើនៅសង្ឃបាទ។

**ស៖** សូមអរគុណ។ តើលោកបានបួសជាព្រះសង្ឃអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** បួសបានបីឆ្នាំ។

**ស៖** តើលោកចាំដែរឬទេ ក្នុងបីឆ្នាំនោះ ឆ្នាំណាខ្លះ តាមដែលលោកចាំ?

**ឆ៖** បីឆ្នាំនោះ ពី១៩៧៥ ដល់៧៩ បាទ។ ៧៨ បាទ។

**ស៖** លោកសាក្សី លោកនិយាយថាលោកជាព្រះសង្ឃពីឆ្នាំ១៩៧៥ ដល់១៩៧៨ នោះជាសម័យកាលឆ្នាំនៃរបបខ្មែរក្រហម។ តើហ្នឹងពិតជារយៈពេលដែលលោកជាព្រះសង្ឃ ឬក៏យ៉ាងម៉េច?

[០៩:៥៦:២៤]

**ឆ៖** អ៊ូ! អារឿងដែលព្រះសង្ឃនោះ ខ្ញុំបួសតាំងពីសម័យលន់ នល់ទេ ប៉ុន្តែសម័យបីឆ្នាំនោះ គឺមិនមានបួសទេ។ បាទ ខ្ញុំស្តាប់អត់បានអំមិញ។

**ស៖** មិនមានបញ្ហាទេ គឺយើងតែងតែច្រឡំពីកាលបរិច្ឆេទ។ នៅពេលដែលលោកជាព្រះសង្ឃ តើនៅក្នុងទសវត្សរ៍ឆ្នាំណា? ទសវត្សរ៍ឆ្នាំ៦០ ឬទសវត្សរ៍ឆ្នាំ៧០?

**ឆ៖** ទសវត្សរ៍ឆ្នាំ៦០ បាទ។

**ស៖** តើឥឡូវនេះ លោកនៅតែជាពុទ្ធសាសនិកជន លោកគោរពប្រតិបត្តិពុទ្ធសាសនាទេ?

**ឆ៖** បាទ គោរពព្រះពុទ្ធសាសនាយើង។

**ស៖** តើនៅក្នុងរបបប៉ុល ពត តើលោកអាចគោរពប្រតិបត្តិពុទ្ធសាសនាបានទេ សម័យនោះ?

**ឆ៖** ក្នុងសម័យនោះ គោរពមិនបានទេ បាទ។ សូម្បីតែលោក--

[០៩:៥៧:៥២]

**ចៅក្រម យ៉ា សុខន៖**

លោកមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន សូមគោរពលោកប្រធាន ខ្ញុំមិនមានចេតនាក្នុងការកាត់ផ្តាច់សួរ របស់លោកសហព្រះរាជអាជ្ញាទេ ក៏ប៉ុន្តែខ្ញុំស្តាប់ឮអម្បាញ់មិញ លោកសាក្សីបាននិយាយថា គាត់បួស នៅសម័យលន់ នល់ ហើយបន្ទាប់មក លោកឆ្លើយតបនឹងសំណួរមួយទៀតរបស់លោកសហព្រះរាជអាជ្ញាអន្តរជាតិថា តើនៅទសវត្សរ៍៦០ហ្នឹងមែនឬទេ? លោកសាក្សីបានឆ្លើយថា នៅទសវត្សរ៍៦០។ ដូច្នេះ ហាក់ដូចជាមិនមានការស៊ីគ្នាអំពីពេលវេលា មិនស៊ីចង្វាក់រវាងពេលវេលា។ ចង់ស្នើសុំជូនលោកសហព្រះរាជអាជ្ញាឲ្យសួរបញ្ជាក់អំពីបញ្ហានេះថែម។ សូមអរគុណលោកប្រធាន។

**ចៅក្រម យ៉ា សុខន៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញាមានសំណួរបន្ត!

**លោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណ។ លោកសាក្សី នៅក្នុងរបបខ្មែរក្រហមនោះ បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ រហូតមកដល់ខែមករា ឆ្នាំ១៩៧៩ តើលោកអាចគោរពប្រតិបត្តិព្រះពុទ្ធសាសនាបានដែរឬទេ?

**លោក ឈិត យឿក៖**

**ឆ៖** គោរពមិនបានទេ ជំនាន់នោះ ចាប់ពីនោះមក។

**ស៖** ហេតុអ្វីក៏គោរពមិនបាន លោកសាក្សី?

**ឆ៖** ព្រោះលោកសង្ឃទាំងអស់ គេត្រូវផ្សឹកចេញអស់។ ឈប់ឲ្យមាននៅក្នុងវត្តហើយ។

**ស៖** លោកសាក្សី តើត្រឹមត្រូវដែរឬទេ លោកកើតនៅព្រះនេត្រព្រះ?

**ឆ៖** បាទ ខ្ញុំកើតនៅស្រុកព្រះនេត្រព្រះ បាទ។

[១០:០០:០៣]

**ស៖** តើលោកបានរស់នៅទីនោះរហូតមកដល់ឆ្នាំ១៩៧០ ដែរឬទេ? តើនៅឆ្នាំ១៩៧០ លោកនៅតែរស់នៅស្រុកកំណើតលោកហ្នឹងដដែលទេ?

**ឆ៖** ឆ្នាំ១៩៧០ រស់នៅស្រុកកំណើត។

**ស៖** នៅពេលណាមួយដែលខ្មែរក្រហមចូលកាន់កាប់ស្រុកព្រះនេត្រព្រះនោះ?

**ឆ៖** នៅក្នុងស្រុកព្រះនេត្រព្រះតែនៅក្នុងភូមិខ្ញុំរស់នៅសង្កាត់ទឹកជោរ ប្រហែលជាឆ្នាំ៧៣ ខ្មែរក្រហមចេញចូលកាន់កាប់។

**ស៖** តើត្រូវដែរឬទេ ដែលថាខ្មែរក្រហមបានចូលកាន់កាប់នៅផ្នែកផ្សេងៗនៃស្រុក ប៉ុន្តែកន្លែងខ្លះគឺថានៅដើមឆ្នាំ៧៣ ហើយនៅកន្លែងខ្លះគឺខុសពីហ្នឹង។ ចំពោះកន្លែងលោក គឺខ្មែរក្រហមចូលកាន់កាប់នៅក្នុងឆ្នាំ១៩៧៣ អ៊ីចឹងអេ្វះ?

**ឆ៖** បាទ។

**ស៖** តើលោកបានចូលចលនាខ្មែរក្រហមនៅក្នុងឆ្នាំណា?

**ឆ៖** ចលនាខ្មែរក្រហម បើតាមការគិតទៅភូមិខ្ញុំចេញចូលតាំងពីឆ្នាំ៧០គត់ តែមិនទាន់បានកាន់កាប់បាទ។

**ស៖** សូមអរគុណចំពោះការពន្យល់នេះ។ តើលោកចូលរួមជាមួយចលនាបដិវត្តនោះ នៅក្នុងឆ្នាំណាដែរ?

**ឆ៖** បាទ បើគិតថាដែលទៅពីផ្ទះទៅ គឺឆ្នាំ៧៣។

[១០:០២:៤២]

**ស៖** សំណួរខ្ញុំសួរថា លោកចូលរួមជាមួយចលនាខ្មែរក្រហមនៅឆ្នាំណា? លោកចាប់ផ្តើមធ្វើការជាមួយខ្មែរក្រហមតាំងពី៧៣ ឬក៏នៅពេលណា?

**ឆ៖** បាទ នៅ៧៣។

**ស៖** តើលោកមានមុខងារជាអ្វីដែរជាមួយនឹងខ្មែរក្រហមមុនជ័យជម្នះថ្ងៃ១៧ មេសា ១៩៧៥?

**ឆ៖** ខ្ញុំជាអ្នកទិញអីវ៉ាន់ពីតំបន់ លន់ នល់ លក់ឲ្យតំបន់ខ្មែរក្រហម។

**ស៖** តើលោកធ្លាប់ធ្វើជាកងឈ្លបដែរទេ? ធ្លាប់ធ្វើជាកងឈ្លបនៅពេលណាមួយដែរទេ?

**ឆ៖** បាទ ខ្ញុំដែលទៅនៅក្នុងព្រៃទៅ គេឲ្យធ្វើកងឈ្លបបាទ នៅដែលពេលទៅនៅក្នុងព្រៃបាទ។

**ស៖** តើលោកធ្លាប់បានធ្វើជាប្រធានកងឈ្លប គឺថាក្តាប់ទាំងឈ្លបនារី ឈ្លបបុរស។ លោកធ្លាប់

ទេ?

**ធ៖** ខ្ញុំពេលនោះ គេបោះឆ្នោតជ្រើសរើសទៅ វាជាប់ខ្ញុំប្រធានឈ្លប តែខាងបុរសទេ មិនមែនខាងស្ត្រីទេបាទ។

**ស៖** ក្រុមដែលគេបោះឆ្នោតឲ្យលោកជាប់ឆ្នោតជាប្រធានកងឈ្លបហ្នឹង គឺជាកងឈ្លបឃុំស្រុក ឬក៏យ៉ាងណា?

**ធ៖** អ្វើជា អានោះ គឺក្មេងៗដែលនៅក្នុងភូមិបណ្ដោយ តែខ្ញុំចាស់ជាងគេហ្នឹង គេយកខ្ញុំ បាទ។

**ស៖** បាទ សូមអរគុណ។ តើអ្នកទាំងអស់នោះ មកពីៗស្រុកព្រៃនិព្វាន ឬក៏ស្រុកព្រះនេត្រព្រះក៏យ៉ាងណា?

**ធ៖** នៅនោះ ភាគច្រើនគឺនៅភូមិ ជិតគ្នាពីរភូមិ ភូមិខ្ញុំ បាទ។

**ស៖** ហើយភូមិរបស់លោកឈ្មោះ ចារលូ អ៊ីចឹងមែនទេ?

**ធ៖** ឈ្មោះ ចារលើ បាទ។

**ស៖** លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ អំពីលក្ខណៈខុសគ្នារវាងឈ្លប និងកងទ័ពនៅក្នុងរបបខ្មែរក្រហម?

**ធ៖** បាទ ខ្ញុំជម្រាបជូនបាន។ តែឈ្លប គ្រាន់តែជួយដឹក ជួយជញ្ជូនគេទៅទេ អត់មានពាក់ព័ន្ធអីចូលទៅធ្វើអីជាមួយយោធាទេ អត់ទេ គឺទៅជួយជញ្ជូន ជួយទៅយកសម្ភារៈអីទៅឲ្យ។

[១០:០៧:០០]

**ស៖** តើឈ្លបមិនមានដើរតួនាទីតាមដាន នៅក្នុងតំបន់ដែលខ្មែរក្រហមត្រួតត្រា សម្រាប់បុគ្គលណា ជនណាមួយដែលបង្កជាបញ្ហាអីទេ?

**ធ៖** បាទ ព្រោះគេឲ្យតាមដានដូចលោកនិយាយដែរ ព្រោះខ្លាចប្រជាជនណាបង្ករឿងរ៉ាវអីមិនប្រក្រតីអី តែធ្វើបានមួយរយៈមក ក៏ចប់ទៅបាទ។

**ស៖** លោករាយការណ៍ទៅឲ្យអ្នកណា?

**ធ៖** ឲ្យៗឃុំ ឲ្យប្រធានឃុំគេ បាទ។

**ស៖** លោកបានឆ្លើយថា លោកត្រូវបានគេជ្រើសរើសហ្នឹង ឲ្យធ្វើឈ្លបដោយសារតែលោកចាស់ជាងគេ។ នៅក្នុងចំណោមកងឈ្លបហ្នឹង តើមានអាយុពីប៉ុន្មាន ទៅដល់ប៉ុន្មាន?

**ធ៖** គេអត់បានគិតពីអាយុទេ គិតតែពីរើសអ្នកនៅលើវ បាទ។

**ស៖** ចុះឈ្លបដែលមានអាយុក្មេងជាងបំផុតហ្នឹង មានអាយុប៉ុន្មានដែរលោក?

**ឆ៖** ដែលជំនាន់នោះ ក្មេងជាងគេបំផុត ប្រហែលជា១៩ ទៅ២០ បាទ។

**ស៖** នៅពេលមួយនោះ តើមាននៅពេលណាមួយ ខ្មែរក្រហមបានវាយដណ្ដើមយក ក្ដោបក្ដាប់បានភូមិរបស់លោក ភូមិចារលើ ហ្នឹងដែរទេ?

**ឆ៖** បាទ នៅឆ្នាំ៧៣ ចូលនៅតាមភូមិបណ្ដោយ បាទ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកសហព្រះរាជអាជ្ញា។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ និងមេធាវីប្រឹក្សា នៅក្នុងអំឡុងពេលឈប់សម្រាក និងអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១០:១០ នាទី ដល់ម៉ោង១០:២៩ នាទី)*

[១០:២៨:៥៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាបន្តសំណួរដល់សាក្សីរូបនេះ!

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើឪពុកម្ដាយរបស់លោក ហើយនិងអ្នកជិតខាងរបស់លោកនៅក្នុងភូមិនោះពួកគាត់អាចរស់នៅក្នុងភូមិដដែលទេ? ឬក៏ពួកគាត់មានបញ្ហាអ្វីពេលដែលខ្មែរក្រហមមកកាលនោះ?

**លោក ឈិត យឿក៖**

**ឆ៖** ពួកខ្ញុំត្រូវខ្មែរក្រហមជម្លៀសចូលទៅព្រៃ។

**ស៖** តើនៅខែឆ្នាំណាដែលគេជម្លៀសឪពុកម្ដាយរបស់លោកចេញ?

**ឆ៖** ចុងឆ្នាំ៧៣។

**ស៖** ហេតុអ្វីបានជាគេយកអ្នកទាំងនោះចេញពីផ្ទះទៅនៅព្រៃវិញ?

**ឆ៖** មិនដឹងជាមូលហេតុអី ព្រោះអត់ហ៊ានសួរគេដែរ ព្រោះគេអត់ឲ្យនៅ។

**ស៖** តើមានតែឪពុកម្តាយរបស់លោកទេ ឬក៏អ្នកផ្សេងទៀតនៅក្នុងភូមិក៏ត្រូវបានគេបង្ខំឲ្យចេញពីភូមិ ពីផ្ទះសម្បែង?

**ឆ៖** បាទ ទាំងអស់ ប្រមាណពីរបីភូមិហ្នឹងត្រូវចេញទាំងអស់។

**ស៖** លោកសាក្សី ឥឡូវនេះ ខ្ញុំនឹងចូលទៅដល់សម័យក្រោយជោគជ័យរបស់ខ្មែរក្រហមក្រោយពីឆ្នាំ១៩៧៥។ តើលោកធ្វើការងារអ្វីក្រោយពីខ្មែរក្រហមទទួលបានជ័យជម្នះមកនោះ?

**ឆ៖** ខ្ញុំដំបូងគេហៅមកឲ្យធ្វើឈ្លបទៀត តែដល់រយៈក្រោយមកក៏គេត្រូវជ្រើសរើសទៅ ក៏ខ្ញុំក៏ទៅនៅកន្លែង គេហៅថានៅកន្លែងស្រុក ប៉ុន្តែមិនដឹងគេហៅថាស្អី ព្រោះខ្ញុំមិនមែនគណៈស្រុកណាបាទ។

[១០:៣១:៥៨]

**ស៖** បាទ នៅពេលដែលដំបូងក្រោយពីខែមេសា ឆ្នាំ១៩៧៥ គេចាត់តាំងឲ្យធ្វើឈ្លប តើលោកជាប្រធាន ឬក៏ តើលោកបញ្ជាលើកងឈ្លបមានគ្នាប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ពេលនោះខ្ញុំអស់នាទីជាប្រធានហើយ ព្រោះគេឲ្យដើរមើល យើងឈ្លបពីរបីនាក់ទៅដើរមើលប្រជាជនដែលគេជម្លៀសចេញពីភូមិហ្នឹងបាទ។

**ស៖** លោកនិយាយថា ក្រោយមកគេបញ្ជូនលោកទៅមន្ទីរស្រុក។ តើមន្ទីរស្រុកព្រះនេត្រព្រះឬ?

**ឆ៖** បាទ មន្ទីរស្រុកព្រះនេត្រព្រះ។

**ស៖** តើលោកចាំទេនៅពេលណា តើនៅក្នុងឆ្នាំណា ឬក៏នៅក្នុងរដូវប្រាំង ឬក៏រដូវវស្សាដែលគេបញ្ជូនលោកទៅទីនោះ?

**ឆ៖** នៅជិតឈានចូលដល់រដូវវស្សា ខ្ញុំទៅទីនោះបាទ ៧៥។

**ស៖** តើអ្នកណាជាគណៈស្រុកព្រះនេត្រព្រះនៅពេលដែលលោកចាប់ផ្តើមធ្វើការងារនៅទីនោះ?

**ឆ៖** ឈ្មោះ លឿម មុនដំបូង លឿម គាត់ធ្វើគណៈស្រុកព្រះនេត្រព្រះ។

**ស៖** តើ លឿម ក្រោយមកត្រូវបានគេដកចេញ មានអ្នកមកជំនួសឬទេ?

**ឆ៖** បាទ ក្រោយមកមាន តាម៉ោង គណៈស្រុកព្រះនេត្រព្រះបាទ។

**ស៖** តើលោកដឹងពីមូលហេតុដែលគេដក លឿម ចេញដែរឬទេ?

**ឆ៖** ទេ អង្កាល់នោះ ខ្ញុំក៏ក្តាប់មិនបានច្បាស់ ដោយសារឮតែគេថាគាត់ខុសសីលធម៌ បាទ។

**ស៖** តើ លឿម មានទំនាក់ទំនងអ្វីជាមួយ ខៀវ សំផន ទេ? លោកធ្លាប់ដឹងពីរឿងនេះទេ?

**ឆ៖** ទេ បើតាមការគិត គ្រាន់តែឮគេថាទេ ថាគាត់ធ្លាប់នៅជុំ ខៀវ សំផន តែខ្ញុំអត់បានដឹងច្បាស់លាស់ទេ នេះគ្រាន់តែឮគេថាដែរ។

**ស៖** បន្ទាប់ពីគេដក លឿម ចេញទៅ តើលោកដឹងទេថា គេយកទៅដាក់ទោស ឬក៏គាត់ទៅធ្វើការងារអ្វីផ្សេង?

**ឆ៖** បើតាមខ្ញុំដឹងគេដូរលោកទៅនៅៗបាត់ដំបងនោះវិញបាទ។

**ស៖** នៅក្នុងចម្លើយរបស់លោកៗ និយាយថាលោកបានឃើញគាត់នៅក្នុងឡាន។ តើលោកធ្លាប់បានឃើញគាត់នៅធ្វើដំណើរតាមឡាន តើពេលឃើញក្នុងឡានហ្នឹងលោកយល់ថា គាត់ធ្វើអីកាលនោះ?

**ឆ៖** កាលណោះ គាត់ ស្តាកឡានគាត់ដាក់ភូមិភាគបាទ តែយោធា។

**ស៖** ខ្ញុំនឹងបន្តទៅទៀត ខ្ញុំអាចត្រឡប់មកនៅពេលក្រោយ។ លោកសាក្សីការងារដែលលោកធ្វើនៅមន្ទីរស្រុក សូមលោកប្រាប់តុលាការថា ការងារមានអ្វីខ្លះ? តួនាទី ហើយនិងមុខងារធ្វើអ្វីខ្លះនៅកាលនោះ?

[១០:៣៦:២៧]

**ឆ៖** កាលដែលនៅមន្ទីរស្រុកនោះ ខ្ញុំមិនមានធ្វើអ្វីធំដុំទេ មានតែបញ្ជាពីស្រុកថា ឲ្យប្រជាជនដែលជម្លៀសនេះទៅឯណោះ ឲ្យប្រាប់អ្នកឡានទៅ ហើយក៏ឲ្យបញ្ជូនអង្ករទៅតាមកម្លាំងដែលរបបហូបហ្នឹងបាទ។

**ស៖** តើលោកធ្វើការជាមួយខាងបញ្ជីជំរឿនចំនួនប្រជាជនដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានធ្វើទេ ព្រោះមានគេអ្នកធ្វើផ្សេងហើយ។

**ស៖** តើលោកមានស្ថិតិដែលឬទេ ដែលប្រើដើម្បីបែងចែកប្រជាជន ហើយនិងប្រើសៀវភៅបញ្ជីជំរឿនដើម្បីបែងចែកអង្ករ ឬក៏អ្វី ស្បៀងអ្វីទេ?

**ឆ៖** បាទ ជំនាន់នោះមានតើ ព្រោះឲ្យដឹងថាកម្លាំងទៅៗភូមិនេះចំនួនប៉ុណ្ណេះ អង្ករត្រូវទៅប៉ុណ្ណោះ តែឥឡូវចាំលែងបានហើយ។

**ស៖** នៅពេលដែលលោកនិយាយអំពីជំរឿន តើព័ត៌មានអ្វីខ្លះដែលស្ថិតនៅក្នុងបញ្ជីជំរឿននោះ ដែលគេដាក់បញ្ចូលទៅក្នុងជំរឿន គឺថាមានឈ្មោះគ្រប់គ្នាប្រជាជនដែលរស់នៅក្នុងភូមិ ឬក៏ក្នុងស្រុកហ្នឹង ឬយ៉ាងម៉េច?

**ឆ៖** បាទ អត់ទេ មានតែចំនួន អត់មានឈ្មោះ អត់មានអីទេ។

**ស៖** តើលោកដឹងថា តើគេសម្រេចដោយរបៀបណា ប្រធានភូមិ ឬក៏អ្នកណាជាអ្នកចុះឈ្មោះ ឬក៏ចុះបញ្ជីប្រជាជនទៅក្នុងបញ្ជីនោះ?

**ឆ៖** ទេ បើតាមខ្ញុំយល់មានតែប្រធានភូមិ និងឃុំគេបាទ។

**ស៖** តើអ្នកណាម្នាក់ជាអ្នកកត់ឈ្មោះលោកចូលបញ្ជីហ្នឹងដែរឬទេ បញ្ជីជំរឿនប្រជាជននោះ?

**ឆ៖** ទេ អារឿងកត់នូវឈ្មោះអី ដូចជាមិនមាន ព្រោះខ្ញុំអត់បានកត់បានគួរអី។

**ស៖** ចុះការងាររបស់លោកបន្ទាប់ លោកធ្វើអីទៀត?

**ឆ៖** ដល់បន្ទាប់មក ខ្ញុំត្រូវគេដកចេញពីមន្ទីរស្រុក ទៅនៅចល័ត – ចល័តស្រុកវិញបាទ។

[១០:៤០:០៣]

**ស៖** តើលោកបានក្លាយទៅជាប្រធានកងចល័តយុវជនដែរឬទេ?

**ឆ៖** បាទ ពេលនោះ វាប្រធាន ប៉ុន្តែវាមិនបានគ្រប់គ្រងទាំងអស់ទេ ប៉ុន្តែជំនួយពីគេមកបាទ។

**ស៖** សូមអរគុណ។ តើមានកងចល័តសមាជិកប៉ុន្មាននាក់ដែលនៅក្រោមការគ្រប់គ្រងរបស់លោក?

**ឆ៖** មាន បើគិតទៅពី៦០០ ទៅ ១០០០ដែរ ប៉ុន្តែគ្រប់គ្រងបន្តជាមួយគេបាទ។

**ស៖** តើអាយុរបស់សមាជិកនៅក្នុងកងចល័តរបស់លោកហ្នឹង អាយុពីប៉ុន្មានដល់ប៉ុន្មានដែរ?

**ឆ៖** ចាប់ពីបីដណ្ដប់ឆ្នាំទៅ ប្រហែលជា២៧-២៨ ព្រោះខ្ញុំអាយុ២៧-២៨ ហើយបាទ។

**ស៖** ឥឡូវនេះនៅពេលណាមួយ នៅពេលដែលគេយក -- បញ្ជូនលោកចេញពីមន្ទីរស្រុក ហើយទៅកន្លែងមួយផ្សេងទៀត?

**ឆ៖** ពេលដែលខ្ញុំចេញទៅពីមន្ទីរស្រុក ចាំវាមិនបានដែរ ព្រោះខ្ញុំធ្វើបានប្រហែល៦ខែនៅមន្ទីរស្រុកហ្នឹង រួចគេដកចេញទៅ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងព្យាយាមការចងចាំ នៅក្នុងឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា តើលោកនៅចាំទេថា គឺថាលោកផ្ដល់បទសម្ភាសន៍មួយមកពី បុគ្គលិកមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺ

មានមនុស្សពីរបីនាក់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានមកជួបលោក។ ហើយក៏បាននិយាយអំពីទំនប់ត្រពាំងថ្ម នៅឆ្នាំ២០១១។ តើលោកចាំទេពីបទសម្ភាសន៍នោះ ហើយលោកបាននិយាយប្រាប់ទៅដានី, ដារ៉ា នៅក្នុងឆ្នាំ២០១១ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំនៅចាំបានខ្លះ។

[១០:៤៣:១៥]

**ស៖** បាទ នៅក្នុងបទសម្ភាសន៍នោះ នៅទំព័រខ្មែរ ERN 00728790, ទំព័រ១៤ ភាសាអង់គ្លេស ហើយបារាំង 01123715 ដានីបានសួរថា៖ "តើគេឲ្យលោកពីកងចល័តស្រុកទៅតំបន់នោះពេលណា?" ហើយលោកឆ្លើយថា៖ "នៅឆ្នាំ១៩៧៦ ប្រហែលជានៅក្នុងខែតុលា"។ ខ្ញុំចង់សួរលោកថា តើលោកចង់និយាយម៉េចនេះ លោកចេញពីកងទៅចល័តទៅថ្នាក់រដ្ឋនោះ គឺថាទៅមានន័យដូចម្ដេចកន្លែងហ្នឹង?

**ឆ៖** បាទ ពីព្រោះនោះ បានន័យថាចល័តស្រុកផ្សេង។ ព្រោះចល័តតំបន់ គេប្រមូលក្នុងមួយតំបន់ ដូចយើងប្រមូលមួយខេត្តអ៊ីចឹង។ បើស្រុកផ្សេងដោយស្រុកបាទ។

**ស៖** អ៊ីចឹងនៅពេលលោកនិយាយ ពាក្យថា"តំបន់រដ្ឋ"នោះ គឺថាមានន័យថា ទៅជាកងចល័តរបស់តំបន់។ តើអ៊ីចឹងឬទេ?

**ឆ៖** បាទ ព្រោះគេប្រមូល គេជ្រើសពីតាមស្រុកមក យកមកធ្វើជាចល័តតំបន់បាទ។

**ស៖** លោកបាននិយាយនៅក្នុងបទសម្ភាសន៍នោះ គឺថាមានជម្លោះរវាងរដ្ឋ ហើយនិងសហករណ៍ដែលគេឈ្លោះអំពីរបបអាហារ អំពីស្បៀងអាហារ តើលោកពន្យល់បន្តិចទេ ជូនតុលាការនៅពេលនេះ?

**ឆ៖** បាទ ពីព្រោះអង្កាល់នោះ សហករណ៍នឹងនេះវាផ្សេង ព្រោះចល័តហូប ដូចថា យើងបានពីរកំប៉ុងអី តែសហករណ៍អត់បានទេ។ ព្រោះចល័ត គេឲ្យដូចជាកម្លាំងទី១ បាទ។

**ស៖** តើលោកដឹងថា របបអាហារនៅសហករណ៍ហ្នឹង កម្រិតណាដែរនៅពេលនោះ?

**ឆ៖** ទេ បើតាមខ្ញុំដឹងខ្លះទេ ព្រោះនៅជាមួយចល័តនេះ អត់សូវបានដឹងពីសហករណ៍ គ្រាន់តែដឹងតាមរយៈអ្នកទៅមកខ្លះ។ ហូបកន្លះកំប៉ុងមួយថ្ងៃ បាទ ហើយនិងមានទៅឈានពេលដាច់ បាទ។

[១០:៤៦:៣៩]

**ស៖** លោកសាក្សី ខ្ញុំចង់សួរលោកអំពីឯកសារមួយ ឯកសារ E3/1181 បាទ E3/1181។ ឯកសារខ្លី ខ្ញុំនឹងអានកថាខណ្ឌលេខ៤ ភាសាបីស្រួលតាម។ វាជាឯកសារមួយជាភាសាខ្មែរ ចុះថ្ងៃទី២៧ មិថុនា ឆ្នាំ១៩៧៧។ លោកសាក្សី គេនិយាយថា "ស្រុកព្រះនេត្រព្រះ ប្រជាជនព្រះនេត្រព្រះមុនឆ្នាំ

១៩៧៥ គឺមាន១៥០គ្រួសារ គឺច្រើនជាង៧០០០នោះ គឺមកពីភ្នំពេញ។ ៣០០០០នាក់ គឺរស់នៅក្នុងស្រុកព្រះនេត្រព្រះ មុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ ព្រះនេត្រព្រះ ហើយនិងឃុំប្រសាទ មានចំនួនសមាសភាពមិនល្អហ្នឹងច្រើន។ ព្រៃខម--"។ ខ្ញុំសូមបញ្ចប់ត្រឹមនេះសិន។ អ្វីដែលខ្ញុំអានមកដល់ពេលនេះ តើត្រឹមត្រូវទេខ្លឹមសារ តាមអ្វីដែលលោកចងចាំនោះ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមកាត់ផ្តាច់។ ខ្ញុំគ្រាន់តែធ្វើការកត់សម្គាល់មួយតែប៉ុណ្ណោះ។ ដើម្បីជួយដល់អ្នកបកប្រែ ដើម្បីផ្តល់លេខ ERN ដើម្បីឲ្យគាត់អាចបកប្រែបាន ព្រោះថាពេលដែលសហព្រះរាជអាជ្ញាគាត់ដកស្រង់នោះ មិនមានលេខ ERN អីជាដើមហ្នឹង អ្នកបកប្រែ គាត់ពិបាកតាម។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមិនបានផ្តល់លេខ ERN ទេ ពីព្រោះជាឯកសារខ្លី ដែលកថាខណ្ឌ៤ នៅក្នុងឯកសារហ្នឹងជាភាសាបី គឺថាមានកថាខណ្ឌលេខ៤ បាទ។

[១០:៤៩:០៣]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើត្រឹមត្រូវទេ ខ្លឹមសារដែលខ្ញុំទើបតែបានអានហ្នឹង អំពីស្រុកព្រះនេត្រព្រះនោះ?

**លោក ឈិត យឿក៖**

**ឆ៖** បាទ ដោយមុន៧៥ ខ្ញុំមិនអាចទទួលដឹងថា ប្រជាជនមានប៉ុន្មានទេ បើតាមការគិតនេះខ្ញុំមិនដឹងមុន។

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលឯកសារនេះ និយាយថា ប្រជាជនជាង ៣០.០០០នាក់ គឺថាក្រោយឆ្នាំ១៩៧៥ ខែមេសា។ តើអ៊ីចឹងឬទេ?

**ឆ៖** បាទ អាហ្នឹង ៣០.០០០។

**ប្រធានអង្គជំនុំ៖**

សូមអរញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។

**លោក នីកូឡាស គូមជែន៖**

តើត្រឹមត្រូវដែរទេ គឺថាភាគច្រើន?

**លោក គង់ សំអុន៖**

សុំជំទាស់ចំពោះការប្រើប្រាស់ឯកសារនេះជាលក្ខណៈរួម ក៏ប៉ុន្តែបើសិនជាសហព្រះរាជអាជ្ញាមានបំណងប្រើប្រាស់ឯកសារនេះ គួរតែបង្ហាញពីទំនាក់ទំនងដែលសាក្សីរូបនេះបានដឹង បានឮ អំពីឯកសារជាមុនសិន ពីព្រោះថានៅពេលដែលសាក្សី -- ការបង្ហាញឯកសារមួយដែលសាក្សីមិនដែលបានស្គាល់ មិនបានដឹង ហើយប្រើដើម្បីថាឲ្យគាត់ធ្វើអត្ថាធិប្បាយទៅឯកសារនោះ គឺវាមានភាពដែលអាចទុកចិត្តបានអំពីភស្តុតាងទេបាទ។ ដូច្នេះសហព្រះរាជអាជ្ញាគួរតែសួរបញ្ជាក់អំពីស្ថានភាពនៃឯកសារនេះថាតើសាក្សីធ្លាប់បានដឹង បានឮ អំពីរបាយការណ៍នេះដែរឬទេ? បាទ សូមអរគុណ។

[១០:៥១:០៥]

**លោក នីកូឡាស គូមជែន៖**

លោកចៅក្រម គឺឯកសារនេះ គឺនិយាយអំពីព្រះនេត្រព្រះ ជាទីកន្លែងដែលសាក្សីបានកើតនៅទីនោះ ហើយធ្វើនៅកន្លែងនោះ នៅមន្ទីរស្រុកទៀត ហើយគាត់បានដឹងពីស្រុកព្រះនេត្រព្រះហ្នឹង។ អ្វីដែលខ្ញុំអានហ្នឹង គឺគ្រាន់ដើម្បីសួរគាត់ថាតើអ្វីដែលគាត់ដឹងដោយផ្ទាល់ខ្លួន តើពិតជាអ៊ីចឹងដែរឬអត់ ជាការយល់ដឹងរបស់គាត់អំពីរឿងហ្នឹង។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** អ៊ីចឹងលោកសាក្សី ខ្ញុំសូមអានដើម្បីបញ្ចប់ផ្នែកនេះគឺថា គឺមានចំណុចមួយផ្សេងទៀតនៅក្នុងឯកសារនេះដែលនិយាយថា ជាកន្លែងអាក្រក់បំផុតដែលអត់អាហារ គឺចុងឆ្នាំក្រោយនេះ គឺថាអាចធ្វើឲ្យមនុស្សស្លាប់ជាង ២០.០០០នាក់ នៅក្នុងឯកសារនេះចុះថ្ងៃទី -- ខែមិថុនា ឆ្នាំ១៩៧៧ ហើយថាតើនៅក្នុងឆ្នាំនោះ តើមានមនុស្សអត់អាហារស្លាប់ច្រើនដែរឬទេ លោកសាក្សី?

**លោក ឈិត យឿក៖**

**ឆ៖** ទេ នៅក្នុងឆ្នាំនោះវាស្លាប់ដែរ ដោយទៅសម្រាកពេទ្យខ្លះក៏ស្លាប់ទៅ ហើយជួនកាលក៏ស្លាប់នៅហ្នឹងកន្លែង តែរឿងចំនួនវាមិនដឹងគិតទេ ព្រោះនៅក្នុង--។

**ស៖** សូមអរគុណ។ ខ្ញុំនឹងបន្តទៅឯកសារមួយទៀត ឯកសារ E31783, ខ្មែរ ERN គឺ 00659260, បារាំង 00606766 ហើយអង់គ្លេស 0049180។ ខ្ញុំ -- ឯកសារនេះមេធាវីការពារក្ដីបានអានជូនទៅសាក្សីចុងក្រោយនេះ។ លោកសាក្សី នេះជាឯកសារមួយដែលយកមកពីសម័យខ្មែរក្រហម ដែលគេដាក់ចំណងថា -- ដែលនិយាយថា បាទ គឺថាតំបន់៥ នៃត្រពាំងថ្ម គឺថាយើងអាច បើយើងឈរនៅទីនោះយើងអាចឃើញគេជិះកាណូត ហើយយើងអាចឃើញជើងភ្នំ។ ហើយសមមិត្ត រស់ ញឹម ហើយនិងប្រធាន គណៈប្រធានរដ្ឋ ហើយនិងអនុភូមិភាគពាយ័ព្យ ហើយនិងស្ថិតនៅក្នុងគណៈប្រជាជន ហើយបាននិយាយថា អាងទឹកនេះគឺធ្វើ សាងសង់ក្នុងរយៈពេលតិចជាងពីរខែ ដោយប្រជាជនទាំងអស់នៅក្នុងភូមិភាគ -- នៅក្នុងតំបន់៥។ ហើយឆ្លើយតបទៅនឹងគណៈមជ្ឈិមបក្សដើម្បីៗបង្កើតនូវគម្រោងអាងនេះដ៏ធំធេងមួយ ដើម្បីជាធារាសាស្ត្រ។ លោកសាក្សី ខ្ញុំនឹងត្រឡប់មកពេលក្រោយ តើនៅពេលណាមួយ តើគេបញ្ជូនលោកទៅធ្វើការនៅត្រពាំងថ្មការដ្ឋានទំនប់ត្រពាំងថ្មដែរឬទេ?

**ឆ៖** បាទ គេបញ្ជូនទៅនៅ ប្រហែលជាដើមឆ្នាំ៧៦នេះ ខែប៉ុន្មានទេ ខែ៥, ខែ៤ហ្នឹង ព្រោះរួចច្រូតស្រូវ គេត្រូវបញ្ជូនទៅអាងត្រពាំងថ្ម។

[១០:៥៥:២២]

**ស៖** មុននឹងសួរនៅឆ្នាំ នៅពេលដែលលោកទៅដល់កន្លែងនោះ តើការសាងសង់កំពង់តែចាប់ផ្ដើម ឬក៏ក្នុងពេលដែលលោកទៅនោះ លោកជាក្រុមទី១ ដំបូងដែលទៅដល់កន្លែងហ្នឹង?

**ឆ៖** ខ្ញុំទៅហ្នឹង គឺមានគេនៅមុនហើយ គេអ្នកវាស់វែងអីរួចអស់ហើយ បានពួកខ្ញុំទៅ។

**ស៖** នៅក្នុងចម្លើយពីមុនរបស់លោក លោកនិយាយថា -- ខ្ញុំសួរលោកបែបនេះវិញ តើលោកនៅចាំទេ តើគម្រោងសាងសង់ហ្នឹង ចាប់ផ្ដើមនៅខែណា ឆ្នាំណា?

**ឆ៖** គម្រោងហ្នឹង ខ្ញុំបែបជាមិនចាំច្បាស់ តែដឹងថា ឆ្នាំ៧៦ គឺដើមឆ្នាំហើយ ទំនងដែលគេសាងសង់។ វាភ្លេចដែរ យូរហើយ។

**ស៖** បាទ។ តើលោកអាចជម្រាបតុលាការបានទេ តើលោកទៅធ្វើការនៅការដ្ឋានទំនប់នោះអស់រយៈពេលប៉ុន្មាន ដែលលោកធ្វើការនៅទីនោះនុះ អស់ពេលប៉ុន្មាន?

**ធ៖** ខ្ញុំធ្វើចាប់ពីនោះ មកទល់នឹងឆ្នាំ ចុងឆ្នាំ៧៧។

**ស៖** តើលោកនៅចាំទេ ប្រហែលរយៈពេលប៉ុន្មាន ប្រហែលជាប៉ុន្មានខែ ដែលលោកចាប់ផ្ដើមពីដំបូង រហូតដល់លោកចប់ពីកន្លែងហ្នឹង?

**ធ៖** ប្រហែលជាចាប់ពីខែ០៥, ៧៦ មកខែ១២, ៧៧, ៧៨ ហើយ ចាំមិនបានដែរ ភ្លេច។

**ស៖** បាទ។ អ៊ីចឹងគឺថា លោកបញ្ជាក់ថា លោកនៅទីនោះជាងមួយឆ្នាំ។ តើអ៊ីចឹងមែនឬទេ?

**ធ៖** បាទ។

**ស៖** រស់ ញឹម ក៏បន្តនិយាយទៀត នៅទំព័រដដែល គាត់និយាយថា ចាប់ផ្ដើមយើងពីកងសាងអាងទឹកនេះ គឺមនុស្ស ២០.០០០នាក់ បានចូលរួមនៅក្នុងការសាងសង់ ទោះបីជាមិនមានទឹកបរិភោគគ្រប់គ្រាន់ក៏ដោយ។ តើលោកចាំទេថា ករណីថាមិនមានទឹកហូបដែរឬទេ ពេលដែលលោកនៅទីនោះ?

**ធ៖** បាទ ខ្ញុំចាំបាន ព្រោះអត់ទឹក ហេតុនេះមានឡានគេដឹកទឹកមក។

[១០:៥៩:០១]

**ស៖** នៅក្នុងពេលថ្ងៃដែលលោកធ្វើការនៅទីនោះ តើលោកមានទឹកហូបទេ ឬក៏មិនមានទេ?

**ធ៖** នៅពេលថ្ងៃ មានទឹកហូប តែវាមិនគ្រប់គ្រាន់ ពីព្រោះវាអ្នកដែលនៅជិតបឹងជិតអី អាចបានហូបគ្រប់ អ្នកដែលនៅឆ្ងាយ លំបាក ព្រោះឡានយកមកឱ្យអត់ទាន់ បាទ។

**ស៖** នៅពេលដែលលោកធ្វើការនៅទំនប់នោះ តើលោកដឹកនាំក្រុម ឬក៏លោកដឹកនាំកងចល័ត ឬក៏កងអ្វីផ្សេងដែរឬទេ?

**ធ៖** ដំបូង ខ្ញុំគេឱ្យចូលនៅជាសមាជិកទេ ប៉ុន្តែក្រោយមក គេដកខ្ញុំឱ្យរែកដី លើកលាមក។

**ស៖** ខ្ញុំនឹងត្រឡប់មកបញ្ហានេះនៅបន្តិចខាងមុខ។ នៅពេលដែលលោកធ្វើជាសមាជិកហ្នឹង តើលោកត្រួតពិនិត្យការងារអ្នកផ្សេង ឬក៏គ្រាន់តែជាសមាជិកធម្មតា?

**ធ៖** បាទ គឺសមាជិកវាត្រូវជំនួយជួយមើលខុសត្រូវគេខ្លះបាទ។

**ស៖** តើអ្នកណាជាប្រធាននៅពេលនោះ?

**ធ៖** នៅពេលដំបូងគឺ តាវ៉ាល់។ ឈ្មោះ តាវ៉ាល់ ប្រធានធំមួយចល័តបាទ។

**ស៖** តើលោកធ្វើការជាជំនួយការរបស់ តាវ៉ាល់ ហ្នឹងអស់រយៈពេលប៉ុន្មាន?

**ធ៖** ខ្ញុំធ្វើប្រហែលជាបួនខែ គេត្រូវដកឱ្យខ្ញុំរែកដី លើកលាមកដែរ។

**ស៖** ហេតុអ្វីគេឱ្យលោកទៅរែកដី?

**ឆ៖** គេផ្លាស់ប្តូរទៅ ព្រោះខ្ញុំក៏មិនដឹងមូលហេតុអីដែរ ព្រោះពេលហ្នឹងអត់មានប៊ានសួរថាម៉េចអីទេ តែគេដកហើយៗ។

**ស៖** ខ្ញុំនឹងត្រឡប់ចូលមកនិយាយចំណុចនេះបន្តិចទៀតនេះ។ មុនពេលចាប់ផ្តើមលើកទំនប់ លោកមានបានដឹងថា តាវ៉ាល់ មានបើកកិច្ចប្រជុំណាមួយស្តីអំពីការងារលើកទំនប់នេះទេ?

**ឆ៖** ទេ ខ្ញុំគឺមិនអាចដឹងទេ ពីព្រោះដែលគេប្រជុំអី គេទៅប្រជុំនៅតំបន់ពិភាក្សាគ្នាពីបញ្ហាគូសផែនទី ត្រូវលើកយ៉ាងម៉េចអីយ៉ាងម៉េចហ្នឹង បើតាមខ្ញុំដឹងគេប្រជុំនៅតំបន់បាទ។

**ស៖** តើ តាវ៉ាល់ មានប្រាប់លោក និងអ្នកដទៃទៀតអំពីកិច្ចប្រជុំដែល តាវ៉ាល់ គាត់បានទៅចូលរួមប្រជុំនោះស្តីអំពីផែនការលើកទំនប់នេះទេ?

**ឆ៖** តែមកវិញ ហ្នឹងគេថា គេផ្សព្វផ្សាយទៅតាមកង ពីព្រោះមានមុខនាទីទៅប្រជុំខ្លះៗហើយខ្លះហ្នឹងក៏បន្តពីគ្នាមក តែគ្រាន់តែថា គេត្រូវធ្វើឲ្យមានចំណុះប៉ុន្មានម៉ឺនលានម៉ែត្រគូប ហើយកម្ពស់ប៉ុន្មានៗទៅ ហើយផែនការធ្វើឲ្យបានបីខែ ឬប្រាំមួយខែឲ្យចប់ ហ្នឹងចេះតែឮបាទ។

[១១:០៣:៣៨]

**ស៖** តើពួកគាត់មានប្រាប់ថាការណែនាំនេះ ឬក៏ផែនការនេះ ចេញមកពីខាងណាទេ?

**ឆ៖** ថាមកពីភូមិភាគបាទ។

**ស៖** លោកសាក្សី កាលដែលខ្ញុំសួរនេះ តើលោកដឹងថាមានកិច្ចប្រជុំមួយនៅឯស្វាយដែរឬទេ? មួយខែ ឬក៏ពីរខែមុនចាប់ផ្តើមលើកទំនប់នេះ?

**ឆ៖** បាទ មានកិច្ចប្រជុំនៅស្វាយ តែទៅប្រជុំតែ គេមិនមែនឲ្យចេះតែឲ្យទៅ ឲ្យតែមេៗគេទៅបាទ។

**ស៖** តើមានថ្នាក់ដឹកនាំណាម្នាក់មកពីមជ្ឈិមបក្សទេ?

**ឆ៖** ដូចជាមិនមានដោយសារ មាន ឬក៏ខ្ញុំមិនស្គាល់ ហ្នឹងវាពិបាកដែរជំនាន់នោះ ព្រោះគេអត់បានប្រាប់យើងថាយ៉ាងណាៗ។

**ស៖** លោកសាក្សី ខ្ញុំសូមរំឭកលោកអំពីអ្វីដែលលោកបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ សម្រាប់មេធាវីការពារក្តី ខ្មែរ ERN គឺ 00728803, អង់គ្លេស 00731127 និងភាសាបារាំង 01123722។ "លោកបានឆ្លើយទៅប្រាប់ ដានី ថា៖ ដោយសារត្រពាំងថ្មបានចាប់លើកទំនប់នៅខែកុម្ភៈ ១៩៧៧ ប៉ុន្តែគេបានជួបប្រជុំមួយខែ ពីរខែមុន គេធ្វើការសិក្សា

ស្រាវជ្រាវពីការលើកទំនប់នេះ ហើយក្រោយមកក៏បានបង្កើតគណៈកម្មាធិការមួយ។ ដានី សួរទៅលោកថា៖ នៅក្នុងកិច្ចប្រជុំអ្នកណាមានវត្តមានខ្លះ? លោកឆ្លើយថា៖ មានតាញឹម។ ហើយគាត់សួរតទៅទៀតថា៖ តើមានអ្នកណាមកពីមជ្ឈិមបក្សដែរទេ? លោកឆ្លើយថា៖ ពួកគេមានអ្នកមកពីមជ្ឈិមតែខ្ញុំអត់ស្គាល់ពួកគាត់។ ដានី សួរលោកបន្តទៅទៀតដើម្បីឱ្យលោកប្រាប់អំពីកិច្ចប្រជុំ ហើយលោកបានឆ្លើយថា៖ លោកមិនស្គាល់អ្នកណាម្នាក់មកពីមជ្ឈិមបក្សពីភ្នំពេញដែរទេ?” លោកឆ្លើយថា៖ លោកមិនស្គាល់ទេ។ ហើយគាត់សួរទៀតថា៖ តើពួកៗមេដឹកនាំពីមជ្ឈិមពិតជាមកចូលរួម? លោកឆ្លើយថា៖ មាន តែលោកស្គាល់តែ តាញឹម។ ហើយលោកក៏បានឆ្លើយថា៖ មានអ្នកមកពីតំបន់ដែរ ដូចជាតាហុង។ ហើយលោកក៏បានឆ្លើយដែរថា សមាជិក គណៈកម្មាធិការស្រុកទាំងអស់បានចូលរួមប្រជុំ។ ហើយក្រោមមកទៀត ទំព័របន្ទាប់ជាភាសាអង់គ្លេស លោកបានឆ្លើយថា៖ ដំបូងគេជួបប្រជុំគ្នានៅស្វាយ ហើយក្រោយមកជួបប្រជុំគ្នានៅត្រពាំងថ្ម។ ដានី សួរថា៖ លោកបានចូលរួមប្រជុំទេចុះ? លោកឆ្លើយថា៖ អត់បានចូលរួមប្រជុំទេ។ ចុះបើមិនបានចូលរួមប្រជុំ ម៉េចបានដឹងថាមានប្រជុំ? លោកបានឆ្លើយថា៖ ពួកគេប្រាប់ខ្ញុំថា ស្អែកនេះនឹងមានប្រជុំជាមួយនឹងសមាជិកមជ្ឈិមបក្ស សមាជិកគណៈកម្មាធិការស្រុក ប្រធានតំបន់”។ តើអ្វីដែលខ្ញុំអានឱ្យលោកស្តាប់នេះត្រឹមត្រូវដែរទេថា លោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងកិច្ចសម្ភាសន៍មួយនៅឆ្នាំ២០១១។ អ៊ីចឹងមែនទេ?

លោកសាក្សី ខ្ញុំកំពុងតែរង់ចាំចម្លើយរបស់លោក។

*(សម្រាករយៈពេលខ្លី)*

[១១:០៨:៥៦]

**ស៖** លោកសាក្សី លោកបានស្តាប់ឮនូវអ្វីដែលខ្ញុំអាននូវអ្វីដែលខ្ញុំអានឱ្យលោកស្តាប់មុននេះទេ ខ្ញុំគិតថាអានឱ្យលោកស្តាប់ម្តងទៀត វាវែងបន្តិច។

**ឆ៖** បាទ។

**ស៖** មុននេះលោកមានស្តាប់ឮខ្ញុំអានឱ្យលោកស្តាប់ទេ ហើយលោកស្តាប់សំណួរខ្ញុំទាន់ទេ ឬក៏លោកចង់ឱ្យខ្ញុំអានម្តងទៀត?

**ឆ៖** បាទ ស្តាប់អត់ទាន់។

**ស៖** បាទ ខ្ញុំព្យាយាមអានម្តងទៀត ហើយម្តងនេះគឺថាលើកឡើងតែចំណុចសំខាន់ៗទេ។ លោកបាននិយាយថា ទំនប់ត្រពាំងថ្មចាប់ផ្តើមលើកនៅខែកុម្ភៈ ប្រហែលជានៅក្នុងឆ្នាំ១៩៧៧។ ប៉ុន្តែ

មួយខែ ពីរខែមុននេះ មានកិច្ចប្រជុំមួយដែលនៅក្នុងកិច្ចប្រជុំនោះមានវត្តមាន តាញឹម និងអ្នកដែលមកពីគណៈមជ្ឈិម។ ហើយលោកក៏បានឆ្លើយថា មានប្រជាជនមកពីតំបន់របស់ តាហ៊ីង្ស ហើយនិងសមាជិកគណៈកម្មាធិការស្រុកទាំងអស់ ហើយលោកបានឆ្លើយថាប្រធានកងចល័ត តាវ៉ាល់។ ហើយគេសួរលោកថា គេជួបប្រជុំនៅឯណា? លោកថាដំបូងប្រជុំស្វាយ ក្រោយមកប្រជុំនៅត្រពាំងថ្ម។ លោកបានឆ្លើយថាលោកមិនបានចូលរួមប្រជុំទេ ប៉ុន្តែអ្នកដែលប្រជុំនោះបានប្រាប់លោកថា ស្អែកនេះនឹងមានកិច្ចប្រជុំជាមួយនឹងប្រធានគណៈកម្មាធិការស្រុក សមាជិកគណៈកម្មាធិការស្រុក ប្រធានតំបន់ និងអ្នកដែលមកពីមជ្ឈិម។ តើត្រឹមត្រូវដែរទេ ដែលលោកបានឆ្លើយថាមានកិច្ចប្រជុំមួយនៅស្វាយ និងមួយលើកទៀតនៅត្រពាំងថ្មអំពីផែនការលើកទំនប់នេះ?

[១១:១១:១៦]

**ឆ៖** បាទ ត្រឹមត្រូវហើយ ព្រោះគេប្រជុំពីស្វាយហើយ មកប្រជុំនៅអាងត្រពាំងថ្មហ្នឹង។

**ស៖** តើគេប្រាប់លោកថាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស សមាជិកគណៈកម្មាធិការស្រុក ប្រធានតំបន់ និងអ្នកមួយចំនួនទៀតមានវត្តមាននៅក្នុងកិច្ចប្រជុំនេះ?

**ឆ៖** ទេ គេអត់បានប្រាប់ថាយ៉ាងណាទេ ព្រោះគ្រាន់តែគេផ្សព្វផ្សាយត្រូវធ្វើផែនការលើកទំនប់ហ្នឹងតមក។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានកត់ត្រាត្រឹមត្រូវ លោកបានឆ្លើយថា៖ "បាទ ពួកគេបានប្រាប់ខ្ញុំថា ស្អែកនេះនឹងមានកិច្ចប្រជុំ ដែលមានសមាជិកមកពីគណៈកម្មាធិការមជ្ឈិម សមាជិកគណៈកម្មាធិការស្រុក តំបន់"។ តើពេលលោកឆ្លើយហ្នឹង តើលោកឆ្លើយកុហកអ្នកគេសួរលោកហ្នឹង នៅពេលសម្ភាសហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ពេលនោះ គឺគេប្រាប់អ៊ីចុះមែន។ ខ្ញុំមានមិនថាអី ប៉ុន្តែត្រង់អ្នកណា ឈ្មោះណាឈ្មោះណី ខ្ញុំអត់ដឹងដែរ។ គេប្រជុំមែន។

[១១:១២:៥៦]

**ស៖** តើពួកគេមាននិយាយប្រាប់ថា សមាជិកគណៈមជ្ឈិមមានវត្តមានក្នុងកិច្ចប្រជុំនោះទេ?

**ឆ៖** ទេ តាមដែលឮគេប្រាប់ថាមាន ប៉ុន្តែមិនដឹងជាគេឈ្មោះណាដែលត្រូវទៅធ្វើប្រជុំនៅនោះ ខ្ញុំអត់ដឹងដែរ។

**ស៖** នៅពេលដែលលោកធ្វើការជាមួយកងចល័តនៅទំនប់នោះ តើរបបអាហារនោះ គេចែក

បានប៉ុនណាដែរលោក?

**ឆៈ** របបអាហារ ពេលគេរើសម្រុកបានមួយថ្ងៃបីកំប៉ុង តែដល់ពេលដែលមិនបានរើសម្រុកទេ មួយកំប៉ុងកន្លះ ហើយជួនកាលក៏វារហូតដល់មានដាច់អាហារដែរបាទ។

**សៈ** លោកបានឆ្លើយថា -- បាទខ្ញុំសួររបៀបផ្សេង។ តើពលករកម្មករមកពីកន្លែងផ្សេងគ្នា ទទួលរបបអាហារខុសគ្នាឬក៏អត់? ដូចជាលោក ពេលដែលគេឱ្យលោករែកដីលេខ១អីចឹង តើរបប អាហារហ្នឹងវាខុសពីគេ ឬយ៉ាងម៉េច?

[១១:១៤:៣១]

**ឆៈ** បាទ រឿងឱ្យរែកដីលេខ១លេខអី គេបើកយ៉ាងណា ពួកខ្ញុំក៏បើកអីចឹងដែរ។ ហើយតាម ស្រុកផ្សេងគ្នា ដែលមាននៅចល័តហ្នឹងក៏បើកដូចគ្នាទាំងអស់ដែរ។

**សៈ** សំណួររបស់ខ្ញុំ នៅពេលដែលលោកប្រមូលដី រែកដី តើលោកទទួលបានបីកំប៉ុង ក្នុងមួយ ថ្ងៃ ឬក៏យ៉ាងម៉េច ពីព្រោះលោកឆ្លើយថា បើធ្វើការពិបាកទៅ សម្រុកទៅ គឺថាបានបីកំប៉ុងក្នុងមួយថ្ងៃ។ បើធ្វើតិចទៅ បានតិច។ ចុះលោកនោះ ពេលដែលលោកធ្វើការរែកសែងដីហ្នឹង តើលោកទទួលបានរបប អាហារប៉ុន្មាន?

**ឆៈ** ពេលដែលខ្ញុំរែកដីនោះ ក៏តែនៅក្នុងនោះ គេបើកបី ខ្ញុំក៏បើកបីដែរ ដែលនៅក្នុងពេលគេ សម្រុកនោះ បាទ។

**សៈ** លោកនៅក្នុងកងចល័តនោះដដែលឬ នៅពេលដែលលោករែកដី?

**ឆៈ** បាទ ខ្ញុំនៅក្នុងកងចល័ត។ ព្រោះគេឱ្យរែកដីនៅក្នុងចល័ត បាទ។

**សៈ** តើលោករែកដី រែកដីនៅឯកន្លែងទំនប់ជិតទំនប់ហ្នឹង នៅឯទំនប់ហ្នឹង ឬក៏រែកដីនៅកន្លែង ផ្សេង?

**ឆៈ** បាទ ដីវាអត់ទៀង ជួនកាលក៏រែកចល័តដែលនៅជិតនោះទៅ ប៉ុន្តែក្រោយមក មករែកនៅ តាមចល័តដែលនៅអែបៗព្រៃឯណោះទៅ បាទ។

**សៈ** លោកបានឆ្លើយថាលោកបានរែកដីលេខមួយ ដីអាចម៍ គឺថាវាជាការមួយមិនគួរឱ្យចង់ធ្វើ ទេ។ អីចឹង ហេតុអ្វីក៏លោក ដោយសារលោក គឺថាជាអ្នកដែលទទួលបានការជ្រោមជ្រែង ដូចជំនួយការ ពី តាវ៉ាល់។ ហេតុអ្វីបានជាគេបញ្ជូនលោកទៅឱ្យរែកដីលេខមួយហ្នឹង?

**ឆៈ** បាទ ពេលនោះ វាមិនដឹងកំហុសខ្លួនឯងដែរជំនាន់នោះ ព្រោះតែគេដក ដកឱ្យរែកអី រែក។

ធ្វើអីធ្វើ។ តែយើងគិតខ្លួនយើងថាប្រហែលជាមានការចោទប្រកាន់ពីអ្នកណាម្នាក់ បាទ។

**ស៖** អ្នកណាជាអ្នកចាត់តាំងលោកឡើងវិញឲ្យទៅរែកដីលេខមួយហ្នឹង?

[១១:១៧:៤៩]

**ឆ៖** តាវ៉ាល់ គេប្រជុំ គេដកខ្ញុំ ឲ្យចាត់តាំងឲ្យរែកដីលេខមួយ បាទ។

**ស៖** ហេតុអ្វីបានលោកមិនសួរទៅ តាវ៉ាល់ ថាហេតុអីក៏ចាត់តាំងឲ្យលោករែកដីលេខមួយអ៊ីចឹង?

**ឆ៖** ជំនាន់នោះ អត់ប៉ានសួរទេ។ ពីណាក៏ដោយៗ បើគេចាត់តាំងឲ្យធ្វើអីហើយ គឺត្រូវតែធ្វើ បាទ មិនអាចទៅសួរដេញដោលអីបានទេ។ មិនប៉ានសួរផង និយាយឲ្យខ្លី បាទ។

**ស៖** ចុះហេតុអ្វីក៏លោកមិនបដិសេធកុំធ្វើការហ្នឹងទៅ?

**ឆ៖** មិនអាចប៉ានបដិសេធទេ ព្រោះថាជំនាន់នោះខ្ញុំចង់និយាយថា មិនអាចបដិសេធអីតែផ្ដេសផ្ដាសបានទេ ព្រោះខ្លាចណាស់ វាគ្រាន់តែគេដកនោះ យើងខ្លាចទៅហើយ ហើយថែមឯណាទៅសួរគេទៀតនោះ ស្រេច។

[១១:១៩:០៩]

**ស៖** ពេលដែលលោកនិយាយថាលោកភ័យខ្លាច។ តើលោកភ័យខ្លាចអំពីអ្វីលោក? តើលោកភ័យខ្លាចថាវាមានអ្វីនឹងកើតឡើងចំពោះលោកពេលនុ៎ង?

**ឆ៖** ការខ្លាចហ្នឹងវាដូចថា ជួនកាលក៏វាចេញមកពីប្រភពអ្នកណាម្នាក់ដែលគេចោទយើងថាខុសនេះខុសនោះ គេអាចយកយើងទៅវ៉ៃចោលក៏មិនដឹង ព្រោះវាអត់ដឹងដែរ។ ដល់ហើយចេះតែភ័យ បាទ។

**ស៖** តើលោកមានបានដឹងថា មានរឿងអ្វីកើតឡើងទៅដល់អ្នកខ្លះទៀតទេ?

**ឆ៖** បាទ វាអាចឮ អាចដឹងខ្លះ តែក៏វាមិនបានឃើញជាក់ស្ដែងខ្លួនយើង ដោយសារថាព្រោះពេលនោះគ្រាន់តែនិយាយខ្សឹបខ្សៀវគ្នាទៅ ជួនកាលថាបាត់អ្នកនេះ បាត់អ្នកនោះ វាក៏មិនដឹងមូលហេតុអីបាទ។

**ស៖** លោកនៅចាំទេថា មានពលករ កម្មករណាបាត់ខ្លួនដោយគ្មានមូលហេតុអីទេ នៅពេលធ្វើការនៅឯការដ្ឋានលើកទំនប់នុ៎ង?

**ឆ៖** ទេ ការដែលបាត់ខ្លួននោះ គឺវាមិនដឹងមូលហេតុ ដោយសារតែ ការពិតពីជំនាន់នោះអ្នកណាក៏មិនប៉ានសួរពីណា បើថាគេយកខ្ញុំទៅបាត់ហើយៗ វាមានប៉ាននិយាយអី មានអីទេ បាទ។

**ស៖** ប្រធានបទមួយនេះ លោកដែលសួរទៅគេថាៗ លោកៗ គេដែលសួរលោកថាពីមុនហ្នឹង លោកធ្លាប់ធ្វើ លោកធ្លាប់បួស ហើយនិងធ្លាប់ធ្វើជាគ្រូបង្រៀនអីដែរទេ?

**ឆ៖** បាទ គេមិនសួរទេ វានោះគេធ្វើប្រវត្តិរូបបាទ។ យើងឆ្លើយត្រង់ មិនត្រង់ អាហ្នឹងនៅលើយើង គេតាមដានយើង។

[១១:២១:៥៣]

**ស៖** តើលោកមានប្រាប់គេតាមត្រង់ទេកាលនុ៎ង ឬក៏លោកលាក់ដើម្បីការពារអាយុជីវិតរបស់លោក?

**ឆ៖** ខ្ញុំលាក់ថា ខ្ញុំរៀននៅវត្ត អត់សូវបានចេះដឹងអី បាទ។ តែគេទៅសួរអ្នកស្រុកដែរ ប៉ុន្តែអ្នកស្រុកថាមិនដឹង វាថ្នាក់ទីប៉ុន្មាន អីទីប៉ុន្មាន ព្រោះគេអត់ដឹងដែរ ស្រុកខ្ញុំនៅជនបទដែរ។

**ស៖** បាទ សូមអរគុណ។ តើគេចាត់តាំងឲ្យលោក រែកដីលេខមួយហ្នឹង អស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ប្រហែលជា បើតាមខ្ញុំគិតប្រហែលជា ប្រាំ ប្រាំមួយខែក្រោយមកហ្នឹងរហូតគេ និយាយរួមគេចាប់ តាវ៉ាល់ ផុតទៅបានខ្ញុំនៅទើរបណ្តោយ បាទ។

**ស៖** លោកដឹងទេ ប្រហែលជាក្នុងជាពេលណាដែលគេចាប់ខ្លួន តាវ៉ាល់?

**ឆ៖** អានោះ គ្រាន់តែប្រហាក់ប្រហែល ប្រហែលជាឆ្នាំ៧៧ ឬក៏ចុងឆ្នាំអី វាភ្លាប់មិនបាន។ មិនមែនចុងឆ្នាំទេ ប្រហែលដើមឆ្នាំនេះឯង។

**ស៖** អ្នកណាជាអ្នកចាប់ខ្លួន តាវ៉ាល់?

**ឆ៖** អត់បានដឹងច្បាស់លាស់ទេ ពីព្រោះការចាប់ហ្នឹង ខ្ញុំអត់បានដឹងដែរ។

**ស៖** លោកដឹងថា គេចាប់គាត់ហ្នឹងពីកន្លែងណាទៅទេ?

**ឆ៖** អត់ដឹង គ្រាន់តែថាគេហៅទៅរៀនទៅ បាត់បណ្តោយទៅ មិនដឹងគេទៅចាប់ឯណាឯណី។

**ស៖** លោកឆ្លើយនៅដើមឆ្នាំ១៩៧៧ នៅពេលពេលដែលគេចាប់ខ្លួន តាវ៉ាល់ ហ្នឹង លោកដឹងថាអ្នកណាជាប្រធានភូមិភាគទេ?

**ឆ៖** កាលនោះនៅ រស់ ញឹម បាទ។

**ស៖** លោកដឹងថាប្រជាជនដែលចាប់ តាវ៉ាល់ មកពីភូមិភាគនិរតី ឬក៏មកពីភូមិភាគណាដែរទេ?

**ឆ៖** ទេ មិនអាចដឹងរឿងកាលនុ៎ង មិនដឹង ព្រោះវាល្ងង់ល្ងា ស្ថានភាពវាចេះតែប្រែប្រួល បាទ

អត់ដឹងអីទេ រឹកវរ។

**ស៖** លោកបានឆ្លើយថាលោករែកដីលេខមួយប្រហែលជាប្រាំខែ។ បន្ទាប់មកទៀត តើលោកធ្វើអ្វី?

**ឆ៖** បាទ បន្ទាប់មកទៀត ពេលគេចាប់ តាវ៉ាល់ ចេញទៅ គេត្រូវដូរៗអ្នកដែលមកពីនិរតីទៅ គេឲ្យខ្ញុំទៅនៅបើកអង្គរ បាទ។

**ស៖** តើអ្នកណាជំនួសការងារ តាវ៉ាល់ នៅពេលដែលគេចាប់គាត់ទៅ?

**ឆ៖** ពេលដែលគេចាប់គាត់ទៅ ក្រោយមកមាន កាលនុំងដូចមាន តាផេង បាទ តាផេង គណៈស្រុកភ្នំស្រុក។

[១១:២៦:៥៣]

**ស៖** នៅពេលដែលលោកធ្វើជាជំនួយការឲ្យ តាវ៉ាល់ លោកដឹងទេ តើមានមនុស្សប៉ុន្មាននាក់ស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់គាត់?

**ឆ៖** ខ្ញុំកាលនុំង គិតទាំងចល័តទាំងអស់ អង្គាល់ តាវ៉ាល់ នៅ ប្រហែល៨០០០។

**ស៖** លោកអាចជម្រាបអង្គជំនុំជម្រះបានទេ ហេង ដែលមក -- ផេង ដែលមកជំនួស តាវ៉ាល់ នេះ គាត់មកពីខាងណាដែរ?

**ឆ៖** នោះ គាត់មកពី គេយកមកពីគណៈស្រុកភ្នំស្រុក បាទ អនុស្រុកហ្នឹងកាលនោះ បាទ។

**ស៖** ដូច្នេះគាត់ក៏មកពីភូមិភាគពាយ័ព្យដែរ។ ត្រឹមត្រូវដែរឬអត់ទេ?

**ឆ៖** បាទៗ ពាយ័ព្យ បាទ។

**ស៖** ការងារដែលលោកចែកអង្ករ បើកអង្ករឲ្យគេ តើលោករាយការណ៍ទៅអ្នកណា?

**ឆ៖** បាទ អង្គាល់ពីជំនាន់ខ្ញុំ រាយការណ៍ទៅឲ្យឈ្មោះ បងយន់។ បងយន់ នោះ គាត់អ្នកទទួលចល័តបន្តពី តាផេង ទៀត។

**ស៖** តើត្រឹមត្រូវដែរទេដែលថា កងចល័តនេះគឺជាកងចល័តសម្រាប់តំបន់៥? ត្រឹមត្រូវទេលោក?

**ឆ៖** បាទ ត្រឹមត្រូវហើយ ព្រោះចល័ត គឺជាចល័តរបស់តំបន់៥ បាទ។

[១១:២៨:០៧]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន តើគួរដល់ពេលសម្រាកសិន ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកតំណាងសហព្រះរាជអាជ្ញា។

ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ ឈប់នៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់ដល់កន្លែងសក្ខីកម្មក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះរសៀលនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង១១:៣០ នាទី ដល់ម៉ោង១៣:២៨ នាទី)*

[១៣:២៨:៥៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធី។ ពេលនេះអង្គជំនុំជម្រះប្រកាសសេចក្តីសម្រេចផ្ទាល់មាត់ទៅលើសំណើរបស់ នួន ជា សុំឲ្យទទួលយកភស្តុតាងថ្មី អនុលោមតាមវិធាន៨៧ អនុវិធាន៤ នៃវិធានផ្ទៃក្នុង។ ឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា សុំឲ្យអង្គជំនុំជម្រះទទួលយកភស្តុតាងថ្មីដែលជាច្បាប់ចម្លងពណ៌ធម្មជាតិនៃរូបភាពក្រដាសប្រាក់របស់ធនាគារកម្ពុជាជាច្រើនសន្លឹកនោះ អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារនេះត្រូវបានប្រើប្រាស់នៅក្នុងពេលជំនុំជម្រះកាលពីថ្ងៃម្សិលមិញគឺថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ រួចហើយ ដោយពុំមានការជំទាស់តវ៉ាឡើយ។ រូបភាពទាំងនេះគឺជារូបភាពនៃក្រដាសប្រាក់ពណ៌ធម្មជាតិដែលសំណៅរូបភាពពណ៌សនិងខ្មៅរបស់វាមាននៅក្នុងសំណុំរឿងរួចហើយ ឯកសារ E3/4535 នៅត្រង់លេខ ERN 00685868 ដល់ 00685869, 00685827, និង 00685772។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះឯកភាពតាមសំណើសុំរបស់មេធាវីការពារក្តីលោក នួន ជា។

ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសូមរំឭកដល់ភាគីទាំងអស់ថា ប្រសិនបើមានភាគី បើភាគីមានបំណងប្រើប្រាស់ឯកសារណាមួយនៅក្នុងអំឡុងពេលជំនុំជម្រះ ហើយដែលឯកសារនោះ មិនមាននៅក្នុងសំណុំរឿងទេនោះ ភាគីត្រូវតែធ្វើការស្នើសុំជាមុនក្នុងពេលវេលាសមស្រប មិនមែននៅ នាទីចុងក្រោយនៃការជំនុំជម្រះនេះទេ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាមានសំណួរបន្តចំពោះសាក្សី។

[១៣:៣១:២៧]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សីនៅពេលដែលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម តើលោកមានបានដឹង អំពីដំណើរទស្សនកិច្ច ឬការចុះទៅពិនិត្យណាមួយពីកម្មាភិបាលពីភ្នំពេញទេ?

**លោក ឈិត យឿក៖**

**ឆ៖** បាទ ខ្ញុំមិនសូវបានដឹងដោយសារថា ពេលនោះខ្ញុំកំពុងតែធ្វើការដែរទៅ វាអត់បានដឹងថា គេទៅទំនប់ទៅអី បាទ។

**ស៖** ព្រឹកមិញមុនពេលយើងឈប់សម្រាក លោកបានពន្យល់ថា ក្រោយពីលោកត្រូវបានគេដក ចេញពីរែកដី គេយកលោកទៅឲ្យចែកអង្ករ។ តើលោកចែកអង្ករទៅឯណាដែរ? ទៅខាងកងចល័ត ឬក៏ ទៅខាងចែកអង្ករទៅខាងស្រុក ឬទៅខាងណា?

**ឆ៖** បាទ អង្ករនោះ គឺចែកនៅក្នុងចល័តតំបន់បាទ។

**ស៖** ពេលលោកនិយាយថាចែកចាយនៅក្នុងរង្វង់គណៈកម្មាធិកាតំបន់ហ្នឹង ខ្ញុំមិនសូវជាយល់ ទេ។ មានន័យថា លោកចែកអង្ករហ្នឹងទៅឲ្យប្រជាជនទូទាំងតំបន់៥ តែម្តង ឬក៏ចែកឲ្យតែគណៈ កម្មាធិកាតំបន់៥ទេ?

**ឆ៖** បាទ នោះនិយាយរួមទៅចល័ត បាទ ចល័តតំបន់។ អត់មានចែកទៅប្រជាជនទូទាំងតំបន់ អត់ទេ តែចល័តទេ។

[១៣:៣៣:៤៥]

**ស៖** តើប្រជាជនប៉ុន្មាននាក់ដែលបានទទួលអង្ករពីលោក?

**ឆ៖** ប្រជាជនបើតាមគិតខ្ញុំនៅចាំបានប្រហែលជាជាង ២០.០០០នាក់ ចល័ត។

**ស៖** លោកទទួលបានអង្ករមកពីណា?

**ឆ៖** អង្ករនោះ កាលដែលគេចាត់តាំងឱ្យទៅធ្វើ គេឱ្យទៅយកស្រូវតាមសហករណ៍បាទ តាមស្រុកយកមកកិន ហើយយកមកបើកឱ្យចល័តបាទ។

**ស៖** ដូច្នេះលោកទទួលបានអង្ករពីសហករណ៍ដោយសារសហករណ៍ជាកន្លែងដែលដាំស្ទូងស្រូវ ហើយបន្ទាប់មកលោកចែកទៅតាមឃ្លាំងផ្សេងៗ ចែកទៅឱ្យកម្លាំងប្រហែលជារាប់ពាន់នាក់។ អ៊ីចឹងមែនទេលោក?

**ឆ៖** បាទ ត្រូវហើយ។

**ស៖** ខ្ញុំកំពុងតែធ្វើការប៉ាន់ប្រមាណ។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាត្រង់ ERN 00728822 ជាភាសាខ្មែរ, បារាំង 0112331-- អង់គ្លេស 0071179។ លោកថាលោកចែកទៅឱ្យកម្មករជាច្រើន។ តើកម្លាំងដែលលោកចែកអង្ករទៅឱ្យហ្នឹងប៉ុន្មាន ២.០០០, ៣.០០០ ឬក៏ប៉ុន្មានពាន់នាក់?

**ឆ៖** បាទ អង្កាល់ដែលគេប្រជុំថា ផែនការគេមានមកគឺចល័ត ២០.០០០នាក់ជាងដែលត្រូវចែកអង្ករឱ្យ។

[១៣:៣៦:២៧]

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកចែកអង្ករ តើលោកចែកទៅឱ្យអ្នកណា? លោកចែកឱ្យម្នាក់ៗ ឬក៏ចែកឱ្យទៅមេដឹកនាំតាមផ្នែកៗ?

**ឆ៖** អង្ករចែកឱ្យទៅតាម -- ព្រោះចល័តដែលយកមកក្នុងតំបន់នេះបានមកពីស្រុក។ ហេតុនេះមានអ្នកតំណាងគេមកយកអង្ករទៅចែកនៅតាមចល័ត តាមកងគេបាទ។

**ស៖** លោកនឹកឃើញទេថា អង្ករហ្នឹងរក្សាទុកដោយរបៀបណា ច្រកស្បោង ច្រកបាវទុក ឬក៏យ៉ាងម៉េចមុនពេលដែលលោកចែកចាយទៅឱ្យអ្នកទាំងនោះ?

**ឆ៖** អង្ករច្រកជាបាវៗ ហើយយកមកស្តុកទុកបានចែក។

**ស៖** តើលោកចែកអង្ករហ្នឹងរាល់ថ្ងៃ ឬក៏រាល់អាទិត្យ?

**ឆ៖** ចែកអង្ករនោះ អង្កាល់ដែលគេវ៉ៃសម្រុកចែក ជួនកាលបីថ្ងៃ មិនដែលដល់មួយអាទិត្យទេ។

**ស៖** ខ្ញុំដឹង លោកប្រើពាក្យថា “វាយសម្រុក” វាជាពាក្យទ័ព នៅពេលនុំង តើវាមានន័យថាម៉េច

ពេលដែលលោកប្រើពាក្យថា “វាយសម្រុក” ហ្នឹង?

**ឆ៖** “វាយសម្រុក” ហ្នឹងបានន័យថា ពេលដែលសម្រុកហ្នឹងគឺប្រឹងខំធ្វើម៉េចឲ្យរួច ដូចផែនការអីមួយណា ត្រូវតែធ្វើឲ្យរួច ម៉្លោះហើយសម្រុក។

[១៣:៣៨:៥១]

**ស៖** តើអង្ករប្រហែលជាប៉ុន្មានបាវលោកចែកក្នុងមួយថ្ងៃ?

**ឆ៖** ក្នុងមួយថ្ងៃ អង្ករយើងចែកទៅតាមចំនួនដែលកម្លាំងដែលមកបើកហ្នឹង ឧបមាថាមួយបាវវាមាន ៤០០កំប៉ុង តែបើម្នាក់បីកំប៉ុង គិតទៅតាមនោះទៅ ជួនកាលទៅវាអស់ជិតទៅ ៣០បាវ អាហ្នឹងបានទូទាត់ទៅបានដឹងបាទ។

**ស៖** សូមអរគុណ។ បើសិនណាជាលោកអាចនឹកឃើញនាពេលនេះ លោកនឹកឃើញទេ តើក្នុងមួយថ្ងៃ ឬក៏ក្នុងមួយខែ លោកចែកអស់ប៉ុន្មានបាវ?

**ឆ៖** វាបើតាមខ្ញុំគិត ដូចថាម្នាក់បីកំប៉ុងអ៊ីចឹង ជួនកាលអស់៣០បាវ តែមួយកន្លែងចល័តបាទ។

**ស៖** អ៊ីចឹងមានន័យថា ក្នុងមួយថ្ងៃលោកចែកអង្ករអស់៣០បាវ ចេញពីឃ្លាំងរបស់លោក។ បើសរុបទាំងអស់ គឺ៣០បាវចែកទៅតាមបណ្ដាស្រុកផ្សេងៗ។ ខ្ញុំស្ដាប់ទៅឮថាអ៊ីចឹង។ តើត្រឹមត្រូវ ឬក៏អត់ទេ? ជួនកាលស្រុកខ្លះអាចទទួលបាន១០បាវ ឬក៏អ៊ីចឹង? លោកមានន័យថាអ៊ីចឹង ឬយ៉ាងម៉េច?

**ឆ៖** បាទ អានោះទៅតាមកម្លាំងរបស់ស្រុក ដូចថាស្រុកណាមានកម្លាំងប៉ុនណា គឺបានប៉ុណ្ណោះប៉ុន្ដែចែក ជួនកាលថ្ងៃនេះចែកឲ្យស្រុកនេះ ថ្ងៃណោះ ចែកស្រុកនេះ ផ្លាស់ប្ដូរគ្នាដែរបាទ។

[១៣:៤១:២២]

**ស៖** អង្ករមួយកំប៉ុង តើមួយកំប៉ុងហ្នឹង បើយើងគិតជាគីឡូ វាស្មើនឹងប៉ុន្មានភាគនៃគីឡូក្រាមហ្នឹង?

**ឆ៖** វាមួយគីឡូ បួកកំប៉ុង តែបើមួយកំប៉ុង អានោះគិតទាំងអស់គ្នាមើល៍ ព្រោះខ្ញុំ ខ្លាចខ្ញុំគិតវាមិនទាន់។ ចែកជាបួនមើល៍ ព្រោះខ្ញុំចែកវាមិនទាន់ ខ្ញុំមិនមានអីចែក។

**ស៖** ដូច្នេះមានន័យថា ក្នុងមួយកំប៉ុងវាស្មើនឹងមួយភាគបួនគីឡូក្រាម។ លោកនិយាយហ្នឹងលោកនិយាយពីកំប៉ុងហ្នឹង កំប៉ុងទឹកដោះគោយើងហ្នឹង?

**ឆ៖** បាទ កំប៉ុងទឹកដោះគោ។

**ស៖** អ៊ីចឹងមានន័យថាក្នុង១០០គីឡូក្រាម គឺក្នុង១០០គីឡូក្រាម គឺវាស្មើនឹង៤០០កំប៉ុងហើយ

អ៊ីចឹង អ៊ីចឹងមួយបាវហ្នឹងៗ មួយបាវចំណុះ១០០គីឡូក្រាមហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ មួយបាវ ១០០គីឡូ។

**ស៖** បាទ សូមអរគុណ។ តើមានអ្វីកើតឡើង បើសិនណាគេ ប្រជាជនគាត់បំពេញការងារមិនបានតាមតម្រូវការកំណត់ហ្នឹង តើរបបអាហារហ្នឹងវាត្រូវកាត់បន្ថយ ឬក៏យ៉ាងម៉េចដែរ ទទួលបានយ៉ាងម៉េចបានដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយ! សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ដោយសារជាប្រភេទសំណួរឧបមាណវិធី។ បាទ សូមអរគុណ។

[១៣:៤៣:០១]

**លោក នីកូឡាស គូមជែន៖**

សាក្សីរូបនេះ គាត់ធ្វើការនៅការដ្ឋានលើកទំនប់នោះ ខ្ញុំសួរគាត់តាមរយៈបទពិសោធន៍របស់គាត់ផ្ទាល់។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** នៅពេលអ្នកណាម្នាក់ធ្វើការមិនបានគ្រប់ផែនការ តើគាត់ទទួលបានរបបអាហារយ៉ាងម៉េចដែរ? នេះសំណួរខ្ញុំសួរទៅតាមបទពិសោធន៍ផ្ទាល់របស់គាត់នៅការដ្ឋាននោះ?

**លោក ឈិត យឿក៖**

**ឆ៖** វាអ៊ីចេះ អាបញ្ហានោះ បញ្ហាដែលធ្វើបាន មិនបាននោះ អានោះនៅលើតាមកង តាមក្រុមគេទេ ព្រោះខ្ញុំដឹងថាតែដល់ថ្ងៃបើក មកបើកបាទ ព្រោះអានោះនៅតាមគេនោះ ព្រោះរួចមិនរួច ឬក៏បានមិនបាន ព្រោះខាងអ្នកបើកអង្ករ អត់មានទាក់ទងអីទៅគិតរឿងនេះទេបាទ។

**ស៖** នៅពេលលោកធ្វើការនៅកងចល័តតំបន់ តើលោកមានទំនាក់ទំនង -- ពេលដែលលោកចែកអង្ករ (សូមទោស) ធ្វើការចែកអង្ករសម្រាប់កងចល័តចម្រុះតំបន់នោះ តើលោកមានទំនាក់ទំនងជាមួយលេខាតំបន់ដែរទេ?

**ឆ៖** នៅពេលនោះ ជួនកាល តំបន់គាត់ចុះមកផ្ទាល់តែម្តង មកមើលអង្ករនៅឃ្លាំង។ ជួនកាល

គាត់ឲ្យអ្នកផ្សេងមកមើល។ ឧបមាថាដូចថា ក្នុងមួយខែ យើងហូបអស់៣០០០បាវ តែបើដឹកមក ៦០០០នោះ វាសល់ប៉ុន្មាន។ បាទ មកមើលអារឿងសល់ ឬក៏វាអស់ម៉េច។

**ស៖** តើអ្នកណាជាមេដឹកនាំតំបន់ ជាប្រធានតំបន់ ពេលដែលលោកទទួលនាទីជាអ្នកចែកចាយអង្ករ?

**ឆ៖** ឈ្មោះ បងរិន – ឈ្មោះ បងរិន បាទ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ រិន នេះ មកពីណាដែរ?

**ឆ៖** បងរិន មកពីភូមិភាគនិរតី បាទ។

**ស៖** លោកនៅនឹកឃើញភូមិ ឃុំ ស្រុក ខេត្ត គាត់មកពីកន្លែងណាជាក់លាក់ទេ?

**ឆ៖** បាទ មិនដឹងទេ ដឹងតែភូមិភាគ ព្រោះជំនាន់នោះ លំបាកដេញដោលគេពេក។ ឥឡូវ វាដឹងតែភូមិភាគនិរតី – និរតី បាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំមិនចង់ឲ្យលោកឆ្លើយស្មានទេ។ សូមឲ្យលោកប្រាប់លម្អិតបន្តិចមក អំពីឈ្មោះ រិន នេះ។ ក្នុងឋានៈគាត់ជាប្រធានតំបន់ តើគាត់មានចរិតលក្ខណៈបែបណាដែរ សូមលោករៀបរាប់លម្អិតបន្តិចបានទេ?

[១៣:៤៧:៥១]

**ឆ៖** តែអានេះ ដែលខ្ញុំផ្ទាល់នៅឃើញច្បាស់ ព្រោះគាត់នេះ អត្តចរិតគាត់ តែទៅដល់ គឺគាត់ចាប់បង្កី ចាប់ដងរែកចប ទៅកាប់ដីបណ្ដោយ។ មិនដឹងជាបញ្ហាអី ព្រោះគាត់ទៅកាប់ដីអឹចុះតែម្ដង។

**ស៖** តើគាត់ធ្វើការជាមួយអ្នកដទៃ ដូចគេដូចឯងអ៊ីចឹង លោកចង់និយាយថាអ៊ីចឹង ឬយ៉ាងម៉េច?

**ឆ៖** បាទ គាត់ចូលទៅរែកដុំចល័ត ជួនកាលចល័តអត់ស្គាល់ទៀត។ ព្រោះស្លៀកពាក់សាមញ្ញដូចតែគ្នា។

**ស៖** ចុះមានអ្វីកើតឡើងចំពោះ រិន នេះដែរ លោកដឹងទេ?

**ឆ៖** នែ៎ ពេលក្រោយមក ក៏ស្រាប់គេផ្លាស់ប្ដូរគាត់ទៅ ប៉ុន្តែមិនដឹងគាត់ផ្លាស់ទៅខាងណា។

**ស៖** សូមអរគុណលោកសាក្សី។ លោកចៅក្រម មានឯកសារពីរពាក់ព័ន្ធទៅនឹងជោគវាសនារបស់ឈ្មោះ រិន នេះ គឺឯកសារ E3/2254។ ហើយERN ភាសាខ្មែរ 0086766, បារាំង 00834852 ហើយអង់គ្លេស 00789707។ មានបញ្ជាក់នៅលើបញ្ជីឈ្មោះអ្នកទោស ស-២១ គឺបញ្ជាក់ថា សូមដកស្រង់ គឺក្នុងឆ្នាំ១៩៧៨ សរសេរថា "បញ្ចប់ហើយ" គឺឯកសារ E3/--

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន អ្នកបកតាមអត់ទាន់លេខ ERN លឿនពេក។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញា សូមលោកអានលេខ ERN បានយឺតៗ ដើម្បីឱ្យអ្នកបកប្រែស្តាប់បាន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** អ៊ីចឹងតើខ្ញុំគួរ -- បាទ ម្តងទៀតសម្រាប់ឯកសារ E3/2254, ERN គឺ00 -- ជាភាសាខ្មែរ 0086766, ជាភាសាបារាំង 00834853, ERN អង់គ្លេស 00789707។ ឯកសារមួយទៀតគឺចម្លើយសារភាពរបស់ រិន គឺឯកសារ E3/7403។ លោកសាក្សី លោកដែលធ្លាប់ឮថា រិន ត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរសន្តិសុខស-២១ ដែរទេ?

**លោក ឈិត យឿក៖**

**ឆ៖** ទេ បើតាមខ្ញុំដូចជាមិនដឹង។ មិនដឹងថាគេផ្លាស់ ឬក៏គេធ្វើយ៉ាងម៉េច?

[១៣:៥២:១៥]

**ស៖** លោកដឹងទេថាអ្នកណាមកជំនួសឈ្មោះ រិន?

**ឆ៖** ក្រោយមកមានតែ ឮថាខាងយាយចែម គាត់ជាគណៈតំបន់បណ្តោះអាសន្នជំនួសបងរិន។

**ស៖** ខ្ញុំសូមសួរឱ្យច្បាស់បន្តិច។ យាយចែម នេះជាមនុស្សតែមួយដែលមានឈ្មោះពេញថា អ៊ឹម ចែម ជាមនុស្សដែលមកពីនិរតីហ្នឹង ឬក៏មិនមែនទេ?

**ឆ៖** បាទ គាត់មកពីភាគនិរតី។

**ស៖** លោកដឹងថា អ្នកណាជាប្រធានតំបន់មុន រិន នេះ គឺជាប្រធានតំបន់មុន រិន ភ្លាមៗនោះ?

**ឆ៖** មុន បងរិន ភ្លាមៗ តែអង្គាល់ដែលគេចាប់ តាហ៊ីង្ស វាមាន តាជាល។ ជាល ហ្នឹងបណ្តោះអាសន្ន មិនដឹងម៉េចបានជាស្រាប់ក្រោយមកបានដល់ឈ្មោះ រិន។

**ស៖** តើ ជាល នេះជាកូនប្រុសរបស់ រស់ ញឹម ឬមិនមែនទេ?

**ឆ៖** ទេ អានេះខ្ញុំមិនដឹងតាមរយៈឮគេដែរ ថាជាកូនប្រុសរបស់ រស់ ញឹម បាទ។

**ស៖** តើលោកនៅនឹកឃើញទេ នៅពេលដែល រិន ក្លាយទៅជាប្រធានតំបន់ ហើយក្រោយមកគាត់បាត់ខ្លួន។ តើលោកអាចនឹកឃើញអំពីពេលវេលាដែលគាត់ឡើងកាន់តំណែងជាប្រធានតំបន់ និងបាត់ខ្លួនមានរយៈពេលប៉ុន្មានដែរ ចន្លោះនុំង?

**ធ៖** ទេ ចន្លោះនុំងប្រហែលជាដើមឆ្នាំ៧៧ មកពាក់បណ្ដាលឆ្នាំ ប៉ុន្តែអាប្រឡោះហ្នឹង មិនដឹងខែណាអីណា វាអត់ចាំផង។

[១៣:៥៥:០០]

**ស៖** ស្ដាប់ដូចជាមិនច្បាស់កាលបរិច្ឆេទហ្នឹង ប្រហែលជាដោយសារខ្ញុំសួរមិនច្បាស់ក៏មិនដឹង ខ្ញុំសួរពីរសំណួរក្នុងពេលតែមួយក៏ថាបាន។ ឥឡូវខ្ញុំសួរអ៊ីចេះវិញ តើនៅពេលណា រិន បាត់ខ្លួន ពីប្រធានតំបន់? លោកអាចនឹកមើលថាតើវាមានរយៈពេលប៉ុន្មានមុនពេលកងទ័ពវៀតណាមចូលមកដល់ មានរយៈពេលប៉ុន្មានខែ? ប៉ុន្មានឆ្នាំ?

**ធ៖** ឥឡូវខ្ញុំនឹកហើយ ប្រហែលដើមឆ្នាំ៧៨ បាទ។

**ស៖** បាទ សូមអរគុណ។ លោកនឹកឃើញទេតើ រិន នេះ ធ្លាប់ធ្វើជាប្រធានតំបន់បានរយៈពេលប៉ុន្មានដែរ?

**ធ៖** ដែលគាត់មកធ្វើគណៈតំបន់នៅតំបន់៥ មិនបានយូរប៉ុន្មាន បើតាមខ្ញុំគិតប្រហែលជា បើលើសពីមួយឆ្នាំតិចតួច ឬក៏មួយឆ្នាំ មិនបានមួយឆ្នាំផងមិនដឹង។ វាមិនបានគិតដែរកាលនុំង។

**ស៖** លោកសាក្សី ពីខាងដើមនេះលោកនិយាយអំពីឈ្មោះ ម៉ោង ដែលមកជំនួសឈ្មោះ រិន នៅឯស្រុកព្រះនេត្រព្រះ។ លោកដឹងទេតើមានអ្វីកើតឡើងចំពោះឈ្មោះ ម៉ោង នេះ?

**ធ៖** ម៉ោង គេចាប់ហ្នឹង។ បាត់ខ្លួនគេចាប់ទៅបណ្ដោយ។

**ស៖** លោកនឹកឃើញទេ គេចាប់ខ្លួនគាត់នៅក្នុងឆ្នាំណាដែរ?

**ធ៖** ទេ ពិបាកដែរ ប្រហែលជាឆ្នាំ នៅឆ្នាំ៧៧នេះ ឬក៏ដើមឆ្នាំ៧៧ ឬយ៉ាងម៉េចទេ វាភ្លេចដែរខ្ញុំ។

**ស៖** សូមអរគុណ។ ចុះអនុប្រធានរបស់គាត់ លោកនឹកឃើញទេ? នឹកឃើញឈ្មោះអីទេ? ហើយតើគាត់ត្រូវបានគេចាប់ខ្លួនដែរ ឬក៏អត់ទេ?

**ធ៖** អនុប្រធាន តាម៉ោង ក៏គេចាប់ដែរ ឈ្មោះ សំ អាត។

**ស៖** ឈ្មោះ សំ អាត អ៊ីចឹងលោក?

**ធ៖** ឈ្មោះ អាត នេះឯងបាទ។

**ស៖** មុនពេល ជាល ឡើងធ្វើជាប្រធានតំបន់ តើអ្នកណាជាប្រធានតំបន់មុន ជាល?

**ធ៖** តាហ៊ីង្ស ឈ្មោះ ហ៊ីង្ស។

**ស៖** តើមានអ្វីកើតឡើងចំពោះ តាហ៊ីង្ស?

**ឆ៖** ព្រោះខ្ញុំក៏មិនដឹងស្ថានភាព ឬក៏បញ្ហាអ្វីដែលខ្ញុំត្រូវដឹង ប៉ុន្តែយើងចេះតែឮថាវាបាត់ខ្លួនគេចាប់ដែរ។

**លោក គង់ សំអុន៖**

លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

[១៣:៥៩:០៩]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាមេត្តាផ្ទៀងផ្ទាត់ទៅលើឯកសារ E3/2254 ដែលលោកបានបង្ហាញមិញ ទាក់ទងនឹងឈ្មោះ រិន នេះ។ ខ្ញុំពិនិត្យមើលទៅវាអត់មានឃើញឈ្មោះនេះនៅក្នុងឯកសារនេះទេ។ អ៊ីចឹងសូមឲ្យលោកជួយបញ្ជាក់។ បាទសូមអរគុណ។

**លោក នីកូឡាស គូមជែន៖**

បាទ នៅត្រង់ ជាភាសាខ្មែរនៅត្រង់ទំព័រនៅផ្នែកខាងលើបំផុតនៃទំព័រ១ ខ្ញុំបានអានលេខERN រួចហើយ គឺ 00686766, ឈ្មោះគាត់គឺនៅលើគេបង្អស់នៅត្រង់ទំព័រនេះ។

**លោក គង់ សំអុន៖**

បាទ លោកប្រធាន ខ្ញុំពិនិត្យមើលទៅលើទីតាំងដែលសហព្រះរាជអាជ្ញាបានបញ្ជាក់ហ្នឹងគឺមានឈ្មោះថា រ៉ុន ឬក៏ រ៉ុន ខ្ញុំមើលមិនសូវច្បាស់ដែរ ប៉ុន្តែមិនមែនឈ្មោះ រិន ទេ។

**លោក នីកូឡាស គូមជែន៖**

លោកចៅក្រម ខ្ញុំអានឈ្មោះ រិន ជាលេខាតំបន់៥។ បាទ ឃើញមាននៅត្រង់បន្ទាត់មួយនេះ ដូច្នេះ សូមមេត្តាអានមើល ផ្ទៀងផ្ទាត់មើល។

**លោក ពេជ អង្គ៖**

បាទ ខ្ញុំសុំបញ្ជាក់នៅក្នុងឯកសារដូចលោកសហព្រះរាជអាជ្ញាអន្តរជាតិបានលើកហ្នឹងគឺនៅក្នុងទំព័រ៤ ឈ្មោះ ហេង រិន នៅបន្ទាត់លើគេដែលមានការឆូតចោលទី១។ បាទ សូមអរគុណ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណលោកសាក្សី។ លោកអាចរៀបរាប់ទេថា តើមានរឿងអ្វីកើតឡើងនៅស្រុក

ព្រះនេត្រព្រះនៅតំបន់៥? ហើយយើងនឹងពិនិត្យមើលឈ្មោះមួយចំនួន។ តើលោកអាចជម្រាបតុលាការបានដែរទេគឺលោកបាននិយាយអំពីការបាត់ខ្លួនមនុស្សមួយចំនួន? តើមានគម្រោង ឬក៏ជាដំណាក់កាលអ្វីដែលលោកបានដឹងបានឃើញពីហេតុការណ៍ដែលកើតឡើងកាលនោះ?

**លោក ឈិត យឿក៖**

**ឆ៖** ទេ ខ្ញុំវាអាចដឹងថា អ្នកដែលបាត់ខ្លួនហ្នឹងគឺបើតាមឃុំតាមភូមិអីផ្សេងទៀត ខ្ញុំក្តាប់មិនសូវបានទេ ប៉ុន្តែខ្ញុំដឹងថាស្រុកព្រះនេត្រព្រះ ដូចតាម៉ោង ដូចតាវ៉ាល់ ដូចតាសំអាត នោះប្រហែលជាខ្ញុំ, ដូចតាឆាល –ឈ្មោះឆាល– ក្នុងកន្សោមស្រុកព្រះនេត្រព្រះ ខ្ញុំក្តាប់បានថា វាបាត់ខ្លួនបាទ។

**ស៖** តើមានអ្នកមកពីខាងក្រៅភូមិភាគចូលមកតំបន់៥ ដែរឬទេនៅពេលដែលលោកនៅទីនោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** មានខាងភូមិភាគនិរតីដែរមកបាទ។

**ស៖** តើមានអ្វីកើតឡើងទាក់ទងទៅនឹងការចាប់ខ្លួន ហើយនិងការបាត់ខ្លួន នៅពេលដែលពួកនិរតីមកដល់ តើការបាត់ខ្លួន និងការចាប់ខ្លួននោះបានឈប់ ឬក៏បានកើតឡើង ឬយ៉ាងដូចម្តេច? សូមលោកជម្រាបតុលាការផង?

**ឆ៖** ការបាត់ខ្លួននោះ បើតាមខ្ញុំគិត វាពីមុនភាគនិរតីមកក៏ឮថាមានបាត់នេះបាត់នោះ បាត់អ្នកនេះ អ្នកនោះដែរ ប៉ុន្តែយើងវាមិនដឹង តែដល់ភាគនិរតីមកក៏នៅតែមានបន្តបាទ។

**ស៖** សូមអរគុណ។ ចុះមានឈ្មោះ តាហាត់ មកពីថ្មពួក តើលោកស្គាល់ឈ្មោះនេះដែរឬទេ?

**ឆ៖** តាហាត់ មិនមែនថ្មពួកទេ ភ្នំស្រុកអ្រេះ! មើលឲ្យស្រួលមើល។ ដូចភ្នំស្រុក? ចៅហ្វាយស្រុកភ្នំស្រុក ឬក៏ដាក់ច្រឡំយ៉ាងម៉េច ខ្ញុំអត់ដឹងដែរ។

[១៤:០៤:៤២]

**ស៖** បាទ ខ្ញុំច្រឡំ ខ្ញុំល្មៀង។ តើលោកអាចពន្យល់ពីហេតុការណ៍ដែលកើតឡើងចំពោះគាត់ទេ? និយាយពី តាហាត់ នេះ?

**ឆ៖** និយាយពីរឿងហេតុការណ៍អីផ្សេងៗពីបញ្ហាដែលគេត្រូវចាប់ខ្លួន ត្រូវអី ពួកខ្ញុំមិនដឹងទេ ប៉ុន្តែដឹងថាមនុស្សបាត់ – ដឹងថាមនុស្សបាត់ ចេះតែថាគេចាប់ទៅ ទាំងអស់តែគ្នាហ្នឹង។

**ស៖** ខ្ញុំមានឈ្មោះទៀតដូចឈ្មោះ តាផេង ដែលថាមកពីភ្នំស្រុក។ ខ្ញុំអាចច្រឡំចម្លើយលោកពីដើមរបស់លោក តើលោកស្គាល់ តាផេង ដែលមកពីភ្នំស្រុកទេ?

**ឆ៖** បាទ ខ្ញុំស្គាល់ តាផេង នោះក៏គេចាប់ដែរ ភ្នំស្រុកហ្នឹង។

**ស៖** បាទ មាន -- ខ្ញុំនឹងអាចជូនលោកស្ដាប់ គឺដកស្រង់ពីសៀវភៅគឺ E3/1595, សៀវភៅ ប៊ិន ឃៀរនិន, ERN ជាភាសាខ្មែរ 00637738, ជាភាសាបារាំង ERN 00639009 ហើយជាភាសាអង់គ្លេស 00678616។ នៅក្នុងសៀវភៅនេះ អ្នកនិពន្ធបានសរសេរថា សូមលោកស្ដាប់ដោយប្រុងប្រយ័ត្ន៖ "នៅក្នុងស្រុកព្រះនេត្រព្រះប្រជាជនមូលដ្ឋានក៏រងទុក្ខអំពីការគ្រប់គ្រងរបស់និរតីដែរ។ ហើយគេបាននិយាយថា គេនិយាយថាគេមានពួកពាយ័ព្យនោះគឺអាចជាកូនៗ ប៉ុន្តែពួកនិរតីបានសម្លាប់ពួកពាយ័ព្យទាំងនោះ ទាំងកសិករផងដែរ ហើយក៏គេបង្កើតនូវសង្គមថ្មី រវាងអ្នកថ្មី ហើយនិងមូលដ្ឋាន។ ហើយកសិករមូលដ្ឋានក៏យល់ស្រប សារុន ដែលធ្វើការនៅថ្នាក់ស្រុកបានដឹងអំពីថា ការមកដល់នៃកម្មាភិបាលប្រុស ស្រីមកពីនិរតីនៅដើមឆ្នាំ១៩៧៧។ ពួកគេម៉ឺងម៉ាត់ណាស់ តឹងតែងណាស់ ហើយគេបានចាប់ផ្ដើមការចាប់ខ្លួន ហើយនិងការកាប់សម្លាប់ទ្រង់ទ្រាយធំ។ អ្នកណាម្នាក់ដែលមានទំនាក់ទំនងជាមួយរបបលន់ នល់ ក៏បានបាត់ខ្លួន ដោយរាប់ទាំងអតីតប្រធានភូមិ គ្រូបង្រៀន ហើយនិងមនុស្សដែលជាអតីតទាហាន លន់ នល់ ទោះបីជាធ្វើទាហានមួយថ្ងៃក៏ត្រូវបាត់ខ្លួនដែរ។ មិត្តភក្តិរបស់ សារុន នៅក្នុងភូមិក៏ត្រូវបានគេចាប់ខ្លួន ហើយសម្លាប់ចោលដែរ។" សំណួរ តើលោកបានឆ្លងកាត់ ឬមានបទពិសោធន៍អ្វីដូចដែលខ្ញុំរៀបរាប់ទេ នៅពេលដែលកម្មាភិបាលនិរតីមកដល់ តើលោកបានឃើញពួកគេថាតើពួកគេបានប្រឹងប្រែងស្វែងរកអតីតអ្នកធ្វើការឲ្យរបប លន់ នល់ ឬក៏ទាហាន លន់ នល់ អីដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវី កូប៉េ!

[១៤:០៩:០៤]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនមានជំទាស់ទេ គឺថា ប៉ុន្តែមានមូលហេតុមួយចំនួន គឺជាបឋម គឺថាមួយ គឺជាសំណួរនាំមុខ ហើយមិនទាន់មានការសួរសំណួរទៅសាក្សីនេះទេ ដែលទាក់ទងទៅនឹងជោគវាសនារបស់ទាហាន លន់ នល់ ទេ។ ហើយដូច្នេះ ខ្ញុំគិតថា ហើយត្រូវគោរពទៅតាមបទដ្ឋានស្តង់ដារ គឺត្រូវសួរសំណួរបើកជាមុន ហើយប្រសិនបើអាចគាត់មិនដឹង គឺអាចនឹងដកស្រង់សេចក្តីដកស្រង់តាមសៀវភៅ។ ហើយខ្ញុំក៏ជំទាស់ចំពោះការដកស្រង់នេះដែរ គឺថាយើងមិនដឹងប្រភពដែលផ្តល់ព័ត៌មាន ដែលថាអ្នកនិពន្ធហ្នឹងផ្អែកលើអ្នកណាទេ អ្នកផ្ដល់ព័ត៌មានឲ្យគាត់។ ប៉ុន្តែសេចក្តីដកស្រង់នេះ វាហាក់ដូចជាពិនិត្យមើលការប្រព្រឹត្ត

ទៅលើប្រជាជនមូលដ្ឋាន ហើយក៏មិនមានពាក់ព័ន្ធអ្វីទៅនឹងការចាប់ខ្លួន ដែលសហព្រះរាជអាជ្ញាលើកឡើងដែរ។ ក្រៅពីហ្នឹងទៀត សាក្សីបាននិយាយថា រិន ដែលបានមកជំនួស ភឿង ហ្នឹងគឺថាជា គឺជាកម្មាភិបាលនិរតី ហើយជាកម្មាភិបាលដែលត្រឹមត្រូវ។ អ៊ីចឹងគឺថាខ្ញុំមានការជំទាស់ ដោយសារមូលហេតុមួយចំនួនច្រើន។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកចៅក្រម។ នៅពេលដែលមេធាវីនិយាយថា រិន ជាមនុស្សដែលថាកម្មាភិបាលត្រឹមត្រូវ ហើយនិងធម្មតា ប៉ុន្តែខ្ញុំឮសាក្សីនិយាយថាមកធ្វើការងាររបស់គាត់ជាធម្មតា។ ប៉ុន្តែទាក់ទងនឹងប្រភពរបស់អ្នកនិពន្ធ គឺបានផ្តល់ឈ្មោះនៅក្នុងសៀវភៅ ប៊ិន ឃៀរនិន ដែលថាគាត់បានសម្លាសមនុស្សមួយចំនួននៅក្នុងអត្ថបទ នៅក្នុងលេខយោង។ អ៊ីចឹងគឺថាយើងនឹងមានប្រភពត្រឹមត្រូវ ទាក់ទងថាតើបញ្ហានោះ វាមានភាពពាក់ព័ន្ធដែរ ឬអត់នោះ។ តាមអ្វីដែលខ្ញុំ ជាពិសេសមតិរបស់មេធាវី នួន ជា គឺថា និយាយថាកម្មាភិបាលនិរតីទទួលបញ្ជាពី តាម៉ុក មិនឲ្យប៉ះពាល់ទាហាន លន់ នល់។ ដូច្នេះគឺថាវាមានការពាក់ព័ន្ធទៅនឹងអ្វីជាការតទល់របស់មេធាវីការពារក្តី លើកលែងតែពួកគាត់បោះបង់ទ្រឹស្តីនេះ -- យុទ្ធសាស្ត្រនេះចោល។ ហើយខ្ញុំសួរសាក្សីអំពីគម្រោងនៃការអនុវត្តនៅពេលដែលកម្មាភិបាលនិរតីមកដល់នោះ ជាសំណួរបើកចំហឲ្យគាត់រៀបរាប់ពីគំរូហ្នឹង។ តើតុលាការអនុញ្ញាតឲ្យខ្ញុំបន្តដែរឬទេ?

[១៤:១២:០៦]

**ប្រធានអង្គជំនុំ៖**

បដិសេធការជំទាស់ តែសូមព្រះរាជអាជ្ញាកែសម្រួលសំណួរ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី នៅពេលដែលកម្មាភិបាលនិរតីចូលមកដល់ ទៅដល់តំបន់របស់លោកនោះ តើមាន -- ពួកគេបានស្វែងរកមនុស្ស ឬក៏ក្រុមមនុស្សណាដែរឬទេ? ឬក៏តើគេបានសួរសំណួរអ្នកមូលដ្ឋានពីអ្វីខ្លះ គេចង់ចាប់ស្វែងរកអ្នកណាដែរឬទេ?

**លោក ឈិត យឿក៖**

**ឆ៖** បាទ ពេលនោះ ខ្ញុំនៅចល័ត។ ហេតុនេះមិនសូវបានដឹងរឿងរ៉ាវនៅតាមសហករណ៍ទេ ព្រោះនៅដាច់ នៅដាច់ឆ្ងាយពីក្រុម ដូចថាដាច់ទៅ វាមិនសូវដឹងរឿងរ៉ាវ មានអ្នកណាដើរហើរបានដឹងរឿងទាំងអស់ទេបាទ។

**សៈ** តើលោកធ្លាប់ឮពីការប្រកាសតាមវិទ្យុ បន្ទាប់ពីកម្មាភិបាលនិរតីមកដល់ អំពីជនក្បត់នៅក្នុងតំបន់ផ្សេងៗ នៅក្នុងភូមិភាគពាយ័ព្យអីដែរទេ?

**ឆៈ** បើនិយាយរួមទៅ ជំនាន់នោះដូចជាលំបាក គ្មានវិទ្យុ គ្មានអីណាស្តាប់ផង អត់ដឹងទាំងអស់ បើតាមការពិត គឺមិនដឹងតែម្តង។ វាអត់មានអីស្តាប់។

**សៈ** តើមានវិទ្យុភ្នំពេញដែលគេផ្សព្វផ្សាយអំពីការប្រជុំ អំពីអ្វីដែរឬទេ ជាពិសេសនៅពេលដែលគេប្រជុំម្តងៗនោះ?

**ឆៈ** បើតាមខ្ញុំគិតជំនាន់នោះដូចជាគ្មាន ខ្ញុំដែលនៅអ៊ីចេះ ដូចមិនដែលបានមានវិទ្យុ មានអីស្តាប់ទេ បើគេអ្នកទទួលខុសត្រូវ គឺមាន ធំៗហ្នឹង តែយើងនៅ ល្អិតល្អោចល្មមៗ អត់ទេ វាមិនមានតែម្តង។

[១៤:១៤:៤៥]

**សៈ** ខ្ញុំនឹងអានសៀវភៅ សេចក្តីសម្រង់ គឺថា ERN ខ្មែរ 00637989, បារាំង 00639202 នៅខាងក្រោម ហើយនិងទៅទំព័របន្ទាប់ អង់គ្លេស 00678710 បាទ និយាយអំពីតំបន់។ “នៅពាក់កណ្តាលឆ្នាំ១៩៧៧ រស់ ញឹម -- កូនរបស់ រស់ ញឹម ឈ្មោះ ជាល បានទទួលតំណែងជាបណ្តោះអាសន្នពី ហេង នៅតំបន់៥។ ឥឡូវនេះ ជំនួសដោយកម្មាភិបាលនិរតីឈ្មោះ ហេង រិន។ នៅចុងឆ្នាំ១៩៧៨ កម្មាភិបាលនិរតីក៏ចាប់ផ្តើមកាន់កាប់ស៊ីសុផុន ហើយនិងតំបន់៥ រួចទៅហើយ។ ជនភៀសខ្លួនបានរាយការណ៍ថា ក្រោយការដឹកនាំរបស់អ្នកដឹកនាំចាស់ គេអនុញ្ញាតឲ្យរស់នៅបាន ប៉ុន្តែអ្នកដឹកនាំថ្មីគឺមានវិធានការតឹងណាស់។ នៅថ្ងៃ២៦ មិថុនា គឺកម្មាភិបាលនិរតីក៏បានកាន់កាប់នៅថ្មពួក នៅតំបន់៥ផងដែរ។ ពួកគេបានចាប់មនុស្សប្រាំនាក់ ហើយនិងក៏ចាប់ខ្លួនពួកកងឈ្លបមូលដ្ឋាននោះដែរ។ ហើយនៅក្នុងសហករណ៍ស្រុក១៥នោះ ក៏មានចាប់ខ្លួន។ នៅក្នុងថ្ងៃទី០៥ កក្កដា អ្នកមកថ្មី ក៏បានប្រកាសជាផ្លូវការថា ហើយប្រជាជន៧០.០០០នាក់នោះ គឺថា៤០.០០០ គឺជាខ្មាំងដែលសហការជាមួយខ្មាំង ហើយបានលាក់ឈ្មោះអតីតលន់ នល់ ហើយជាភ្នាក់ងាររបស់ប្រទេសថៃ និងវៀតណាម។ នេះជាការចោទរបស់គេ។” លោកសាក្សី តើលោកចាំអំពីការប្រកាសដែលថា ប្រជាជននៅស្រុកថ្មពួក គឺជាជនក្បត់ដែលសហការ ដែលចូលរួមជាមួយ សេ.អ៊ី.អា, វៀតណាម ហើយនិងប្រទេសថៃនោះ?

**ឆៈ** នេះមិនបាន -- ខ្ញុំមិនសូវបានដឹងដែរ ប៉ុន្តែថា ពេលដែលវៀតណាមមករត់ទាំងអស់គ្នាទៅ គឺវាមិនបានដឹងសេចក្តីប្រកាសអីនោះ។ ព្រោះស្រុកថ្មពួក ហើយតាមមូលដ្ឋាន នៅដាច់ឆ្ងាយពីចល័ត មិនងាយបានដឹងទេ បាទ។

**សៈ** សូមអរគុណ។ លោកសាក្សី តើលោកស្គាល់ឈ្មោះប្រពន្ធរបស់ រិន ទេ?

**ឆៈ** អត់ស្គាល់ ខ្ញុំអត់ស្គាល់ អត់ស្គាល់ឈ្មោះ បាទ។

[១៤:១៨:២៩]

**សៈ** តើលោកដឹងថា រីន គាត់មានក្មួយស្រីអាយុ១៣ឆ្នាំដែរឬទេ?

**ឆៈ** អត់បានដឹងខ្ញុំ រឿងក្មួយរឿងអី អត់ដឹងសោះ។

**សៈ** លោកចៅក្រម ឯកសារពីដំបូង គឺឯកសារដែលខ្ញុំលើកពីមុននោះ គឺថា E3/2254 គឺនិយាយអំពីឈ្មោះស្រីម្នាក់ គឺជាក្មេងស្រីអាយុ១៣ឆ្នាំ នៅលើទំព័រនោះ។ បាទ គឺនៅជិតឈ្មោះ ហេង រិន។ ខ្ញុំនឹងជិតបញ្ចប់សំណួររបស់ខ្ញុំហើយ ខ្ញុំនឹងបញ្ចប់ដោយសួរសំណួរទៅលោក ដើម្បីឲ្យលោកឆ្លើយបញ្ជាក់ទៅនឹងអ្វីដែលលោក ខៀវ សំផន បានសរសេរ។ គឺឯកសារ E3/18, ខ្មែរ 00103878, បារាំង ERN 00595492 ហើយជាភាសាអង់គ្លេស 001037823។ ខៀវ សំផន បានសរសេរថា "ប្រហែលជាភាពល្ងង់ក្នុងអនុញ្ញាតឲ្យខ្លួនឯងមានភាពងប់ងល់ទៅនឹងការដ្ឋាន -- ទៅនឹងអាងទឹក ហើយទំនប់ដែលមានប្រឡាយ ដែលបង្ហាញពីភាពទំនើបនៃជនបទដែលខ្ញុំបានសង្ឃឹមជាយូរមកហើយ ប្រហែលជាការយល់ដោយឆោតល្ងង់ ប៉ុន្តែអាចធ្វើឲ្យនាំខ្ញុំជឿជាក់ ប៉ុល ពត ដែលថាដឹកនាំឲ្យមានវិន័យល្អ ហើយដែលនាំឲ្យខ្ញុំលង់ខ្លួននៅក្នុងមន្ទីររបស់គាត់ ដោយសារ ដោយគំនិតតូចមួយអំពីគោលនយោបាយមួយ ហើយដែលឃោរឃៅ ដែលធ្វើឲ្យប្រទេសជាតិ ធ្វើឲ្យមានការទន់ខ្សោយមិនអាចទប់ទល់នឹងវៀតណាមបាន"។

ជាបឋមលោកសាក្សីតើលោកបានកត់សម្គាល់ទេថាតើមេដឹកនាំណាមានភាពងប់ងល់ទៅនឹងការកសាងទំនប់ហ្នឹងដែរឬទេ?

**ឆៈ** ទេ ពិបាកណាស់ ព្រោះខ្ញុំដល់រឿងអីចុះពិបាកឃើញ ពិបាកពិចារណា ព្រោះខ្ញុំ បើនិយាយរួមទៅ វាជាការកម្លាំងឧបករណ៍មួយដែលគេហៅថាសម្រាប់ទៅធ្វើ ហើយនិងគេចាត់ចែង ដល់ឲ្យមើលឃើញថាអ្នកណាងប់ងល់ ឯណាឯណី ដូចពិបាកដែរ។

[១៤:២១:៤២]

**សៈ** តើលោកយល់ស្របជាមួយ ខៀវ សំផន ដែរទេ គឺថានយោបាយដាច់ខាតរបស់ ប៉ុល ពត ហើយនិងវិធីសាស្ត្រដ៏ឃោរឃៅនាំឲ្យកម្ពុជាចុះខ្សោយ ហើយនិងដើរថយក្រោយ ដែលមានប្រៀបអន់ជាងវៀតណាម?

**ប្រធានអង្គជំនុំ៖**

លោកសាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ ចម្លើយរបស់សាក្សីគឺច្បាប់ហើយ គាត់មិនមែនជាអ្នកជំនាញទេ យើងត្រូវសួរសំណួរទៅលើអ្វីដែលគាត់បានដឹង គាត់បានឃើញ។ នៅពេលដែលយើងសួរសំណួរធម្មតា -- ជាទូទៅបែបនេះ ដែលក្រោយពីអានឯកសារមួយរបស់លោក ខៀវ សំផន ដែលគាត់មិនដឹងនោះ ខ្ញុំគិតថាវាមិនមែនស្ថិតនៅក្នុងតួនាទីរបស់គាត់ដែលត្រូវដឹងឮអំពីរឿងនេះទេ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ផ្អែកលើបទពិសោធន៍អ្វីដែលលោកឆ្លងកាត់ អ្វីដែលលោកបានឃើញនៅព្រះនេត្រព្រះ នៅទំនប់ត្រពាំងថ្ម តើលោកបានឃើញគោលនយោបាយដាច់ខាតដែលអនុវត្តទៅលើប្រជាជនធម្មតាផ្អែកទៅលើការចាប់ខ្លួន ហើយនិងការបាត់ខ្លួនដែលលោកបានឃើញ តើអំពើនោះធ្វើឱ្យប្រទេសចុះខ្សោយដែរឬទេ? តើលោកបានសង្កេតឃើញអ៊ីចឹងដែរឬទេ?

**លោក ឈិត យឿក៖**

**ឆ៖** វាពិតបាកនឹងឆ្លើយ ព្រោះខ្ញុំវាសឹងថាតូចតាចហើយ ក៏វាមិនបានគិតពីរឿងបញ្ហាអស់នេះទេ ព្រោះសំខាន់ទី១ គឺអាយុជីវិត, ទី២ គឺខំរកច្រកឆ្លាំងនោះខ្លាំង មិនសូវបានជាគិតថាថយចុះថយឡើងម៉េចទេ។ អានោះទុកឱ្យគេខាងលើទៅ ព្រោះខ្ញុំអត់។

[១៤:២៣:៥៥]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានសំណួរបន្តទៀតទេ ហើយខ្ញុំនឹងជូនវេទិកាទៅសហសេរិកខាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សូមគោរពលោកលោកស្រីចៅក្រម មេធាវីនាំមុខសូមអនុញ្ញាតលោកប្រធានផ្ទេរសិទ្ធិនៅក្នុងការសួរសាក្សីរូបនេះជូនលោកស្រីមេធាវី ទី ស្រ៊ុនណា ហើយនិងបន្ទាប់ពី

នោះ គឺបន្តដោយលោស្រីមេធាវី ម៉ារី ហ្គីរ៉ូដ៍។ សូមលោកប្រធានអនុញ្ញាត សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

[១៤:២៤:៤៦]

**លោកស្រី ទី ស្រ៊ុនណា៖**

សូមអរគុណលោកប្រធាន និងជាបឋមនាងខ្ញុំសូមគោរពលោកប្រធាន លោកចៅក្រមក្រុមប្រឹក្សា និងអង្គសវនាការទាំងមូល ហើយនិងសូមគោរពលោកសាក្សី នាងខ្ញុំឈ្មោះ ទីស្រ៊ុនណា ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** ហើយមុននឹងធ្វើការតាំងសំណួរជូនលោក ខ្ញុំសូមធ្វើការបញ្ជាក់ជាមួយនឹងលោកទាក់ទាក់ទងទៅនឹងចម្លើយ ដែលលោកបានឆ្លើយជាមួយនឹងសហព្រះរាជអាជ្ញាកាលពីព្រឹកមិញ ហើយក៏ដូចជាពេលមុននេះបន្តិច។

កាលពីព្រឹកមិញហ្នឹងលោកមានចំណុចមួយដែលខាងព្រះរាជអាជ្ញាសួរទៅកាន់លោក ទាក់ទងជាមួយនឹងការដករូបលោកចេញពីការងារ ហើយពេលនោះលោកក៏បានឆ្លើយផងដែរថា ពេលហ្នឹងលោកក៏មិនប៊ានធ្វើការបដិសេធដែរ ទោះបីជាគេដកចេញហើយចាត់តាំងលោកឲ្យធ្វើការរែកដីលេខ១ ក៏លោកមិនប៊ានបដិសេធជាមួយគេដែរ ហើយព្រមទាំងមានការភ័យខ្លាចទៀត។ អ៊ីចឹង ខ្ញុំសូមសួរលោកថា ពេលហ្នឹងរាល់ការងាររបស់លោកទាំងអស់ហ្នឹង តើថ្នាក់លោករបស់លោកហ្នឹងគាត់ជាអ្នកគ្រប់គ្រង ឬក៏គាត់ដឹងឮទាំងអស់រាល់ការងាររបស់លោកដែលលោកកំពុងធ្វើរាល់ថ្ងៃ? តើអ៊ីចឹងមែនទេលោក?

**លោក ឈិត យឿក៖**

**ឆ៖** បាទ អង្គាល់នោះ ព្រោះគេឲ្យមានអ្នកទទួលខុសត្រូវដើរមើលពីរឿងបញ្ហាអ្នករែកដីធ្វើដីអីផ្សេងបាទ មិនមែនជាពីលើគេនេះទេ ព្រោះមានបន្តបន្ទាប់មក។ ខ្ញុំនៅតែរែកទៅ បាទ។

**ស៖** សូមអរគុណ។ អ៊ីចឹង អ្នកដែលរែកដូចលោកដែរ អ្នកដែលមានតួនាទីដូចលោកដែរអ៊ីចឹង តើពួកគេទាំងអស់សុទ្ធតែត្រូវបានមានការតាមដានមើលអំពីការងារប្រចាំថ្ងៃរបស់ពួកលោកទាំងអស់គ្នា

អ៊ីចឹងដែរឬក៏យ៉ាងម៉េចដែរលោក?

**ធ៖** បាទ តាមខ្ញុំមើលទៅគេមើលប្រចាំថ្ងៃ ឬក៏បួនប្រាំថ្ងៃគេអាចមើលថា យើងធ្វើបានប៉ុនណា ឬក៏មិនបាន បាទ។

**ស៖** សូមអរគុណ។ ចុះអ្នកដែលគេតាមដានការងារប្រចាំថ្ងៃរបស់លោកហ្នឹង ក៏ដូចជាក្រុមលោកអីផ្សេងហ្នឹង តើគេស្លៀកសម្លៀកបំពាក់អីគេដែរលោក? ហើយពួកគាត់មកពីខាងណាដែរ?

**ធ៖** បើសម្លៀកបំពាក់អីគឺខ្មៅ ប៉ុន្តែអ្នកខ្លះក៏យើងស្គាល់ទៅ អ្នកខ្លះក៏យើងអត់ស្គាល់ មិនដឹងជាចាត់តាំងមកពីខាងណាទៅ ព្រោះខាងគេអ្នកមកមើល យើងអ្នករែកដីរែកអីហ្នឹង ម្ល៉ោះហើយ ពួកខ្ញុំមិនដឹងប៊ានសួរគេថាម៉េច តាមគេមើលបាទ។

[១៤:២៨:០០]

**ស៖** ចុះលោកដឹងដែរឬទេអ្នកដែលគេតាមដានលោកហ្នឹងមានការចាត់តាំងពីខាងណាដែរលោក?

**ធ៖** គ្នាអ្នកដែលដើរមើលហ្នឹង បើតាមខ្ញុំគិត គេការចាត់តាំងមកពីអ្នកទទួលខុសត្រូវចល័តតំបន់ ដូចជាអ្នកទទួលរួមអី គេឲ្យពិនិត្យមើល យូរៗមកមើលយើងម្តងទៅបាទ។

**ស៖** សូមអរគុណ។ ទាក់ទងនឹងអ្នកតាមដានហ្នឹង គេតាមដានតែក្រុមពួកលោក ឬក៏គេតាមដានជាទូទៅទាំងប្រជាជនដែលធ្វើការនៅក្នុងការដ្ឋានហ្នឹងដែរ ឬក៏យ៉ាងម៉េចដែរលោក?

**ធ៖** បាទ ការតាមដានហ្នឹង បើថាក្រុមអ្នកធ្វើដីប៉ុន្មាននាក់គេតាមដាន គេទៅមើល យើងធ្វើបានប៉ុនណា មិនបាន ឬក៏មូលហេតុអីទៅណ៎ា គ្រប់តែគ្នា អត់មានចាំតែខ្ញុំទេបាទ។

**ស៖** សូមអរគុណ។ អ៊ីចឹង ខ្ញុំសុំសួរបកក្រោយបន្តិចពាក់ព័ន្ធជាមួយការងារលោក ដែលលោកនៅពេលដែលលោកធ្វើការជាជំនួយការរបស់ តាវ៉ាល់ វិញ។ អ៊ីចឹងពេលដែលលោកនៅធ្វើជាជំនួយការរបស់ តាវ៉ាល់ ហ្នឹង តើការងាររបស់លោកហ្នឹងមានការតាមដាន និងឃ្លាំមើលដែរឬក៏អត់លោក?

**ធ៖** បាទ ពីព្រោះខ្ញុំនៅជាជំនួយដូចថា ក្នុងនោះវាមានប្រាំមួយប្រាំពីរនាក់ទៅ ប៉ុន្តែយើងគេចាត់តាំងឲ្យទៅនៅដូចថា នៅតាមកន្លែងណាមួយៗទៅ ក៏គ្នាគ្រាន់តែជួយមើលលិចកើត ហើយយើងក៏ធ្វើទៅ ហើយចេះតែជួយអប់រំយុវជនទាំងអស់ឲ្យខំធ្វើខំអីទាំងអស់គ្នាទៅ ព្រោះផែនការគេដាក់អ៊ីចេះអ៊ីចុះទៅ។ នេះអង្កាល់ដែលខ្ញុំនៅជួយធ្វើគេពីមុនមក។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរសំណួរឡើងវិញ ក្រែងលោលោកស្តាប់សំណួរខ្ញុំអត់ទាន់ច្បាស់។ ខ្ញុំសូមបញ្ជាក់សំណួរខ្ញុំឡើងវិញបន្តិច ខ្ញុំចង់សុំសួរថា នៅពេលដែលលោកធ្វើការជាជំនួយការរបស់

តាវ៉ាល់ ក៏ដូចជា តាវ៉ាល់ គាត់អាចមានជំនួយការផ្សេងៗទៀតដែរ។ អ៊ីចឹង រាល់ការងារដែលលោកធ្វើប្រចាំថ្ងៃជូនទៅ តាវ៉ាល់ ក្តី ឬក៏ការងារប្រចាំថ្ងៃរបស់ក្រុមរបស់លោកដែលជាជំនួយការហ្នឹង ធ្វើការជូន តាវ៉ាល់ ក្តី តើពួកគាត់និងលោកអី តែងតែមានការដូចថា មានការឃ្លាំមើល គេមើលការងាររបស់លោកដែរ ឬក៏អត់ទេ? ឬមួយក៏លោកធ្វើអីស្រេចតែនឹងចិត្តទេលោក?

[១៤:៣១:១៣]

**ឆ៖** បាទ ពីព្រោះដែលធ្វើនោះគឺអត់មានធ្វើអីសម្រេចតែចិត្តយើងទេ គឺតាមបទបញ្ជាគេ ដូចថា ត្រូវលើកមួយថ្ងៃពីរម៉ែត្រគូបអ៊ីចេះ យើងនាំគ្នាប្រាប់គ្នាយើងទាំងអស់គ្នាទៅ ព្រោះផែនការគេឲ្យរែក ២ម៉ែត្រគូបក្នុងមួយថ្ងៃ។ ហេតុនេះធ្វើទៅតាមនោះបាទ អត់មានធ្វើអីតាមអំពើចិត្តខ្លួនឯងទេបាទ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកបញ្ជាក់ឡើងវិញមួយទៀតថា នៅពេលដែលលោកនៅជាមួយ តាវ៉ាល់ តើ តាវ៉ាល់ គេឲ្យលោកធ្វើអីខ្លះដែរ នៅក្នុងនាមដែលលោកជាជំនួយការគាត់?

**ឆ៖** វាក្នុងជំនួយការនោះ វាមានដល់ប្រាំមួយ ប្រាំពីររូប ប៉ុន្តែក្នុងខ្លួនខ្ញុំផ្ទាល់ ខ្ញុំដឹងថាគេដាក់យើងចុងកន្ទុយ *(ឮមិនច្បាស់)* ហេតុនេះមិនមានអីដែលថា ធំដុំទេ ប៉ុន្តែគេអ្នកបន្តបន្ទាប់យើងនោះ គេចេះតែមកសួរយើងទៅ។ ម្ដុំនេះ ហើយរែកបានសម្រេចដូចថា ២ម៉ែត្រគូបអីក៏អត់អីណា។ ហេតុនេះខ្ញុំក៏រាយការណ៍ប្រាប់គេទៅ វាដូចថាមួយកន្លែងត្រង់ណេះគឺរែកបាន ២ម៉ែត្រគូប ហើយក៏ហ៊ីទៅ។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមសួរមួយសំណួរទៀតពាក់ព័ន្ធជាមួយនឹង តាវ៉ាល់ វិញ។ អ៊ីចឹង ការងារដែលដាក់ឲ្យលោកធ្វើក៏ដូចជាខាងក្រោមលោកធ្វើតទៅទៀតហ្នឹង តើ តាវ៉ាល់ គាត់ជាអ្នកដាក់ដោយផ្ទាល់ ឬក៏មានការឆ្លងកាត់ការប្រជុំអីរួចបានដាក់ការងារឲ្យលោកធ្វើ ឬក៏យ៉ាងម៉េចដែរលោក?

**ឆ៖** ព្រោះការដែលមុននឹងមកដាក់ឲ្យពួកខ្ញុំខាងក្រោមៗនេះ គេប្រជុំ គេមានគណៈកម្មការគេ គេប្រជុំរួចបានគេចេញជាផែនការមកឲ្យយើង។

[១៤:៣៣:២៦]

**ស៖** អ៊ីចឹងមានន័យថា តាវ៉ាល់ គាត់មិនមែនជាអ្នកសម្រេចខ្លួនឯងទេ គឺគាត់តែងតែធ្វើការប្រជុំជាមុន មានការប្រជុំជាផ្លូវការហើយទើបបានគេដាក់ផែនការហ្នឹងឲ្យថ្នាក់ក្រោមបន្តបន្ទាប់ទៀត។ តើ អ៊ីចឹងមែនទេលោក?

**ឆ៖** បាទ ដូចអ្នកស្រីនិយាយអ៊ីចឹងគឺត្រូវហើយ ព្រោះដល់រួចមកបាន បន្តៗហ្នឹងគេមកដាក់ឲ្យយើងបាទ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកមួយទៀតទាក់ទងនឹងរឿងបញ្ហាបែងចែកអង្ករវិញ ព្រោះកាលពីព្រឹកមិញលោកបានជម្រាបជូនលោកព្រះរាជអាជ្ញាជាច្រើនហើយ ពាក់ព័ន្ធជាមួយនឹងការបែងចែកអង្ករ ហើយលោកក៏បានលើកឡើងថា ក្នុងម្នាក់គេចែកអង្ករឲ្យបីកំប៉ុងក្នុងមួយថ្ងៃ។ អ៊ីចឹងខ្ញុំសូមបញ្ជាក់លោកបន្ថែមថា អង្ករបីកំប៉ុងក្នុងមួយថ្ងៃនេះ គេចែកឲ្យសម្រាប់តែក្រុមចល័តរបស់អ្នកដែលមានតួនាទីដូចជាក្រុមចល័តរបស់លោក អ៊ីចឹងតើមែនទេលោក?

**ឆ៖** បាទ តាមដែលខ្ញុំដឹង គឺមានតែចល័តទេ ព្រោះចល័តជាកម្លាំងទី១ គេឲ្យបីកំប៉ុង។ ពេលដែលបន្ទាន់ចង់រួចអីមួយ គឺគេឲ្យបីកំប៉ុង តែតាមសហករណ៍ ខ្ញុំអត់ដឹងទេ ប្រហែលជាមិនបានបាទ។

**ស៖** សូមអរគុណ ហើយខ្ញុំសូមបន្តទៀត តើការចែកបីកំប៉ុងក្នុងមួយថ្ងៃនេះ គេចែកចាប់តាំងពីគេចាប់ផ្តើមកសាងទំនប់ត្រពាំងថ្មហ្នឹងរហូតដល់ចប់តែម្តង ឬមួយក៏គ្រាន់តែចែកក្នុងដំណាក់កាលដំបូងឬក៏យ៉ាងម៉េចដែរ សូមលោកជួយបំភ្លឺទាក់ទងចំណុចហ្នឹងបន្តិច?

**ឆ៖** បាទ អានោះវា បើតាមខ្ញុំគិតការចែកអង្ករនោះ វាមិនទៀងទាត់ ដោយសារអី? ដោយសារថាពេលណាគេត្រូវសម្រុក ដូចថាយើងត្រូវបង្ខំឲ្យរួចស្អីមួយ គឺអង្ករគេត្រូវបញ្ជូនមកទុកសម្រាប់បើកឲ្យហ្នឹង តែក្រៅពីសម្រុកនោះ មានដល់មួយកំប៉ុងកន្លះ រហូតដល់កន្លះកំប៉ុង រហូតទៅនឹងដាច់មួយថ្ងៃក៏មានបាទ ពីរថ្ងៃបាទ អត់ទៀងបាទ។

[១៤:៣៦:៤១]

**ស៖** សូមអរគុណ។ អ៊ីចឹងមានន័យថា លោកក៏ធ្លាប់មានដាច់របបអាហារដែរ តើអ៊ីចឹងមែនទេលោក?

**ឆ៖** បាទ ខ្ញុំក៏ធ្លាប់ដាច់ រហូតខ្ញុំស៊ីកន្ទក់ដែរ។ ជួនកាលកន្ទក់នេះ គឺវាអត់ដែរ។

**ស៖** សូមអរគុណ ហើយខ្ញុំសូមឲ្យលោកជួយបំភ្លឺបន្តិច ដោយសារតែលោកបានធ្លាប់រស់នៅក្នុងកន្លែងការដ្ឋានហ្នឹង ហើយទោះបីជា ខ្ញុំគិតថាលោកនៅក្នុងកងចល័តទេ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ខ្ញុំគិតថា លោកប្រហែលជាអាចដឹង ឬក៏ឮអំពី ឬក៏បានឃើញទិដ្ឋភាពដែលអ្នកធ្វើការនៅក្នុងការដ្ឋានហ្នឹងជាច្រើនដែរ។ អ៊ីចឹងខ្ញុំចង់សូមសួរលោកថា នៅក្នុងការដ្ឋានដែលគេធ្វើការហ្នឹង ស្ថានភាពនៃការងាររបស់ពួកគេយ៉ាងម៉េចដែរលោក នៅពេលនុ៎ង?

**ឆ៖** បាទ ស្ថានភាពការងារនៅពេលនោះ បើពីដំបូង គេមានធ្វើទាំងយប់ទៀតបាទ។ ដល់រយៈពេលក្រោយមក ក៏ដូចថាមិនសូវបានធ្វើយប់។ ពីអង្កាល់ដំបូងគឺធ្វើយប់ គេធ្វើយប់ផង ចាប់ពីម៉ោង

ប្រាំពីរ ទល់ ម៉ោងដប់យប់។

**ស៖** សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេ តើមូលហេតុអ្វីបានជាគេធ្វើការងារវេនយប់ដូច្នេះ?

**ឆ៖** តែបើតាមការគិត ដែលខ្ញុំគិតឃើញខ្លួនខ្ញុំផ្ទាល់ ខ្ញុំថាមានតែគេចង់ដូចថា ចង់សម្រេចថាក្នុងបណ្ដោយ១គីឡូទំនប់នេះ គឺត្រូវធ្វើឲ្យហើយរយៈពេលប្រាំថ្ងៃអី ឬក៏១០ថ្ងៃ គេត្រូវតែធ្វើអីចឹងហ្នឹងបាទ។

[១៤:៣៩:២៣]

**ស៖** សូមអរគុណ។ ខ្ញុំបានចាប់អារម្មណ៍ទៅលើចំណុចមួយដែលលោកថា នៅការងារដែលកំណត់ថា បើសិនជាគេកំណត់ថាបណ្ដោយ១គីឡូ គេត្រូវបង្ខំប្រឹងទាល់តែចប់តែម្ដង។ អីចឹងខ្ញុំសូមសួរលោកពាក់ព័ន្ធជាមួយផែនការវិញ ទាក់ទងការកសាងទំនប់ហ្នឹង គេកំណត់យ៉ាងម៉េចដែរលោក គេកំណត់ថា ធ្វើក្នុងរយៈពេលប៉ុន្មានឲ្យហើយ ឬក៏យ៉ាងម៉េចដែរ គេមានបង្ខំ ឬក៏គេមានកំណត់គោលការណ៍ហ្នឹងដែរឬទេ?

**ឆ៖** ព្រោះអានោះ បើតាមខ្ញុំគិតតែបើកអង្គរឲ្យគេ ក៏វាមាន -- តែពេលគេសម្រុក គេមកប្រាប់យើងបីកំប៉ុង។ តែបើគិតទៅ អានេះគេចង់គិតថា បណ្ដោយ១គីឡូនេះ វាមានប៉ុន្មានម៉ែត្រគូប ដែលត្រូវពេញ ហើយគេត្រូវយកចល័តទៅដាក់ប៉ុន្មានដើម្បី៥ថ្ងៃឲ្យរួច ឬក៏ត្រូវបន្ថែមចល័តទៀត។ អានេះដែលខ្ញុំដឹង ហេតុនេះគេត្រូវតែធ្វើឲ្យបាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាប់សម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ និងមេធាវីប្រឹក្សា នៅក្នុងអំឡុងពេលឈប់សម្រាកនឹងអញ្ជើញគាត់-- សូមអញ្ជើញមេធាវី!

[១៤:៤១:០៩]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនិយាយនេះ ដើម្បីឲ្យសហព្រះរាជអាជ្ញាអាចពិនិត្យមើលឯកសារ

ក្នុងពេលសម្រាកបាន។ ពាក់ព័ន្ធនឹងឈ្មោះ ហេង រិន គាត់បានលើកឡើងថា ឯកសារពីរគឺ E3/7403 ជាភាសាអង់គ្លេស ដែលនិយាយពាក់ព័ន្ធទៅនឹងចម្លើយសារភាពរបស់ ហេង រិន ហើយនៅក្នុងឯកសារជាភាសាខ្មែរ គឺមានភាពខុសគ្នា គឺមិនមែនឈ្មោះ ហេង រិន ហ្នឹងទេ គឺនៅក្នុងភាសាខ្មែរហ្នឹង គឺថា ហេង រិន ហ្នឹងមិនមែនមកពីតំបន់៥ទេ។ អ៊ីចឹង សូមឲ្យសហព្រះរាជអាជ្ញាគាត់ពិនិត្យមើលនៅពេលសម្រាកហ្នឹង តើមានបញ្ហាយ៉ាងម៉េច គឺយើងមើលទៅមានខុសគ្នាក្នុងរវាងខ្មែរ និងភាសាអង់គ្លេស។ អ៊ីចឹង សូមឲ្យគាត់ពិនិត្យមើលនៅក្នុងពេលឈប់សម្រាក។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

--និងអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ វេលាម៉ោងបី។

សូមអញ្ជើញសម្រាក។

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៤:៥៩ នាទី)*

[១៤:៥៩:១៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្ត សូមអញ្ជើញលោកស្រីមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី មានសំណួរលើសាក្សីនេះបន្តទៀត។

**លោកស្រី ទី ស្រ៊ុនណា៖**

សូមអរគុណលោកប្រធាន ប៉ុន្តែមុនខ្ញុំធ្វើការបន្តសំណួរទៀត សូមសួរលោកប្រធាន ទាក់ទងទៅនឹងពេលវេលាបន្តិច ដោយសារតែកាលពីព្រឹកមិញ លោកសហព្រះរាជអាជ្ញា គាត់បានតាំង -- ចាប់ផ្តើមតាំងសំណួរនៅម៉ោងប្រាំបួន ហាសិបប្រាំនាទី។ អ៊ីចឹងដូច្នេះហើយ តើពួកខ្ញុំនៅសេសសល់ម៉ោងប៉ុន្មានដែរ សូមលោកជួយធ្វើការបញ្ជាក់ជូន។

[១៥:០០:១០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០១:១៦]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីនៅសល់រយៈពេល៣០នាទីទៀត។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** លោកសាក្សី ដោយសារមុននឹងខ្ញុំបានឈានទៅដល់សួរលោកទាក់ទងនឹងលក្ខខណ្ឌការងារ ប៉ុន្តែឥឡូវខ្ញុំសូមសួរបកក្រោយបន្តិចទាក់ទងទៅនឹងការកំណត់ផែនការនៃការសាងសង់ទំនប់វិញ។ ដោយសារតែវាមានភាពពាក់ព័ន្ធគ្នាពីដំបូង មុននឹងខ្ញុំឈានទៅដល់ការសួរលោកពាក់ព័ន្ធជាមួយនឹងលក្ខខណ្ឌការងារ ជៀសវាងកុំឱ្យត្រឡប់ចុះ ត្រឡប់ឡើង។ ខ្ញុំសូមសួរលោកថា តើនរណាជាអ្នកកំណត់ផែនការក្នុងការសាងសង់ទំនប់ត្រពាំងថ្មនេះ? លោកដឹងដែរឬទេ?

**លោក ឈិត យឿក៖**

**ឆ៖** បាទ កាលនោះ អ៊ីចេះ មិនបានជាទៅប្រជុំអីទេ ប៉ុន្តែក៏យើងឮតាមរយៈនោះ គឺគេចង់និយាយថា ការដែលធ្វើទំនប់នេះ មិនមែនសម្រេចត្រឹមតំបន់អីទេ គឺនិយាយរួម ចាប់ពីភូមិភាគឡើងទៅ។ មិនមែនមកធ្វើគម្រោងត្រឹមតំបន់អី មកធ្វើ អត់បានទេ បាទ អានេះតាមខ្ញុំដឹង បាទ។

[១៥:០២:៥០]

**ស៖** ចុះពេលហ្នឹង គេមានបានផ្សព្វផ្សាយថា ទំនប់នេះយើងត្រូវចាប់កសាងនៅពេលណា ហើយនិងត្រូវបញ្ចប់នៅពេលណាឬទេលោក?

**ឆ៖** កាលពីពេលនោះវាបានដឹងឮថា អង្កាល់នោះ គឺគេចង់និយាយថា ក្នុងមួយឆ្នាំនេះ ធ្វើឱ្យរួចតែវាប៉ះឧបសគ្គអីទៀត អាហ្នឹងវាអាច បានទំនប់នេះវាត្រូវធ្វើរយៈពេលពី តាវ៉ាល់ មកដល់ តារិន នេះហើយក៏មិនទាន់រួចជាស្ថាពរដែរ វាទើបតែរួចមួយចំនួនធំទៅ ក៏បែកបាក់គ្នាទៅ បាទ។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំចង់សូមសួរថា នៅពេលដែលផែនការហ្នឹង គេដាក់ចុះ នរណាគេជាអ្នកទទួលការងារអនុវត្តផែនការហ្នឹង?

**ឆ៖** ដែលដាក់ចុះមកគឺ តាវ៉ាល់ ជាអ្នកគ្រប់គ្រងអ្នកទទួល ហើយមានតំបន់គេចុះមកជំនួយជួយពិគ្រោះៗពិភាក្សាគ្នាពីបញ្ហាការលើកទំនប់នេះ បាទ។

**ស៖** អម្បាញ់មិញលោកថាមានជំនួយគេចុះមកពិភាក្សាដែរ។ តើជំនួយដែលគេចុះមកពិភាក្សា

អំពីការសាងសង់ទំនប់ហ្នឹង គេចុះមកញឹកញាប់ដែរឬទេ លោក?

[១៥:០៤:៤៨]

**ឆ៖** បាទ តំបន់ចុះមកញាប់។ បើតាមយើងលើកទំនប់លើកអី តែងឃើញ ជួនកាលមួយខែមកពីរដង។ មុនដំបូង មួយខែពីរបីដង បាទ។

**ស៖** ចុះបន្តបន្ទាប់មកទៀត គេនៅតែបន្តចុះរហូតដល់វៀតណាមចូលមកតែម្តង ឬក៏យ៉ាងម៉េចខាងតំបន់ដែលគេចុះមកមើលហ្នឹង? ចុះមកជួយជាជំនួយហ្នឹង?

**ឆ៖** បាទ បើតាមខ្ញុំឃើញពីមុនក៏គេចុះមកដល់តំបន់ ក្រោយទៀតក៏នៅតែចុះ ៗជាប់ប្រឡូកប្រឡាក់នៅអាងត្រពាំងថ្មនេះឯងបាទ។

**ស៖** សូមអរគុណ។ អ៊ីចឹង ខ្ញុំសុំសួរពាក់ព័ន្ធជាមួយការអនុវត្តវិញ។ នៅពេលដែលយើងអនុវត្តការសាងសង់អាងត្រពាំងថ្មហ្នឹង ពេលហ្នឹងតើប្រជាជន អ្នកដែលគេនាំឲ្យមកធ្វើការងារនៅហ្នឹង គេជាប្រជាជន ឬក៏គេមកពីខាងណាពីខាងណីដែរ? លោកអាចជម្រាបជូនបានទេ ដូចថាមានមកពីខាងណាខ្លះ? ឬក៏មានតែក្រុមអ្នកដែលធ្វើការតួនាទីដូចពួកលោកមានតួនាទីក្នុងជួរកងទ័ពទេ ដែលអាចមកធ្វើការងារនៅហ្នឹង ឬមួយក៏យ៉ាងម៉េចដែរលោក?

**ឆ៖** បាទ រឿងដែលមនុស្សដែលមកធ្វើការនោះគឺយកពីតាមស្រុក តាមស្រុករើសយុវជននារីតាមស្រុកទៅបញ្ចូលទៅក្នុងចល័តតំបន់។ ក្នុងនោះ ដូចមិនមានកងទ័ពទេ អត់មានទ័ពទៅច្របូកច្របល់ទេបាទ។ គ្រប់ស្រុកយកទៅបាទ។

**ស៖** ចុះមានប្រជាជនជម្លៀសទៅពីភ្នំពេញដែរឬទេលោក?

**ឆ៖** បាទ បើតាមខ្ញុំមើលដែលគិតទៅច្រើនបាទ ប្រជាជនដែលជម្លៀសភ្នំពេញគឺច្រើនហ្លងច្រើនជាងមូលដ្ឋានទៀត។

**ស៖** សូមអរគុណ។ តើប្រជាជនដែលជម្លៀសពីភ្នំពេញទៅ គេយកទៅឲ្យធ្វើការនៅក្នុងការដ្ឋានហ្នឹង គេដាក់លាយឡំជាមួយប្រជាជនមូលដ្ឋាន ឬមួយក៏គេដាក់ដោយឡែកពីគ្នា?

**ឆ៖** គេយកទៅគេច្របល់គ្នាដាក់ចម្រុះគ្នានៅក្នុងនោះបាទ ទាំងអស់គ្នា អត់មានដាក់ដោយឡែកទេ។

**ស៖** ពាក់ព័ន្ធជាមួយនឹងការងារវិញ ពេលដែលពួកគាត់ទៅដល់គេឲ្យគាត់ធ្វើអីខ្លះដែរ? ហើយការងារហ្នឹងគេបែងចែកចេញជាប៉ុន្មានប្រភេទដែរលោក?

**ប្រធានអង្គជំនុំ៖**

សាក្សីចាំមីក្រូហ្វូនប្រតិបត្តិការសិន ចាំឆ្លើយ!

**លោក ឈិត យឿក៖**

**ឆ៖** បាទ ពេលនោះដែលគេទៅដល់នោះគឺ គេចាត់ចែងគ្នាឲ្យមានទី១ អ្នកធ្វើស្មៀតចប, ទី២ គឺ អ្នកចាត់ចែងបង្គី ហើយខ្សែ។ ហេតុនេះ អ្នករែកគឺគិតតែរែក បើដាច់ខ្សែបង្គីគឺយកទៅឲ្យគេ ចបសណ្ដក យកទៅឲ្យគេទៅ។ នេះតាមខ្ញុំមើលឃើញថាគេចាត់ចែងហ្នឹងណ៎ាបាទ។

[១៥:០៩:០៥]

**សួរដោយលោកស្រី ទី ស្រីនណា៖**

**ស៖** អ៊ីចឹង ពេលហ្នឹងគេកំណត់លក្ខខណ្ឌការងារយ៉ាងម៉េចដែរ? ដូចថា មួយខែត្រូវធ្វើប៉ុន្មានថ្ងៃ? ហើយក្នុងមួយថ្ងៃត្រូវធ្វើប៉ុន្មានម៉ោង? ហើយទំហំការងារគេបែងចែកឲ្យយ៉ាងម៉េចដែរលោក?

**ឆ៖** ការងារគេបែងចែកព្រឹកចាប់ពីម៉ោងប្រាំពីរ ជួនកាលដល់មានដល់ម៉ោងដប់មួយកន្លះ។ ដល់ថ្ងៃចាប់ពីម៉ោងមួយទល់ម៉ោងប្រាំ។

**ស៖** ចុះការងារដែលគេដាក់ឲ្យធ្វើហ្នឹង គេកំណត់យ៉ាងដូចម្ដេចវិញ?

**ឆ៖** ការងារដែលដាក់ឲ្យធ្វើនោះ គឺគេបែងចែកជាម៉ែត្រគូប ក្នុងម្នាក់២ម៉ែត្រគូប បើក្រុមណា ៣០នាក់គុណទៅឃើញបាទ។ ហេតុនេះបើអ្នកណារួចមុនគេអាចមកផ្ទះបានខ្លះ ប៉ុន្តែភាគច្រើនៗតែជួយគ្នាដែរ។

**ស៖** អ៊ីចឹងមានន័យថា ក្នុងមួយក្រុមគេមាន៣០នាក់ ហើយធ្វើការងារក្នុងម្នាក់ៗ២ម៉ែត្រគូប។ អ៊ីចឹងខ្ញុំសូមបញ្ជាក់លោកបន្តិចថា តើក្នុង២ម៉ែត្រគូបហ្នឹងពួកគាត់អាចធ្វើការងារហ្នឹង ចង់និយាយថា ការងារហ្នឹងគាត់អាចធ្វើហើយទេក្នុងម្នាក់ បើយើងវិភាគទៅ? ដោយគ្មានការជួយពីអ្នកដទៃ។ តើក្នុងម្នាក់ហ្នឹងគាត់អាចធ្វើហើយទេក្នុង២ម៉ែត្រគូបហ្នឹង គេតម្រូវឲ្យធ្វើតែមួយថ្ងៃហ្នឹងតែម្ដង ឬម៉េច?

[១៥:១១:១៨]

**ឆ៖** ២ម៉ែត្រគូបដំបូងគឺមិនរួច អ្នកខ្លះធ្វើដល់យប់ដែរ ព្រោះអ្នកមិនរួចត្រូវតែធ្វើទៀត។ ដល់យូរៗទៅ វាដូចថាវាធ្លាប់ទៅ ដូចថាដាក់រួចៗដែរបាទ។

**ស៖** ចុះអ្នកដែលធ្វើមិនហើយតាមគេកំណត់ហ្នឹង គេមានធ្វើដាក់ទណ្ឌកម្មពិន័យអីទៅលើពួកគាត់ដែរឬទេ កន្លងមកដែរមានទេ?

**ឆ៖** វាមានតែគេលើកទី១ ទី២ អីទៅ គេអប់រំទៅតាមនោះទៅ ប៉ុន្តែភាគច្រើនគ្នាក៏ត្រូវតែខំឲ្យបាន ពីព្រោះជួនកាលដែលយើងធ្វើមិនរួច ហូបបាយរួចត្រូវតែធ្វើទៀតហើយ ធ្វើបង្ហើយទៀតបាទ។ តែអារឿងដាក់ទោសអីយ៉ាងណា ពិបាកណាស់ ព្រោះខ្ញុំនៅខាងបើកអង្ករ ដូចជាមិនសូវបានដឹងរឿងគេទេ។

**ស៖** អ៊ីចឹងខ្ញុំសូមធ្វើការបញ្ជាក់លោកបន្តិច ដោយសារប្រហែលជាខ្ញុំមិនសូវជាយល់ កន្លែងចំណុចមួយដែលលោកថា អ្នកខ្លះគាត់ធ្វើ គេដាក់ផែនការឲ្យធ្វើតែមួយថ្ងៃឲ្យហើយ ដល់ពេលគាត់ធ្វើមិនហើយ គាត់បន្តធ្វើដល់យប់ទៀត។ តើការដែលគេដាក់ការងារឲ្យគាត់ធ្វើដល់យប់ទៀតអាចចាត់ទុកថាជាទណ្ឌកម្មក្នុងការបន្ថែមបំពេញការងារហ្នឹងដែរឬទេ ដើម្បីឲ្យរួចរាល់តាមផែនការគេកំណត់?

**ឆ៖** បាទ អានោះគេទុកដូចជាទណ្ឌកម្មមួយដែលថា យើងធ្វើមិនរួច ឈ្មោះណាដែលធ្វើមិនរួចឬក៏ក្រុមណាត្រូវតែធ្វើឲ្យរួច ពីព្រោះភាគច្រើនគេរួចអស់នៅដូចថាមួយក្រុមអី នៅសល់តែពីរបីនាក់អីដែលថាគ្នាកម្លាំងខ្សោយមិនរួចទៅ គេឲ្យនៅធ្វើទៀត។ បាទ អានោះទណ្ឌកម្មគេៗដាក់ឲ្យយើងធ្វើឲ្យហើយ។

[១៥:១៣:៤២]

**ស៖** ចុះលោកមានដែលធ្លាប់ឮ ឬក៏ធ្លាប់ដឹង ឬក៏ធ្លាប់ឃើញថាមានអ្នកខ្លះគាត់កំពុងតែធ្វើការៗទៅ ដូចថាគាត់ទ្រាំ ស៊ូទ្រាំនឹងការងារហ្នឹងមិនបានក៏ដួលសន្លប់ ឬក៏អាចទៅជាអ្នកខ្លះទៅដល់ថ្នាក់ស្លាប់អីក៏មានដែរ។ តើដែលឮករណីហ្នឹងដែរឬទេ?

**ឆ៖** រឿងអ្នកដែលថា កំពុងធ្វើការស្លាប់ វាមិនដែលបានឃើញទេ ប៉ុន្តែបើអ្នកកំពុងធ្វើការទៅមានដួល មានប្រកាច់ប្រកិនអីខ្លះ គឺមិនមែនត្រឹមដឹងឮទេ ឃើញបណ្តោយបាទ។

**ស៖** សូមអរគុណ។ ចុះលោកមានដែលធ្លាប់ឮគេថា ឧបមាថាប្រជាជនតែងតែគាត់និយាយថា បើសិនជាធ្វើការងារទៅបាក់ចប ជួនកាលបង្កីហ្នឹងដាច់ ហើយគេក៏ចោទថាគាត់ហ្នឹងជាជនក្បត់អីដែរឬទេ? លោកមានដែលដឹងថាករណីហ្នឹងដែរឬទេលោក?

**ឆ៖** ករណីនេះ ខ្ញុំក៏អាចឮដឹងខ្លះ គឺតាមអ្នកមកយកអង្ករ យកអីហ្នឹង តែអារឿងខ្ញុំនេះ វាមិនសូវបានទៅយកចិត្តទុកដាក់អី រឿងគេឯណោះទេ ប៉ុន្តែអ្នកស្គាល់គ្នាអី ដែលខ្ញុំស្គាល់នាងណាមួយ ឬមិត្តណាមួយទៅ ក៏គេប្រាប់ទៅណាថា "ដាច់បង្កី ដាច់អី គេចង់ចោទឯងថាអី ជាឯងជាខ្មាំង ជាសត្រូវ" អានោះខ្ញុំឮបាទ។

**ស៖** សូមអរគុណ។ ចុះនៅក្នុងពេលដែលប្រជាជនហ្នឹង គាត់កំពុងតែធ្វើការនៅក្នុងការដ្ឋាន អំឡុងពេលហ្នឹង តើគេមានធ្វើប្រវត្តិរូបពួកគាត់អត់ លោក?

**ឆ៖** ប្រវត្តិរូប បើតាមខ្ញុំភ្លាប់បាន ពួកនេះច្រើនធ្វើអ៊ីចេះ ធ្វើដូចថា ពេលគេត្រូវរើសអីមួយ ឬក៏អ្នកនោះមានបញ្ហាអីមួយ គេតាមធ្វើប្រវត្តិរូបបាទ។ តែដល់ឮឲ្យធ្វើទាំងអស់ ដូចមិនទាន់មាននៅក្នុងចល័ត បើចល័តរាប់ម៉ឺនឯណោះ។

**ស៖** ខ្ញុំមានចម្ងល់បន្តិចទាក់ទងនឹងការធ្វើប្រវត្តិ តើជាទូទៅគេធ្វើប្រវត្តិរូបហ្នឹងដើម្បីអីដែរទៅលោក ពេលនុ៎ង?

[១៥:១៦:៥៥]

**ឆ៖** ទេ អានេះបើតាមខ្ញុំគិតនោះ ព្រោះប្រវត្តិរូបនេះចង់និយាយថា វាមានលក្ខណៈសម្គាល់មួយថា ឈ្មោះនេះនៅភូមិនោះ ភូមិនេះ រៀនដល់ថ្នាក់ទីប៉ុណ្ណេះ ហើយជាកូនអ្នកក្រ ឬជាកូនអ្នកមាន។ អានេះបើតាមខ្ញុំដឹង ពីព្រោះគេចង់និយាយថា អ្នកមាន អ្នកក្រ ដូចថាវាពិបាកនិយាយដែរអាត្រង់នោះ បើគេធ្វើ គេចង់ដឹងបែប ចង់ដឹងអ្នកមាន អ្នកក្រ អ្នកចេះ អ្នកដឹង បើតាមខ្ញុំមើលទេណា។

**ស៖** ចុះមូលហេតុអ្វីបានជាគេចាំបាច់ដឹងថា អ្នកណាហ្នឹងនៅភូមិនេះ ភូមិនោះ ជាអ្នកមាន និងអ្នកក្រ ដូច្នេះអ៊ីចឹងលោក?

**ឆ៖** វាមិនដឹងយ៉ាងណា ពីព្រោះអានេះ វាពិបាកនឹងនិយាយ ព្រោះអ៊ីចេះ ដោយសារតែ ព្រោះដល់សង្គមណាក៏ដូចសង្គមណា បើគេត្រូវរើសមនុស្សណាទៅ គេតែងមកធ្វើ -- មិននេះទេ គេស្រាវជ្រាវប្រវត្តិរូបទាំងពីស្រុកឃុំ ទទួលស្គាល់ដូចយើងសព្វថ្ងៃអ៊ីចឹងណា ប៉ុន្តែមិនដឹងថាគេនោះ ចង់បានអី ឬស្អីអានោះយើងមិនបានទស្សន៍ទាយទេ គ្រាន់តែដឹងថាគេធ្វើនោះ ប្រហែលជាគេចង់ដឹងអ្នកមាន អ្នកក្រ អ្នកចេះ អ្នកដឹងហើយ បើតាមខ្ញុំមើល។

**ស៖** សូមអរគុណ។ ចុះលោកដែលធ្លាប់ដឹង ឬក៏ឮគេនិយាយទាក់ទងទៅនឹងពួកគាត់ ដែលកំពុងធ្វើការនៅក្នុងការដ្ឋាន ស្រាប់តែធ្វើៗ ក៏មានបាត់ខ្លួនចេញពីការដ្ឋានហ្នឹង តើមានករណីហ្នឹងដែរ ឬទេលោក?

**ឆ៖** បាទ រឿងនោះគឺមានមែន តែត្រង់គេយកទៅធ្វើម៉េចៗ គឺវាមិនបានដឹងបាទ មានបាត់មែនបាទ។

**ស៖** សូមអរគុណ។ តើការបាត់ខ្លួនហ្នឹងមានច្រើនទេលោក?

**ឆ៖** បាទ វាពិបាកដែរ ព្រោះនៅក្នុងនោះ បើសិនជាយើងនិយាយឲ្យខ្លីទៅ បើយើងដូចខ្ញុំអ៊ីចេះ បើការងារនៅក្នុងក្រុម ក្នុងកង ជាមួយគេនោះអាចដឹងច្រើន តែមួយឡែកតែឯង រឿងអ្នកបើកអង្គរនេះ បានដឹងខ្លះ មិនដឹងខ្លះបាទ។

[១៥:១៩:៥១]

**ស៖** សូមអរគុណ។ ខ្ញុំចង់សួរពាក់ព័ន្ធជាមួយលោកផ្ទាល់វិញ ចំពោះរូបលោក បើសិនជាក្នុងករណីដែលគេដាក់ការងារឲ្យលោកធ្វើ ហើយឧទាហរណ៍ថា លោកមិនអាចសម្រេចតាមផែនការរបស់គេ តើមើលទៅអាច លោកនឹងប្រឈមនឹងហេតុការអីកើតឡើងចំពោះរូបលោកទេ បើសិនជាតាមដែលលោកធ្លាប់មានបទពិសោធន៍នៅក្នុងអំឡុងពេលនុ៎ង?

**ឆ៖** បាទ ព្រោះខ្ញុំក៏មានបទពិសោធន៍ ដោយសារតែខ្ញុំមានទោស រែក៨ម៉ែត្រគូបដែរ។ ខ្ញុំមានពិសោធថា ខ្ញុំរែកទាំងយប់ទាំងថ្ងៃទៅ តែដូចថាពេលនោះយើងចេះ លួចរេះដីរេះអី ឲ្យថ្មីខ្លះទៅផ្សេងៗទៅ ពេលគេអ្នកមកវាស់ គេចាប់វាស់ត្រឹមដីថ្មី។ ដីដែលយើងកាប់ថ្មីហ្នឹង គេវាស់មក យើងមិនពិបាកទៅនិយាយអីជាមួយគេទេ គេអត់មានមកសួរអីទេ។ ហេតុនេះ បើអ្នកដែលគ្មានគំនិត ឬក៏ឆ្លាតឈ្លាសវៃទេ ៨ម៉ែត្រគូបនោះ បើតាមខ្ញុំគិត ចាប់ពីម៉ោងបីយប់អី ទៅទល់ម៉ោងដប់ពីរយប់ទៀត ក៏វាមិនរួចផង ត្រូវដេកនឹងអន្លង់នោះឯង ដេកនឹងអន្លង់ដីតែម្តង។ បាយរួចទៅទៀតហើយ ព្រោះខ្ញុំជាប់ទោសនឹងគេម្តងដែរ បានខ្ញុំដឹង។

[១៥:២១:២៤]

**ស៖** សូមអរគុណ ព័ត៌មានរបស់លោកពិតជាសំខាន់មែន។ អ៊ីចឹង ខ្ញុំសូមសួរលោកទាក់ទងនឹងអតីតមេលោកវិញ ដូចជា តាវ៉ាល់ ហើយនិងមុនហ្នឹង ក៏លោកសហព្រះរាជអាជ្ញាក៏បានលើកសួរទាក់ទងនឹង តាម៉ោង, តាសំអាត និងតាជាល រហូតដល់អ្នកអនុវត្តការសាងសង់ការដ្ឋានត្រពាំងថ្មហ្នឹងហូរហែមក រហូតដល់ តារិន ទៀត រហូតដល់ការដ្ឋានហ្នឹង មិនអាចបញ្ចប់ទៅតាមការផែនការរបស់គេទេ។ អ៊ីចឹង ខ្ញុំចង់សួរលោកថា ក្នុងករណីដែលពួកគាត់ទាំងនុ៎ង មិនបញ្ចប់តាមផែនការហ្នឹងហើយគាត់អាចជួបនឹងបញ្ហាអីកើតឡើងចំពោះរូបពួកគាត់ដែរឬទេ ពេលនុ៎ង?

**ឆ៖** បញ្ហានោះ បើតាមដែលខ្ញុំជាអ្នកបើកអង្គរឲ្យគេនោះ ពីព្រោះនៅរដូវវស្សានេះ វាស្មុះ។ ស្មុះឯណា? ស្មុះការកាប់រណ្តៅអី វាអត់បានដំណើរការនេះទេ ព្រោះវាទៅជា គេចង់និយាយថា វាស្មុះធ្វើការអីមិនកើត វាទៅជាផ្អាក ផ្អាកហើយ គេចាត់ ដូចថា ប៉ុន្មានកងនេះ គឺត្រូវទទួលខុសត្រូវមើលជួស

ជុលតែម្តង គេអត់ទាន់នេះទេ ដល់រដូវប្រាំងគឺចាប់ទៀត។ អានេះ បើតាមខ្ញុំមើលនោះណាស់ ប៉ុន្តែ វាស្ទុះនោះ ទី១ ភ្លៀង, ទី២ កងចល័តនោះ ក៏មានការទ្រុឌទ្រោមថយចុះ ទៅដេកពេទ្យច្រើនដែរ បើតាម ខ្ញុំគិតមើលក្នុងនោះ ព្រោះការបើកអង្ករ វាអាចដឹងថាមនុស្សថយ មនុស្សអីយ៉ាងណាយ៉ាងណី ព្រោះ កាលណាទៅដេកពេទ្យច្រើន អង្ករវាទៅពេទ្យច្រើន។ បើកាលណាមនុស្សនៅនេះច្រើន អង្ករពេទ្យ វាខ្សោយ ដែលខ្ញុំអ្នកបើកនេះ ខ្ញុំគិតណ៎ា បាទ។

[១៥:២៣:២៨]

**ស៖** សូមអរគុណ។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់ឡើងវិញថា តាវ៉ាល់ ក្តី រហូតអ្នកដឹកនាំបន្តបន្ទាប់ ទៀត ដែលដឹកនាំការងារការដ្ឋានត្រពាំងថ្មហ្នឹង រហូតដល់ តារិន ទៀត រហូតដល់តារិន ហើយនៅតែ ធ្វើមិនទាន់ហើយទៀត។ តើចំណុចហ្នឹង អាចជាមូលហេតុនៃការដែលនាំឲ្យពួកគាត់ទាំងនុ៎ងបាត់ខ្លួនដែរ ឬទេលោក?

**ឆ៖** បាទ អារឿងការបាត់ខ្លួនរបស់គាត់ ខ្ញុំក៏មិនអាចសន្និដ្ឋានថា បាត់មកពីមិនសម្រេចផែនការ ទំនប់នោះ ឬក៏បាត់ខ្លួននេះមកពីមូលហេតុអី។ តែបើយើងសរុបដូចលោកសួរ -- អ្នកស្រីសួរខ្ញុំនោះ ត្រឹមត្រូវ ថាចាប់ពីនោះមក ទល់នឹងដែលបរាជ័យធ្វើអីដែលវាមិនបានសម្រេចនោះ គឺបាត់ខ្លួនអស់ ប៉ុន្តែមិនដឹងបាត់ទៅដោយសារអី ព្រោះខ្ញុំក៏វាលំបាកដែរ បាទ។

**ស៖** ខ្ញុំសូមធ្វើការបញ្ជាក់បន្តិច តាមរយៈលោកឆ្លើយអម្បាញ់មិញហ្នឹង អ៊ីចឹង ខ្ញុំចង់ធ្វើ ចង់សួរ មួយថា អ៊ីចឹងមានន័យថាការងាររបស់តាវ៉ាល់ ក្តី, ការងាររបស់ តាម៉ោង ក្តី, ការងាររបស់ តាសំអាត ក្តី ឬក៏តារិន ក្តី គឺការងាររបស់ពួកគាត់ទាំងអស់ហ្នឹង គឺសុទ្ធតែមានការក្តាប់ពីថ្នាក់លើ មានន័យថា ថ្នាក់លើសុទ្ធតែបានដឹងទាំងអស់អំពីការងាររបស់ពួកគាត់ មានន័យថាគាត់ធ្វើអី ក៏ថ្នាក់លើដឹងដែរ។ តើ អ៊ីចឹងមែនទេ លោក?

**ឆ៖** បាទ នេះ បើតាមខ្ញុំយល់ តែក៏វាមានព័ត៌មានអីដែលសម្រាប់ខ្ញុំខាងក្រោមដែរ ប៉ុន្តែនេះការ យល់ឃើញរបស់ខ្ញុំ ខ្ញុំថាគេអាចដឹង ពីព្រោះអ្នកខាងក្រោមធ្វើអីយ៉ាងម៉េចក៏ដោយ ក៏ខាងលើគេអាចដឹង ខ្លះ បើមិនបានដឹង១00ភាគរយ ក៏អាចជា៣0 ឬ៤0ភាគរយ បាទ។ តាមខ្ញុំគិតទេ បាទ។

**ស៖** សូមអរគុណ។ ពាក់ព័ន្ធជាមួយនឹងការដ្ឋានត្រពាំងថ្មហ្នឹងទៀត តើ -- ខ្ញុំចង់សួរលោកថា តើធ្លាប់មានកុមារគេទៅធ្វើការនៅទីនុ៎ងដែរឬទេ?

**ឆ៖** មានកុមារទៅទីនោះ ព្រោះខ្ញុំជាអ្នកបើកអង្ករ ខ្ញុំត្រូវតែដឹង ពីព្រោះកុមាររបបអង្ករ វា

ផ្សេងពីអ្នកធំ ហើយធ្វើការនោះ ក៏វាដូចថាគេដាក់ប៉ុនណានោះ ខ្ញុំអត់ដឹងដែរ ប៉ុន្តែឃើញកុមារហ្នឹងវាអាចឡើងមុនៗមនុស្សធំ។ ហើយអង្គរ បើគេបីកំប៉ុង កុមារបានតែពីរកំប៉ុងទេ បាទ។

[១៥:២៦:៣៩]

**ស៖** ចុះការងារដែលគេកំណត់ឲ្យកុមារធ្វើ គេកំណត់ទៅ -- គេកំណត់យ៉ាងដូចម្ដេចដែរ លោក?

**ឆ៖** វាពិបាកដែរ ព្រោះរឿងកុមារ បើតាមខ្ញុំគិត ខ្ញុំមិនអាចមានចម្លើយអីដែលច្បាស់លាស់ថា ១ម៉ែត្រគូប ឬក៏១,៥ ពីព្រោះអានោះ បើអ្នកមានសាក្សីណាដែលគេអាចធ្វើនៅក្នុងចល័តនោះ បានគេដឹង ពីព្រោះខ្ញុំៗមិនបានសួរទៅមើលអី ព្រោះខ្ញុំរវល់តែអង្គរដែរ តែខ្ញុំឃើញតែកុមារឡើងមុនគេ បាទប៉ុណ្ណោះឯង។

**ស៖** សូមអរគុណ។ តើកុមារដែលធ្វើការនៅក្នុងការដ្ឋានហ្នឹង មានអាយុចាប់ពីៗប៉ុន្មាន ដល់ប៉ុន្មានដែរ លោក? ហើយមានចំនួនច្រើនឬក៏តិច ពេលនុ៎ង?

**ឆ៖** ក្នុងកុមារដែលធ្វើការនៅក្នុងចល័តនោះ បើតាមខ្ញុំគិតតែរយៈពេលយូរ វាភ្លេច ដោយសារថា វាមិនបានគិតថាហេតុការណ៍វាកើតយ៉ាងនេះ តែខ្ញុំថាប្រហែលជាចាប់ពី ៦០០ ឡើងទៅ ១០០០ នៅក្នុងចល័តនោះ តែអាយុ បើតាមខ្ញុំឃើញកុមារដែលនោះ ប្រហែលជាមានអ្នក៧ឆ្នាំខ្លះ លាយឡំហើយនិងទៅរហូតចាប់ពី ១១ឆ្នាំទៅ ច្រើន ទៅដល់១៥, ១៦ បាទ។

**ស៖** ចុះពាក់ព័ន្ធជាមួយនឹងស្ត្រីមានផ្ទៃពោះវិញ តើនៅក្នុងការដ្ឋានត្រពាំងថ្មហ្នឹង គេមានប្រើស្ត្រីដែលមានផ្ទៃពោះ នៅទីនុ៎ងដែរឬទេ លោក?

[១៥:២៩:០៧]

**ឆ៖** នៅក្នុងចល័តតំបន់នោះ បើតាមខ្ញុំគិត មិនមាន។ សូម្បីតែអ្នកមានគ្រួសារហើយ ក៏គេមិនយកដែរ។ បើខ្ញុំមើលទៅអត់ទេ សុទ្ធតែយុវជននារីតែម្ដង។ បើអ្នកដែលមានបានគ្នាការនៅក្នុងកងចល័តនោះ គេបន្ថយឲ្យទៅធ្វើការដាំបន្លែ ដាំអីផ្សេងៗ សម្រាប់យកមកផ្ដល់ឲ្យចល័ត បាទ។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមបញ្ជាក់បន្តិច អ៊ីចឹងមានន័យថាស្ត្រីមានផ្ទៃពោះ មិនមានធ្វើការនៅនុ៎ងទេ ចុះប៉ុន្តែស្ត្រី តើមានស្ត្រីធ្វើការនៅក្នុងការដ្ឋានហ្នឹងអត់ លោក?

**ឆ៖** ទេបើតាមខ្ញុំគិត ពីព្រោះស្ត្រីបានន័យថាអ្នកមានប្ដី ប៉ុន្តែបើមានក៏តិចតួច ដូចខ្ញុំ យើងមិនបានជានឹងដឹងផងបើថាមានហ្នឹងណា ព្រោះខ្ញុំដឹងថារយៈកាលខ្លះនោះ ក៏ខ្លះក៏ពេលដែលចល័តបើកអង្គរច្រើនទៅក៏មានរត់ទៅចល័តក៏មាន។ ជួនកាលរត់ពីចល័តមកសហករណ៍ទៅ បើតាមយើងមើលណ៎ា

តែឱ្យឃើញថា ទាំងប្ដីទាំងប្រពន្ធទៅលើកដូចមិនមាន។

**ស៖** សូមអរគុណ។ លោកបានលើកឡើងថាស្ត្រីមានភាគតិច។ អ៊ីចឹង ខ្ញុំចង់សុំសួរបន្តិចទាំងស្ត្រីទាំងកុមារហ្នឹងពេលដែលគេឱ្យធ្វើការងារហ្នឹង ការលីសែង លើកដី លើកអីគេធ្វើដូចជាបុរសដែរ ឬក៏ម៉េចដែរលោក?

**ឆ៖** វាចេះ ដល់ថាសួរហ្នឹងវាពាក់ព័ន្ធនឹងថា ព្រោះមួយស្ត្រី មួយនារី ព្រោះខ្ញុំគិតថានារីជាមនុស្សលើវ ស្ត្រីជាមនុស្សដែលមានគ្រួសារ។ ហេតុនេះនៅក្នុងនោះភាគច្រើនគឺជានារីបាទ នារីយុវជន។ តែការងារធ្វើដូចគ្នា នារី ២,៥ម៉ែត្រ យុវជនក៏ ២,៥ម៉ែត្របាទ។ តែកុមារ អានោះខ្ញុំអត់បានក្ដាប់បានទេ ព្រោះអត់ដឹងហ្នង។

**ស៖** សូមអរគុណ។ អ៊ីចឹង ខ្ញុំសុំសួរលោកទាក់ទងជាមួយនឹងអាងត្រពាំងថ្មហ្នឹងដែរ។ លោកមានដែលឮពាក្យស្លោកមួយដែលគេនិយាយថា "ដើម្បីធ្វើស្ពានឱ្យជាប់ លុះត្រាតែយកស្ត្រីមានផ្ទៃពោះយកទៅសម្លាប់ដាក់ត្រចៀកស្ពាន ទើបស្ពាននោះជាប់" ឬមួយក៏ "សម្លាប់មនុស្សដាក់ទៅក្នុងស្ពាននោះទើបស្ពាននោះជាប់"។ តើលោកដែលឮពាក្យស្លោកហ្នឹងទេនៅក្នុងជំនាន់នោះ?

**ឆ៖** វាអ៊ីចេះ អារឿងពាក្យអី បើអ្វីដែលខ្ញុំឮ ខ្ញុំនឹងជម្រាបជូន តែពាក្យដែលនិយាយអំមិញនេះគឺខ្ញុំមិនបានឮតែហ្នង មិនដឹងថាគេប្រឌិតយ៉ាងណា ឬក៏គេធ្វើអ៊ីចឹងមែនឬក៏អត់ហ្នឹង វាពិបាកអ៊ីចឹងណ៎ា បានថាអ្វីដែលខ្ញុំដឹងប៉ុនណា ខ្ញុំនិយាយប៉ុណ្ណោះបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ មិនមែនថាជាការជំទាស់ ប៉ុន្តែខ្ញុំស្ដាប់ការបកប្រែមិនច្បាស់ សូមឱ្យមេធាវី ថាតើប្រភពព័ត៌មាននេះ យកមកពីណា? ពាក្យដែលថា ពាក្យស្លោកហ្នឹង។ ខ្ញុំមិនដែលឮពាក្យហ្នឹងពីមុនមកសោះបាទ។

[១៥:៣៣:១៥]

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណ។ ខ្ញុំសូមបញ្ជាក់ថា ប្រយោគនេះ គឺខ្ញុំដកស្រង់ចេញមកពី ឃ្លាមួយនៃដីកាដំណោះស្រាយ។ ដូច្នេះហើយបានជាខ្ញុំយកចំណុចនេះមកសួរបញ្ជាក់សាក្សីថា តើសាក្សីមានដឹងឮរឿងហ្នឹងដែរ

ឬក៏អត់? ហើយចំណុចមួយទៀត ខ្ញុំនឹងបញ្ជាក់ទៅនឹងសំណួរ នេះគ្រាន់តែជាការចាប់ផ្ដើម ហើយខ្ញុំនឹងមានការសួរសំណួរបន្តបន្ទាប់ទៀតដែលក៏មានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយដែរ។ អ៊ីចឹងហើយ ខ្ញុំនឹងធ្វើការតាំងសំណួរនៅពេលបន្តិចទៀតនេះ បន្ទាប់ពីសាក្សីគាត់ឆ្លើយ។ ចាស សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី លោកស្រីមានសំណួរប៉ុន្មានទៀត? ពីព្រោះពេលវេលាដែលអង្គជំនុំជម្រះផ្ដល់ឲ្យ សាមសិបនាទី ឥឡូវវាដល់ពេលហើយ?

**លោកស្រី ទី ស្រ៊ីនណា៖**

លោកប្រធាន ខ្ញុំមានពីរសំណួរចុងក្រោយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[១៥:៣៤:១៥]

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ខ្ញុំសូមសួរលោកថា តើលោកមានដែលធ្លាប់ដឹង ឬក៏ឮករណីដែលគេសម្លាប់ស្ត្រីដែលមានផ្ទៃពោះ រួចវាយរុញច្រានចូលទៅក្នុងអាងទំនប់ត្រពាំងថ្មហ្នឹងដែរឬទេ? ហើយមួយទៀត ក្រៅពីស្ត្រីមានផ្ទៃពោះ តើមានគេវ៉ៃសម្លាប់មនុស្សដើម្បីទម្លាក់ទៅក្នុងអាងត្រពាំងថ្មដើម្បីឲ្យស្ពានហ្នឹង ស្ពាននៃអាងត្រពាំងថ្មហ្នឹងឲ្យមានភាពរឹងមាំ? តើលោកមានធ្លាប់ដែលឮ ឬក៏ដឹងអំពីករណីហ្នឹងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំអត់ជំទាស់នឹងសំណួរនេះទេ ប៉ុន្តែសូមឲ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបញ្ជាក់អំពីកថាខណ្ឌណាមួយនៃដីកាដំណោះស្រាយ ដែលលោកស្រីបានលើកនេះ។ បាទ សូមអរគុណ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអាចជួយបាន ព្រោះខ្ញុំរកឃើញឃ្លានេះ មិនមែនជាពាក្យស្លោកទេ។ បាទ យកចេញមកពីសម្ដីសាក្សីទេ ដែលដីកាដំណោះស្រាយយោងទៅរកឯកសារនេះ គឺនៅក្នុងលេខយោង១៤៥២ កថាខណ្ឌ

២៤៩។ ហើយសាក្សីដែលនិយាយនោះ គឺខ្ញុំគិតថា គាត់បានឮពាក្យហ្នឹងពីកម្មាភិបាលបក្សកុម្មុយនីស្ត កម្ពុជា ដូចដែល ប៉ុន្តែមិនជាប្រាកដច្បាស់ថាដូចមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់នោះទេ។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមគោរពលោកប្រធាន កថាខណ្ឌនៅក្នុងដីកាដំណោះស្រាយដែលពាក់ព័ន្ធទៅនឹងចំណុចដែលខ្ញុំបានលើកខាងដើមហ្នឹង គឺស្ថិតនៅក្នុងកថាខណ្ឌ៣៤៩ ជាភាសាខ្មែរ។

ខ្ញុំសូមឲ្យសាក្សីជួយឆ្លើយសំណួរចុងក្រោយរបស់ខ្ញុំហើយនិងខ្ញុំមានសំណួរចុងក្រោយមួយទៀតដើម្បីបញ្ចប់។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយនឹងសំណួរនេះ!

**លោក ឈិត យឿក៖**

**ឆ៖** បាទ សំណួរដែលអ្នកស្រីសួរហ្នឹង ថាខ្ញុំបានដឹង បានឮ បានឃើញ តែខ្ញុំមិនបានដឹងរឿងទាំងអស់ហ្នឹង ព្រោះនិយាយឲ្យខ្លីទៅ គឺមិនដឹងតែម្តង អារឿងរ៉ៃអ្នកផ្ទៃពោះចោលម៉េច ស្ត្រីអីហ្នឹង។ តែអារឿងស្លាប់អីផ្សេងៗចេះដឹង តែអារឿងហ្នឹងដូចៗអត់ដែលបានឮ បានដឹង គេលាក់មិនឲ្យដឹងក៏មិនដឹង។

[១៥:៣៧:១១]

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរសំណួរចុងក្រោយ ខ្ញុំចង់សួរពាក់ព័ន្ធទៅនឹងទិដ្ឋភាពនៅក្នុងការដ្ឋានទំនប់ត្រពាំងថ្មហ្នឹង ដោយលោកធ្លាប់រស់នៅទីនុ៎ង ខ្ញុំគិតថាលោកប្រហែលជាអាចដឹង និងឃើញ និងផ្ទាល់ភ្នែកតាមរយៈបទពិសោធន៍របស់លោក។ ទាក់ទងទៅនឹងប្រជាជនដែលនៅក្នុងការដ្ឋានហ្នឹងទាំងមូលហ្នឹង តើរូបរាងកាយរបស់គាត់ម៉េចដែរពេលនុ៎ង? ហើយស្ថានភាពរបស់គាត់ហ្នឹងស្គម ធាត់ ឬមួយក៏យ៉ាងម៉េចដែរ? ហើយពេលនុ៎ងគាត់មាន--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់របៀបនៃការសួរសំណួរនេះ។ ខ្ញុំគិតថា សាក្សីអាចនឹងនិយាយអ្វីឲ្យប្រាកដទេ ពីព្រោះលក្ខខណ្ឌនៃជីវភាពរបស់កម្មកររាប់ពាន់ ដល់ម៉ឺននាក់ឯណោះគឺថា បើសិនជាអាចសួរទៅអ្នកណាដែល

គាត់ឃើញនៅក្នុងក្រុមជាក់លាក់របស់គាត់ អាហ្នឹងសមជាង។ បើសួរសំណួរជាទូទៅ លក្ខខណ្ឌ ឬក៏ស្ថានភាពរាងកាយរបស់កម្មកររាប់ពាន់ ឬក៏ម៉ឺននាក់នោះគឺមិនអាចទៅរួចទេ។

**លោកស្រី ទី ស្រ៊ុនណា៖**

សូមអរគុណ ខ្ញុំសូមធ្វើការកែតម្រូវសំណួររបស់ខ្ញុំឡើងវិញ។

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** លោកសាក្សី ខ្ញុំសូមបញ្ជាក់ជាមួយលោកបន្តិច ថាតើមនុស្សដែលលោកបានឃើញនៅក្នុងការដ្ឋាន ជាពិសេសគឺពាក់ព័ន្ធនឹងតំបន់ដែលលោកបានទៅដល់។ តើមានតំបន់ណាខ្លះដែលលោកបានទៅដល់ទីនុំង ហើយពេលដែលលោកទៅដល់ហ្នឹង លោកឃើញស្ថានភាពនៃប្រជាជនដូចជា -- ជាពិសេសពាក់ព័ន្ធនឹងរូបរាងកាយរបស់ពួកគាត់។ តើពីមួយតំបន់ទៅមួយតំបន់ហ្នឹងយ៉ាងម៉េចដែរ សូមឲ្យលោកជួយរៀបរាប់ឲ្យបានក្បោះក្បាយអំពីពីកន្លែងមួយទៅកន្លែងមួយទាក់ទងនឹងទិដ្ឋភាពប្រជាជនដែលធ្វើការនៅទីនោះ? សូមអរគុណ។

[១៥:៣៩:២៤]

**លោក ឈិត យឿក៖**

**ឆ៖** បាទ ប្រជាជន នៅក្នុងចល័តនោះដែលតាមខ្ញុំមើលឃើញមានស្គមខ្លះដែរ តែដែលស្គមភាពច្រើនគឺនៅរដូវវស្សា។ ព្រោះរដូវវស្សាការហូបចុកក៏កាត់បន្ថយអង្ករដែរ ហើយការស្នាក់នៅក៏វាមិនស្រួលបានដូចខែប្រាំង ព្រោះជួនកាលក៏ដេកបានលក់ ជួនកាលក៏ទទឹកភ្លៀងខ្លះ បើតាមខ្ញុំយល់។ ហើយពេលនោះហើយដែលមនុស្សទាំងអស់នោះត្រូវចុះសាច់ ស្គមស្គាំងហ្នឹងបាទ អានេះបើតាមខ្ញុំមើលឃើញ។

**ស៖** តើពួកគាត់ចុះសាច់ភាគច្រើន ឬក៏ភាគតិច ឬក៏យ៉ាងម៉េចដែរលោក ចំនួនមើលទៅប្រហាក់ប្រហែល?

**ឆ៖** ទេ បើតាមខ្ញុំគិតនៅអាពេលដែលចុះសាច់ ចុះរបបអីហ្នឹង ប្រហែលជាចង់នឹង៥០ភាគរយហើយ បើតាមខ្ញុំគិតទៅ ពីព្រោះនៅរដូវវស្សាបន្ថយរបប ហើយការជម្រកអី ក៏វាច្រើនតែលិចអីខ្លះដែរបាទ។

**លោកស្រី ទី ស្រ៊ុនណា៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំសូមអស់សំណួរហើយ ហើយនិងសូមផ្ទេរវេទិកាជូនលោកប្រធានវិញ ហើយសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកស្រីមេធាវី។

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការបញ្ជាក់ឆ្លើយតបទៅនឹងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានប្រសាសន៍អំពីកថាខណ្ឌ៣៤៩ នៃដីកាដំណោះស្រាយ។ ក្នុងចំណុចនេះក៏ដូចគ្នាដែរ គឺអត់មាននិយាយថា វាជាពាក្យស្លោករបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការយកស្ត្រីមានផ្ទៃពោះទៅសម្លាប់ ដើម្បីឱ្យស្ពាននោះរឹងមាំនោះទេបាទ។ វាគ្រាន់តែជាសម្ដីរបស់សាក្សី ដែលបានលើកឡើងក្នុងមតិនេះ បាទ។ សូមអរគុណ។

[១៥:៤១:៥៥]

**ប្រធានអង្គជំនុំ៖**

បន្តទៀត អង្គជំនុំជម្រះសូមផ្ដល់វេទិកាដល់មេធាវីការពារក្ដីលោក នួន ជា។

លោក ចៅក្រម ហ្វង់ម៉ាក ឡាវែន៍ មានសំណួរលើសាក្សី។

**ចៅក្រម ហ្វង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណប្រធាន ខ្ញុំមានសំណួរតែពីរបីប៉ុណ្ណោះ សួរទៅសាក្សីរូបនេះ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្វង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ លោកសាក្សី ខ្ញុំយល់ឃើញថា ក្រោយថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ លោកត្រូវបានគេបញ្ជូនទៅតាមភូមិក្នុងឋានៈជាឈ្លប។ តើលោកអាចបញ្ជាក់ជូនតុលាការបានដែរឬទេ ថាតួនាទីជាក់លាក់របស់លោក ក្នុងឋានៈលោកជាឈ្លបនោះ គឺធ្វើអ្វីខ្លះ?

**លោក ឈិត យឿក៖**

**ឆ៖** បាទ ពេលនោះឈ្លប គេឱ្យដើរមើលប្រជាជនដូចថា ខ្លាចប្រជាជនណាមានបញ្ហាអី ដែលដូចថា ព្រោះពេលដែលចប់ពីវាយឈ្នះលន់នល់មក គេខ្លាច ប្រជាជនណាដែលមិនចុះសម្រុង តែឈ្លបនោះដែរទេ ប៉ុន្តែគ្រាន់តែថា យើងអាចប្រាប់គេបើថា ពីណាអីយ៉ាងម៉េចៗ ក៏យើងត្រូវប្រាប់គេ ព្រោះយើងអត់ដឹងទេ បាទ នេះសំខាន់ទី១។ តែទី២ ឃើញតែឱ្យដើរទៅដើរមកទៅ វាមិនដឹងថាមានអី បើវា

អត់មានមនុស្ស មនុស្សគេប្រមូលឲ្យទៅនៅមួយកន្លែងអស់ហើយបាទ។

[១៥:៤៣:៤៦]

**ស៖** តើវិធីដែលឈ្លប ឬក៏លួចស្តាប់តាមដានប្រជាជននោះ គេធ្វើរបៀបណាដែរ? កាលណោះលោកទៅតាមដានប្រជាជនយ៉ាងដូចម្តេចដែរ?

**ឆ៖** ព្រោះពេលនោះ ខ្ញុំចង់និយាយថា ពេលនោះគេមិនអាចទាន់ដល់ឲ្យឈ្លបទៅស្តាប់ ទៅតាមដានអារឿងប្រជាជនថាទេ ប៉ុន្តែគេគិតថា ខ្លាចវាមានបះបោរពីកន្លែងណាមួយ ដែលគេបញ្ចប់សង្គ្រាមរួចហើយ វាមានអ្នកប្រឆាំងអីយ៉ាងណាៗនោះ អានោះគឺយើងគ្រាន់តែបានដឹង គឺប្រាប់គេ តែឲ្យទៅស្តាប់ ទៅស៊ើបអី អត់ទេ ទៅស្តាប់អារឿងប្រជាជននិយាយអី គឺអត់ទាន់ឈានដល់ទេជំនាន់នោះ តែដល់ក្រោយមក ខ្ញុំក៏វាឈប់បានពីឈ្លបនោះទៅបាទ។

**ស៖** អ៊ីចឹង បើសិនខ្ញុំយល់មិនច្រឡំទេ គឺថាលោកទៅតាមដានប្រជាជននោះ ដោយមិនលួចស្តាប់គេទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ មិនទៅលួចស្តាប់អីទេ ដូចថាកន្លែងណាដែលថា បះបោរ ចង់ធ្វើអីម៉េច តតេងតតាងទៅ យើងទៅរាយការណ៍ឲ្យឃុំ ឲ្យអីគេ បាទ។ អត់មានទៅលួចស្តាប់ទេ ព្រោះប្រជាជន គេប្រមូលទៅដេកមួយកណ្តុបអស់ហើយ គ្មានប្រជាជនផងបាទ។

**ស៖** ហើយអ្នកដែលគេឲ្យលោកទៅតាមដាន -- អ្នកដែលលោកត្រូវតាមដាននោះ គឺជាក្រុមមនុស្សជាក់លាក់ គឺចង់និយាយថា តើជាប្រជាជនចាស់ ឬក៏ប្រជាជ១៧មេសា?

[១៥:៤៥:៥៦]

**ឆ៖** បាទ ទេ បើអង្កាល់ដែលយើងបញ្ចប់សង្គ្រាមភ្លាមនោះ គេអត់បានគិតថា ចាស់ថ្មីអីទេ គឺពីណាក៏ដោយ ឲ្យតែប៊ានប្រឆាំង គឺតែគេដឹង ក៏មិនដឹងគេធ្វើរបៀបម៉េច ព្រោះវានៅកន្លែងតំបន់ដែលខ្ញុំនៅនោះ វាអត់មានអ្នកប្រឆាំង ដល់ទៅថាប្រុងរៀបបាញ់គ្នាទៅទៀត អត់ទេ។ ចប់ទៅក៏ចប់ទៅ ប៉ុន្តែក្នុងគេប្រាប់យើង ដូចថាមានអ្នកណាដែលចង់តទល់អីម៉េច មិនព្រមបញ្ចប់សង្គ្រាមនោះ ក៏យើងប្រាប់គេទៅ បាទ។

**ស៖** តើមានបទបញ្ជាច្បាស់លាស់ដែរឬទេ ពាក់ព័ន្ធនឹងជនជាតិវៀតណាម?

**ឆ៖** អត់ទេ ព្រោះរឿងជនជាតិវៀតណាមអី ខ្ញុំអត់ដែលបានពាក់ព័ន្ធទេ ព្រោះដូចថា យើងតូចតាចពិបាកណាស់ ព្រោះវាមិនដឹងរឿងវៀតណាម វៀតណី អានោះវាជារឿងរបស់ខាងលើទេ បើតាមខ្ញុំ

គិត ពីព្រោះវាកាលដែលយើងធ្វើឈ្លបធ្វើអីបន្តិចបន្តួចនោះ វាអត់បាននិយាយពាក់ព័ន្ធដល់វៀតណាមទេ។

**ស៖** ហើយកាលហ្នឹង លោកមិនដឹងថា គោលនយោបាយពាក់ព័ន្ធនឹងជនវៀតណាមហ្នឹងយ៉ាងណាផងនោះទេ អង្កាល់សម័យនុ៎ង អ៊ីចឹងមែនទេ?

**ឆ៖** បាទ សម័យនោះខ្ញុំមិនដឹង ដោយសារថាវាមិនដែលមានពីណាគេហៅទៅប្រជុំទៅម៉េចព្រោះធ្វើចេះតែធ្វើទៅ បាទ។

[១៥:៤៨:១១]

**ស៖** បើសិនជាអ្នកណាម្នាក់ទំនាស់នឹងសកម្មភាពបដិវត្តន៍ តើពួកគេត្រូវចាត់ទុកថា បានប្រព្រឹត្តកំហុសមួយ ហើយគេត្រូវចាប់បុគ្គលរូបនោះ ហើយបើករណីនុ៎ងកើតមាននោះ គឺអ្នកណាជាអ្នកសម្រេចចាប់បុគ្គលរូបនោះ?

**ឆ៖** នែ៎ បើតាមខ្ញុំគិត វាពីព្រោះ ពេលនោះអត់មានទាន់មានរចនាសម្ព័ន្ធស្រុក ឃុំអីច្បាស់លាស់ទេ ព្រោះវ័ល់វ៉ិលាយគ្នា ដូចថាពីណាមួយដែលថា គ្រប់គ្រងមួយកន្លែងនោះទាំងអស់ ក៏គ្រប់ទៅ ហើយបញ្ហាដែលអ្នកប្រឆាំង ដូចលោកនិយាយនោះ អានោះគេប្រគល់ឱ្យទៅខាងទ័ពមក។

**ស៖** តែខ្ញុំសួរថា អ្នកណាជាអ្នកចាប់បុគ្គលទាំងអស់ហ្នឹង ហើយនិងប្រគល់គាត់ហ្នឹងទៅឱ្យយោធា?

**ឆ៖** ព្រោះអាហ្នឹងវាបើតាមគិតគឺកន្លែងណាដែលវាមានបញ្ហា ដូចលោកនិយាយនោះ គឺយោធាគេចុះមកបណ្ដោយ។ ពីព្រោះគាត់នោះ គ្មានអ្នកណាមានអាវុធទេ បាទ អត់មាន។ យោធាចុះមកផ្ទាល់បណ្ដោយ។

**ស៖** បាទ យើងឮសាក្សីច្រើនដែលមកផ្ដល់សក្ខីកម្មនៅទីនេះ ដែលគាត់ជាទាហាន គាត់និយាយថា ឈ្លបជាអ្នកផ្ដល់ព័ត៌មានឱ្យ រាយការណ៍ឱ្យ។ ឥឡូវលោកនិយាយថា យោធាគេចុះមកខ្លួនគេតែម្ដង។ អ៊ីចឹងយើងនឹងបញ្ជាក់ចំណុចនេះនៅពេលក្រោយ។ ខ្ញុំសួរបន្តទៀត តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ អ្នកដែលមានសិទ្ធិអំណាចក្នុងការចាប់មនុស្សនុ៎ង មានផ្លាស់ប្ដូរទេ គឺថាឬក៏មានតែមនុស្សចង់និយាយថា ខ្ញុំចង់សួរថាតើការសិទ្ធិសម្រេចចាប់មនុស្សនុ៎ងមានប្រែប្រួលទេ ឬក៏គេនៅតែរក្សាក្បួនច្បាប់សិទ្ធិអំណាចចាប់ខ្លួនមនុស្សហ្នឹងរហូតដដែលពេញមួយរបបខ្មែរក្រហមតែម្ដង?

[១៥:៥០:៥៦]

**ឆ៖** បាទ រឿងការចាប់មនុស្ស ថាចាប់សម្លាប់អីទៅចុះ ដែលខ្ញុំមកដឹងនៅពេលក្រោយ នៅឆ្នាំ៧៨នេះ ខ្ញុំឮគេ មិនឮទេ ឮគេប្រជុំដូចថា ប្រធានចល័តអីនៅឯនោះទៅ តែខ្ញុំវាអាចឮដឹងទៅថា ការកាប់សម្លាប់ អ្នកខាងក្រោមមិនមានសិទ្ធិសម្លាប់មនុស្សដោយចិត្តខ្លួនឯងទេ គឺទាល់តែសម្រេចពីមជ្ឈិម ចាប់ពីឆ្នាំ៧៨មកហ្នឹង បានត្រង់ថាយ៉ាងម៉េចយ៉ាងណាទៀត ខ្ញុំអត់ដឹងដែរ។ ខ្ញុំឮតែប៉ុណ្ណោះ បាទ។

**ស៖** អ៊ីចឹងរហូតដល់ឆ្នាំ១៩៧៨ហ្នឹង តើអ្នកណាជាអ្នកមានសិទ្ធិអំណាចក្នុងការសម្រេចចាប់មនុស្ស ឬក៏សម្លាប់មនុស្សដែលគេចាត់ទុកថា បានប្រព្រឹត្តកំហុស? តើនៅថ្នាក់ភូមិ ថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់តំបន់ ឬក៏អ្នកណា? សូមលោកជួយជម្រាបជូនតុលាការឲ្យបានច្បាស់លាស់។

**ឆ៖** បាទ នៅពេលនោះ គឺពាក្យសម្ដីដែលគេប្រជុំ គេនិយាយថា និយាយរួម គឺទាល់តែមជ្ឈិមបានសម្រេចថា ត្រូវវាយចោល ឬក៏ទុកអី អាហ្នឹងបាន។ តែយើងខាងក្រោមអី ដូចមុនៗ អត់បានទេ។ នេះអ៊ីចេះ ភូមិ ឃុំអី អត់មានសិទ្ធិវាយមនុស្សចោល ដូចមុនទេ បាទ។

**ស៖** អ៊ីចឹងមុនឆ្នាំ១៩៧៨ហ្នឹង អាជ្ញាធរភូមិ ឃុំនោះ មានសិទ្ធិអំណាចសម្លាប់មនុស្ស តើខ្ញុំត្រូវយល់អ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ទេ អានោះ តាមការយើងគិតទាំងអស់គ្នាទៅ ប្រហែលជាអាចមានសម្លាប់ដោយចិត្តខ្លួនឯង មិនបានរាយការណ៍ទៅដល់លើ ដល់អីយ៉ាងម៉េច យ៉ាងណានោះ បានជាវាអាចមានផែនការមកអ៊ីចឹងក្រោយ៧៨ហ្នឹង បាទ។

[១៥:៥៣:៥៤]

**ស៖** អ៊ីចឹងនៅពេលដែលលោកនិយាយថា ចាប់ពីឆ្នាំ១៩៧៨ទៅ លោកប្រើពាក្យ "មជ្ឈិម"។ លោកសំដៅលើអ្នកណា "មជ្ឈិម" ហ្នឹង? ចង់សំដៅទៅលើអាជ្ញាធរស្រុក អាជ្ញាធរតំបន់ លោកសំដៅទៅលើអ្នកណាឲ្យច្បាស់លាស់តែម្ដង? បើសិនជាលោកអាចឲ្យឈ្មោះមនុស្សតែម្ដងនុ៎ង កាន់តែល្អ។

**ឆ៖** វាពិបាក រឿងការមជ្ឈិម ឬក៏នៅក្រោមមជ្ឈិមហ្នឹង អាហ្នឹងខ្ញុំវាពិបាកដែរ ពីព្រោះមជ្ឈិមនោះ បានន័យថាបើខ្ញុំគិតទៅអ្នកដែលធ្វើការខ្ពស់ជាងគេ ប៉ុន្តែត្រង់លោកគិតយ៉ាងណា អានេះខ្ញុំអត់ដឹងដែរ។ នេះតាមខ្ញុំគិតទេណ៎ា បាទ។

[១៥:៥៤:៥១]

**ស៖** យើងឧទាហរណ៍ ចង់និយាយថា ឧទាហរណ៍ដូច យាយថែមអ៊ីចឹង ចំពោះលោកនោះកាលនោះ គឺគាត់ហ្នឹងជាមជ្ឈិម ឬក៏យ៉ាងម៉េច?

**ឆ៖** អត់ទេ យាយថែម គឺគណៈស្រុក។ គេមិនឲ្យឈ្មោះថា មជ្ឈិមទេ។ មជ្ឈិម គឺលើតែម្តង បើចុះពីមជ្ឈិមមក វាមានអីៗមក។ ហេតុនេះ យាយថែម មិនអាចជាមជ្ឈិមទេ ព្រោះគាត់ជាស្រុកឬក៏ជំនួយតំបន់អី អស់ហើយបាទ។

**ស៖** ឥឡូវខ្ញុំចង់ឲ្យលោកពន្យល់នៅក្នុងចម្លើយរបស់លោកគឺឯកសារ E127/7.1.6, សំណួរចម្លើយ១២៤ នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោក។ លោកពន្យល់ថា ចាប់ពីឆ្នាំ១៩៧៨ ទៅការអនុវត្តមានការផ្លាស់ប្តូរ។ ខ្ញុំសុំដកស្រង់ តើក្នុងការអនុវត្តគឺការណែនាំនៅឆ្នាំ១៩៧៨ មិនត្រូវបានអនុវត្តទេឬ ព្រោះថាបុគ្គលមួយចំនួនត្រូវបានសម្លាប់ដោយមិនបានធ្វើការទៅថ្នាក់តំបន់ផង។ ហើយកន្លែងហ្នឹង ត្រង់ចំណុចនេះ លោកចង់និយាយយ៉ាងម៉េចដែរ ពេលដែលលោកនិយាយពាក្យពេចន៍ទាំងអម្បាលម៉ានអម្បាញ់មិញនេះ?

**ឆ៖** បាទ កាលដែលនិយាយហ្នឹង ព្រោះវាដូចថាខ្ញុំឧទាហរណ៍ឲ្យស្តាប់ទៅចុះ ដូចមួយ មេភូមិដូចថាមួយនេះ ប្រធានក្រុម ហេតុនេះប្រធានក្រុមមិនអាចសម្រេចអីបានទេ អាហ្នឹងទាល់តែប្រធានភូមិ ខ្ញុំលើកឧទាហរណ៍តូចឲ្យស្តាប់ណា៎ តែរឿងថា ត្រង់អនុវត្តបាន ឬមិនបាន អានោះខ្ញុំក៏មិនដឹងដែរ ព្រោះថាផែនការវាដាក់អ៊ីចុះមែន ប៉ុន្តែបើអ្នកខាងក្រោមមិនអនុវត្តបានទេ ចេះតែសម្លាប់បន្ត អាហ្នឹងវាពិបាកដែរ ខ្ញុំអត់ដឹងដែរ ពីព្រោះវាទៅតាមកន្លែង តាមតំបន់បាទ។

**ស៖** បាទ ខ្ញុំអានចម្លើយរបស់លោកនោះ លោកនិយាយថា មនុស្សមួយចំនួនត្រូវបានសម្លាប់ដោយមិនបានរាយការណ៍ទៅតំបន់ទេ។ លោកដឹងរឿងហ្នឹង លោកបានឃើញដោយខ្លួនឯង ដឹងឮដោយខ្លួនឯង ឬក៏លោកដឹងរឿងហ្នឹងដោយសារមានគេនិយាយប្រាប់លោក?

**ឆ៖** បាទ រឿងនោះវាមិនបានទៅឃើញខ្លួនឯង តែជំនាន់នោះវាអាចខ្សឹបខ្សៀវគ្នា វាបានដឹងខ្លះបាទ។ និយាយអ៊ីចេះបាទ។

[១៥:៥៨:១០]

**ស៖** នៅពេលដែលលោកធ្វើការខាងចែកអង្ករ តើមុខងាររបស់លោកមុខការរបស់លោកនោះត្រូវចែកខោអាវដែរឬទេ? ធ្វើការខាងភស្តុភារដែរឬទេ? ចង់និយាយថាកាលនោះ ភស្តុភារខាងសេដ្ឋកិច្ចនោះ ការងារលោកហ្នឹងគឺកម្រិតមកត្រឹមតែចែកអង្ករទេឬក៏យ៉ាងណា?

**ឆ៖** បាទ ខោអាវមិនជាខ្ញុំចែក តែប៉ុន្តែតាមកងអីគេខ្វះខោអាវមក គេយកក្រដាសស្នាមហ្នឹងមកឲ្យខ្ញុំ ខ្ញុំនឹងឲ្យទៅខាងពាណិជ្ជតំបន់ ដល់ពេលដែលត្រូវបានហើយ គេយក គេដឹកមកចែកខ្លួនគេតែ

ម្ដងបាទ។

**ស៖** ហើយគេចែកខោអាវប៉ុន្មានដងដែរក្នុងមួយឆ្នាំ?

**ឆ៖** បើតាមខ្ញុំគិតមិនសូវបានទៀងទាត់ដោយសារថា ព្រោះកាលគេឲ្យហ្នឹងទៅតាមកង្វះខាត។ បើសិនណាជាក្នុងប្រាំខែនេះ វាដាច់អស់ប៉ុន្មាននាក់អីប៉ុន្មាននាក់ គេឲ្យតាមនោះ។ អត់មានកំណត់ថាមួយឆ្នាំពីរដងអី អត់ទេ និយាយរួមគឺអ្នករហែកបន្តបន្ទាប់នោះ គឺគេដាក់នេះសុំទៅ ទៅពាណិជ្ជគេបាទ។

**ស៖** បាទ ខ្ញុំយល់ឃើញថា លោកទទួលបន្ទុកខាងចែកអង្ករទៅកងចល័ត តើលោកទទួលបន្ទុកក្នុងការចែកអង្ករទៅអ្នកទោសនៅតាមមន្ទីរសន្តិសុខដែរឬទេ? តើនៅពេលជាមួយគ្នា ហើយកាលនោះៗ លោកធ្វើការក្រោមបង្គាប់របស់អ្នកណាដែរ?

**ឆ៖** បាទ អង្កាល់នោះ ខ្ញុំនៅក្រោមការបង្គាប់របស់ តារិនៗ បាទ។

**ស៖** អ៊ីចឹងពេលដែលលោកចែកអង្ករទៅកងចល័ត លោកក៏ចែកអង្ករទៅមន្ទីរសន្តិសុខដែរ។ អ៊ីចឹងខ្ញុំសូមសួរលោកថា តើមន្ទីរសន្តិសុខនុ៎ងជាមន្ទីរសន្តិសុខណាដែរ?

**ឆ៖** បាទ មន្ទីរសន្តិសុខនោះ បើអង្កាល់ដែលខ្ញុំនៅចែកនោះ ចែកទៅអ្នកដែលវាយថ្មនៅភ្នំទ្រយោង នៅភ្នំលៀបយើងនេះបាទ ចែកទៅដែរ គឺត្រូវគេចែកទៅបាទ នៅវាយថ្មបាទ។

[១៦:០១:៥៦]

**ស៖** ហើយភ្នំទ្រយោងហ្នឹង គ្រាន់តែជាកន្លែងដែលគេវាយថ្មបំបែកទេ ឬក៏ជាកន្លែងដែលគេសម្លាប់មនុស្សដែរ?

**ឆ៖** មានកន្លែងសន្តិសុខគេនៅនោះដែរ ប៉ុន្តែការកាប់សម្លាប់នោះវា អ្វីដែលខ្ញុំមិនឃើញ ខ្ញុំមិនអាចជម្រាបជូនលោកបានទេ ព្រោះដឹងថាកន្លែងនោះវាមានកន្លែងសន្តិសុខគេមួយ ហើយវាលាយឡំជាមួយនឹងយុវចល័តដែលនៅវាយថ្មនោះផងបាទ។

**ស៖** តើមានមនុស្សប៉ុន្មាននាក់ធ្វើការ ហើយនិងឃុំខ្លួននៅភ្នំទ្រយោង ហើយលោកចែកអង្ករទៅទីនោះរហូតដល់ពេលណាដែរ?

**ឆ៖** ការដែលចែកអង្ករ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំដូចជាវីវក់បន្តិចហើយ ព្រោះថាមន្ទីរសន្តិសុខដែលយើងកំពុងតែនិយាយនេះហ្នឹង ដែលលោកចៅក្រម ឡាវែន៍ កំពុងតែចោទសំណួរនេះ វាកំពុងតែស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះនេះទេ។ នេះខ្ញុំគ្រាន់តែ ដែលនិយាយបំភ្លឺទេ ខ្ញុំមិនប៉ាន់ជំទាស់ គ្រាន់តែនិយាយបំភ្លឺ។ ខ្ញុំដូចជាឮសាក្សីនិយាយថា នៅសម័យនោះៗការចែកអង្ករទៅកងចល័តផង ហើយកងចល័តនោះធ្វើការនៅត្រពាំងថ្ម។ ហើយអ៊ីចឹងខ្ញុំចង់ដឹងថា តើការងាររបស់គាត់នោះធ្វើអ្វីខ្លះនៅពេលដែលគាត់ទទួលបន្ទុកក្នុងការចែកអង្ករនុ៎ង ចែកទៅកន្លែងណាខ្លះតែប៉ុណ្ណឹងទេ។

[១៦:០៣:៥៦]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** អ៊ីចឹងលោកអម្បាញ់មិញនេះ គឺលោកសាក្សី ខ្ញុំឃើញលោកចាប់ផ្ដើមឆ្លើយហើយ ឥឡូវសូមលោកជួយឆ្លើយបញ្ចប់តែម្ដងទៅ។

**លោក ឈិត យឿក៖**

**ឆ៖** បាទ ចាប់ពីដែលខ្ញុំបើកឲ្យរហូតទល់នឹងវៀតណាមចូល តែមនុស្សដែលតាមទូទាត់ក្នុងអង្ករនោះក៏មិនលើសពី៦០០។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណ។ ខ្ញុំអស់សំណួរហើយលោកប្រធាន ខ្ញុំអស់ពេលវេលាហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកចៅក្រម។ ឥឡូវនេះដល់ពេលវេលាសមស្របនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តនៅថ្ងៃចន្ទទី១៧ ខែសីហា ឆ្នាំ២០១៥ ដែលចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃចន្ទ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ឈិត យឿក បន្តបញ្ចប់ ហើយនិងផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-828 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណចំពោះលោក ឈិត យឿក ដំណើរស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃចន្ទទី១៧ ខែសីហា ឆ្នាំ២០១៥ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ឈិត យឿក វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃចន្ទ ទី១៧ សីហា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.កវិញចុះ និងបង្គាប់ឲ្យនាំខ្លួនទាំងពីររូបត្រឡប់មកចូលរួមសវនាការនៅថ្ងៃចន្ទ ទី១៧ ខែសីហា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

អញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៦ នាទី)*